ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ម៉ិញ លីចាន

ពន្លឺសំនៀងតែងសេចក្តី

ថ្នាក់ទី ១២

- ខ្លឹមសារប្រធានពន្យល់ មាន :
  - ពន្យល់បញ្ជាក់ទូទៅ
  - ពន្យល់លក្ខណៈតួអង្គ
  - ពន្យល់លក្ខណៈអក្សរសិល្ប៍
  - ពន្យល់សំដីតួអង្គ _តំនែងនិពន្ធប្បីង

ប្រធាន

- ខ្លឹមសារប្រធានពិភាក្សា
  - ពិភាក្សាទស្សនៈទូទៅ
  - ពិភាក្សាពីលក្ខណៈតួអង្គ
  - ពិភាក្សាពីលក្ខណៈអក្សរសិល្ប៍ _តំនែងនិពន្ធ

បកស្រាយផ្នែកលើអក្សរសិល្ប៍ថ្នាក់ទី១២

ព. ០៨៥
ព ១២.៩

www.budinst.gov.kh www.elibraryofcambodia.org

សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ស្រុង ចាន់ណា** ម្ចាស់គេហទំព័រ៥000ឆ្នាំ

សូមគោរពថ្លែងអំណរគុណចំពោះ

លោកវេជ្ជបណ្ឌិត ខ្ញៅ ឃុនសំរ៉ែង ជាប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា www.ceefoundation.org

និង **ករុណាខ្មែរ** www.karunacambodia.org

ដែលបានអនុញ្ញាតដល់គេហទំព័រ៥000ឆ្នាំ

យកសៀវភៅនេះមកដាក់ផ្សាយបន្តជាធម្មទាន

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ ។

ស្ថាដែនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

ពុទ្ធសាសនបណ្ឌិត្យ និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

អង្គការរីហ្សូ កូស៊ី-កៃ វិទ្យាស្ថានបើកទូលាយ

ការុណាខ្មែរ និង **មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្កេនដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

សៀវភៅទៅពន្លឺសំនេរតែងសេចក្តី ជាវណ្ណកម្មទី ១៤ របស់ខ្ញុំដែលបាន ជាក់ជូនជាវិភាគទានសំរាប់បួនៗសិស្សនុសិស្សទូទាំងព្រះរាជាណាចក្រកម្ពុជាសិស្សាស្វែងយល់ ។ ពិសេសបួនៗដែលនឹងត្រៀមប្រលងយកសញ្ញាបត្រមធ្យម សិក្សាកំរិតទី២ ពេលដ៏ខ្លីខាងមុខនេះ ។

រូបខ្ញុំដែលជាអ្នកនិពន្ធ មានជំនឿក្នុងចិត្តថា សៀវភៅនេះនឹងធ្វើអោយបួនៗទទួលបាននូវសមត្ថភាព តែងសេចក្តីមួយបែបទៀតបន្ថែមលើស្នាដៃនិពន្ធ សាស្ត្រាចារ្យ រៀបចុងដែលលោកបានបញ្ចេញទឹកដៃនិពន្ធសៀវភៅតែងសេចក្តី ជាច្រើនហើយបួនៗ ក៏បានអានរួចមកហើយនោះ ។

សៀវភៅនេះ នឹងជួយបន្ធូរភាពតប់ប្រមល់ក្នុងចិត្តរបស់បួនលើមុខវិជ្ជាតែងសេចក្តី ដោយរូបខ្ញុំបានរៀបចំប្រភេទប្រធានទៅតាមផ្នែក អមដោយអត្ថាធិប្បាយគំរូខ្លីៗ ។ ប៉ុន្តែខ្ញុំសូមនែនាំដោយខ្លីថា បើចង់អោយតំនែងសេចក្តីបួន បានលួចចាំបាច់បួន ត្រូវពង្រីកការយល់ដឹងអោយបានទូលំទូលាយពីប្រវត្តិសាស្ត្រ ជាតិខ្មែរ ពីអរិយធម៌ខ្មែរ ពីនយោបាយខ្មែរ ពីចិត្តគំនិតខ្មែរ និងចំនេះផ្នែកទស្សនវិជ្ជា ។ ពីព្រោះបណ្តាអក្សរសិល្ប៍ខ្មែរ ថ្នាក់ទី ១២ មានចំនែះទាក់ទងយ៉ាងស្និតរមួត ទៅនឹងផ្នែកដែលខ្ញុំបានបញ្ជាក់ខាងលើរួចមកហើយ ។

សូម បួនទទួលបានជោគជ័យក្នុងការប្រលងនាពេលខាងមុខនេះ ។

ធ្វើនៅថ្ងៃ ១០ ខែ មិនា ឆ្នាំ ១៩៩៧

ប៊ុញ- លីង៉ាន

សាស្ត្រាចារ្យអក្សរសាស្ត្រវិទ្យាល័យបឹងត្របែក

LIBRARY
HIST INSTITUTE
ពាក្យ ៥៧/៩៧

www.budimet.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

ស្វែងយល់ប្រធានពន្យល់

១-<u>ពន្យល់បញ្ហាឆ្ងៃ</u>

ក). <u>ចំណាប់ប្រធាន</u>

- ប្រាប់ហេតុ និង ផល

ខ). <u>ខ្លឹមសារសំខាន់</u>

- ការចង់ពៀរជាប្រភពនៃក្តីវិនាសដល់ខ្លួននិងជាតិ

- មានសីលធម៌និងវិជ្ជា អាចទ្រទ្រង់ ជីវិតមនុស្សអោយមានប្រជាប្រិយភាព និង វឌ្ឍនភាព ។

គ). <u>ទិដ្ឋានស្រាយសន្ទូច</u>

* ស្រាយពីសង្គម

* ស្រាយពីអក្សរសិល្ប៍

- ដោយពង្រីកសេចក្តីអោយទាក់ទងន័យពាក្យហេតុនិងផល ដែលប្រធានប្រាប់ភ្ជាប់នឹងឧទាហរណ៍ខ្លីៗ ។

<u>២. ប្រធានពន្យល់ជាសុភាសិតចាស់ប្រៀន</u>

ក). <u>ចំណាប់ប្រធាន</u>

- ប្រាប់គំនិតដែលទាក់ទងធម្មជាតិបាតុភូតផ្សេងៗក្នុងលោកយើងនេះ

ខ). <u>ខ្លឹមសារសំខាន់</u>

- ទំពាំងស្នងឫស្សី

www.budinst.gov.kh www.elibraryofcambodia.org

- បើមិនជួយចែវចូក កុំយកជើងរាទឹក
- ទូកទៅកំពង់នៅ

ខ). ឧទាហរណ៍

- ទំពាំងស្នងឫស្សី
- បើមិនជួយចែវចូក កុំយកជើងរាទឹក
- ទូកទៅកំពង់នៅ

គ). វិធានស្រាយសង្ខេប

* ស្រាយតាមន័យត្រង់ - និយាយសំរប
* ស្រាយតាមន័យធៀប - និយាយធៀបពីសង្គម មនុស្ស , លើកពីមនុស្ស ឬតួអង្គ ក្នុងអក្សរសិល្ប៍នានា

៣. ប្រធានបទលំលក្ខណៈតួអង្គ

ក). បំរាប់ប្រធាន

- ប្រាប់ឈ្មោះ តួអង្គ និងប្រាប់លក្ខណៈតួអង្គនេះ

ខ). ឧទាហរណ៍

- នារីក្នុងអក្សរសិល្ប៍ថ្នាក់ទី១២ មានសុឆន្ទៈ ក្នុងការបន្ធូរទុក្ខកង្វល់ជាតិនិងក្រុមគ្រួសារ
- សមជាមនុស្សមានជំហរវីរមាំពុះពារការលំបាកក្នុងជីវិត ។

គ). វិធានស្រាយ សង្ខេប

- ប្រាប់ចំនុចរាយរងផ្សេងៗ អោយបានច្រើន ដែលចំនុននោះបំរើលក្ខណៈតួអង្គក្នុងប្រធាន
- ប្រាប់ឧទាហរណ៍ភ្ជាប់លើចំនុចនោះ

www.budinst.gov.kh www.elibraryofcambodia.org

គំនិតចំប្រធាន	គំនិតតូចៗ
A- លក្ខណៈ:	a → ឧទាហរណ៍
តួអង្គរបស់ប្រធាន • បំបែកជា	b → ឧទាហរណ៍
	c → ឧទាហរណ៍
	d → ឧទាហរណ៍
	e → ឧទាហរណ៍

៥. ប្រធានបទលំលក្ខណៈអក្សរសិល្ប៍

១. បំរាប់ប្រធាន

- ក្រាប់ឈ្មោះរឿងនិងប្រាប់លក្ខណៈរឿងនោះ

២. ឧទាហរណ៍

- អក្សរសិល្ប៍ថ្នាក់ទី១២សុទ្ធតែមានបំនងបង្ហាញពីវប្បធម៌នៃជាតិខ្មែរ ។
- រឿងថៅកែចិត្តចោរបង្ហាញពីភាពអយុត្តិធម៌ក្នុងសង្គមខ្មែរ ។

៣. និយាយស្រាយសង្ខេប

- ប្រាប់ចំនុចតួចៗអោយបានច្រើន ដែលចំនុចនោះបំពីអោយ លក្ខណៈរឿងនៃប្រធានបានចោទឡើង
- លើកឧទាហរណ៍ភ្ជាប់លើចំនុចតួចៗនីមួយៗ

គំនិតប្រធាន	គំនិតតូចៗ
B- លក្ខណៈ:	១ → ឧទាហរណ៍
អក្សរសិល្ប៍ • បំបែក	២ → ឧទាហរណ៍
	៣ → ឧទាហរណ៍
	៤ → ឧទាហរណ៍
	៥ → ឧទាហរណ៍

www.budinst.gov.kh www.elibraryofcambodia.org

៥. ប្រភេទពន្យល់ពីតំណែងនិពន្ធរឿង(ទាក់ទងទៅនឹងសិល្បវិធីតែងរឿង)

ក). បំរាប់ប្រធាន

- ប្រាប់គោលដៅចុងក្រោយនៃរឿង- ផ្តើមរឿងដែលអ្នកនិពន្ធកំនត់ក្នុងរឿងរបស់គាត់ ។

ខ). ឧទាហរណ៍

- រឿងចៅកែចិត្តចោរ អ្នកនិពន្ធបានបញ្ចប់ដោយអោយពូហំចាញ់កំលាំងទឹកប្រាក់ ។

- រឿងភូមិតិរច្ឆាន បង្ហាញផ្នែកបញ្ចប់ដោយអោយចលនាតស៊ូរបស់រាស្ត្រខ្មែរបរាជ័យយ៉ាងជូរចត់ ។

គ). វិធានស្រាយសន្ទូប

- បង្ហាញពីកត្តាផ្សេងៗដែលមានក្នុងរឿងជាហេតុធ្វើអោយអ្នកនិពន្ធកំនត់សាច់រឿងរបស់គាត់បែបនេះ ។ ពោលគឺគាត់មិនចង់អោយរឿងគាត់ឃ្លាតចាកឆ្ងាយពី សច្ចភាព, តថភាព ។

កត្តាដោះអាចមកពី:

- សង្គម
- អ្នកជីកនាំ
- ជំនឿ
- កំហឹង
- សមត្ថភាព
- កាល:ទេស:
- មធ្យោបាយ
- ជីវភាព ។ល។

*ភ្ជាប់នឹងកត្តានីមួយៗគឺមាន ឧទាហរណ៍ជាក់ស្តែងស្របតាមសាច់រឿង

www.budinst.gov.kh www.elibraryofcambodia.org

៦. ប្រធានពន្យល់ពីសំដីតួអង្គក្នុងរឿងណាមួយ

ក). បំរាប់ប្រធាន

- លើកសំដីរបស់តួអង្គមកបង្ហាញរួចចោទអោយយើងស្រាយពីអត្ថន័យផ្សេងៗជុំវិញសំដីតួអង្គនោះ ។

ខ). ឧទាហរណ៍

- ក្នុងរឿងភូមិតិរច្ឆាននៅនិងជួននិយាយថា «បើសាវតារមិនកាន់ជើងបារាំងទេនោះ គួរទុកឈ្មោះយើងទាំងពីរនាក់ អោយជនជំនាន់ក្រោយបានស្គាល់ផង » ។

គ). ទិដ្ឋានស្រាយសង្ខេប

- ប្រាប់ជំនើរដើមទង សកម្មភាពនៃម្ចាស់ពំនោល (គេធ្វើអ្វីទស្សនៈដើម្បីអ្វី ?)

- ប្រាប់ពីទស្សនៈយូរអង្វែងរបស់ម្ចាស់សំដី(នៃនាំពីអ្វី? ធ្វើបែបណា? ផ្តល់ផលល្អត្រង់ណា ?)

ឆ្លើស្តីមានហើយ :	ប្អូនកុំកន្តើយ	មើលការអនុវត្ត
ប្អូនពិតជាយល់	ដឹងពិតប្រាកដ	ទំរង់បែបបទ
	ប្រធានពន្យល់ ។	
ខាងក្រោយមានផ្នែក	ដែលខ្ញុំបានចែក	មិនអោយវិលវល់
ទស្សនៈ- តួអង្គ	រឿងណានិមល	ចូរប្អូនឈប់ខ្ជល់
	សិក្សាមើលចុះ ។	

www.budinst.gov.kh www.elibraryofcambodia.org

ឃ្លាបានន័យ : «រាល់ទង្វើដោយកង្វះវិចារណញ្ញាណធ្វើអោយបាត់បង់សារៈប្រយោជន៍- បាត់ប៉ង់កិត្តិយស- បាត់បង់អាយុជីវិត» ។ ចូរបកស្រាយដោយលើកឧទាហរណ៍ពីក្នុងអក្សរសិល្ប៍ថ្នាក់ទី ១២ ដែលអ្នកបានសិក្សារួច ។

គំរោងតែង

១- ពន្យល់ពាក្យ

ទង្វើកង្វះវិចារណញ្ញាណៈ ការធ្វើអ្វីដោយគ្មានគិតមុខគិតក្រោយ- ពុំគិតគូរអោយបានល្អិតល្អន់

សារៈប្រយោជន៍ : ប្រយោជន៍ដ៏សំខាន់

- ធ្វើពុំបានគិតគូរល្អិតល្អន់ ⇒ វិនាសប្រយោជន៍ចំចែង, ស្គាប់ខ្លួន, អាប់យស ។

២. បកស្រាយ

ក. ទាក់ទងសង្គម

- ពួកជ្រុលនិយមប៉ុលពត→ បង្កវិនាសកម្មលើជាតិឯង⇒ ពួកវាវិនាស
- ពួកហ្សាស៊ីសអ៊ីស្លែរ → ធ្វើសង្គ្រាម ⇒ រលាយបំនងត្រួតត្រា, មនុស្សជាតិថ្កោលទោស, មនុស្សស្លាប់ជាច្រើន

ខ). ទាក់ទងអក្សរសិល្ប៍ថ្នាក់ទី ១២

រឿងភូមិគិរីប្លាន

- បាដេស + បរិវារខ្មែរ → កាប់សំលាប់ខ្មែរ- ធ្វើបាបឥតត្រាប្រណី
- នៅជួន → ប្រយុទ្ធពុំស្មាបស្មង់ព្រឹត្តការណ៍ជុំវិញអោយបានស្រួល

www.budinst.gov.kh www.elibraryofcambodia.org

<u>លទ្ធផល</u>

- រលាយអស់នូវអ្វីៗដែលខ្លួនប៉ុនប៉ងចង់បានមកតិជាច្រើនថ្កោលទោសរងគ្រោះដល់ជីវិត ។

<u>រឿងគុលីកំនែង</u>

- តាង៉ែត - យាយម៉ុក → ឥតងាករេ ទស្សនៈកម្មផល

- ចៅហ្វាយស្រុក - មេឃុំផាន់ អុងប៉ាងថាវ→ ប្រើអំណាចទ្រព្យបំផ្លាញសុមង្គលខ្មែរ ។

- យាយចាន់ នាងវ៉ែន → ភ្លើតភ្លើនប្រាក់

<u>លទ្ធផល</u>

- ទទួលបាននូវពាក្យរិះគន់ ស្លាប់ឥតតំលៃ

<u>រឿងព្រះអាទិត្យរះលើផែនដីចាស់</u>

- ថៅកែហុក - ឧកញ៉ាសំបូរសម្បត្តិ- តំនាងរាស្ត្រយើង → រំលោភចេតនាលើប្រពន្ធសម, ចោទប្រកាន់គ្មានមេត្តា - មាក់ងាយល្មើសគុណសម

- សម → ជឿលើការឃោសនា , លួចទ្រព្យគេ, សងសឹកសំលាប់ថៅកែហុក ។

<u>លទ្ធផល</u>

- អនាគតវិនាសខ្លួន

- ទទួលទណ្ឌកម្ម, គ្មានក្តីមេត្តា ពីបុគ្គលពាល

<u>រឿងថៅកែចិត្តចោរ</u>

- ពូហំ លង់ខ្លួនព្រមធ្វើតាមថៅកែចិត្តចោរ

www.budinst.gov.kh www.elibraryofcambodia.org

លទ្ធផល

- ប្រាក់កំប៉ងថង់កំដាច់លុយពុំបានខ្លួនជារៀងគុក

សេចក្តីអធិប្បាយ

I- សេចក្តីផ្តើម

ជាទូទៅយើងតែងសង្កេតឃើញថា បុគ្គលគ្រប់រូបមិនថា ចាស់ក្មេង អ្នកធំឬអ្នកតូច ព្រះសង្ឃ ឬគ្រហស្ថទេ ប្រសិនបើអ្នកទាំងនោះធ្វើនូវសកម្ម-ភាព ផ្សេងៗដែលពុំរិះគិតអោយបានល្អិតល្អន់ធ្វើតាមការនឹកឃើញ- តាមកំហឹងចិត្តពុះពារបស់ខ្លួន ។ អ្នកនោះតែងជួបប្រទះផលវិបាកធ្ងន់ធ្ងរជារឿយៗ គឺអាចរលាយបាត់បង់អស់រលីង នូវវត្ថុដ៏គាប់ចិត្ត អាចអោយដល់អាយុរួសក្តី តួនាទីរហូតឈានដល់សេចក្តីអន្តរាយជីវិតថែមទៀតផង ។ ក្នុងន័យនេះហើយ ទើបមានទស្សនៈមួយលើកឡើងថា «រាល់ទង្វើដោយកង្វះវិចារណញ្ញាណ ធ្វើអោយបាត់បង់នូវសារៈប្រយោជន៍បាត់បង់កិត្តិយសបាត់បង់ អាយុជីវិត» ។ តើទស្សនៈនេះបង្កប់នូវ អត្ថន័យដូចម្តេចខ្លះ ? តើក្នុងអក្សរសិល្ប៍ថ្នាក់ទី ១២ មានចំនុចត្រង់ណាខ្លះដែល ឆ្លើយតបនឹងទស្សនៈខាងលើនេះ ?

II-<u>តួសេចក្តី</u>

១. <u>ពន្យល់ពាក្យ</u>

ការធ្វើអ្វីៗដោយព្រាវៗស្មានធ្វើដោយពុំបានគ្រោងទុកធ្វើទាំងប្រថុយប្រថានពុំថ្លឹងថ្លែង ឆ្លងកាត់ការវិភាគរបស់ខ្លួនក្បាលឈ្មោះថា « ទង្វើកង្វះវិចារណញ្ញាណ»។ រីឯការ «បាត់បង់សារៈប្រយោជន៍ កិត្តិយស អាយុជីវិត » គឺចង់សំដៅទៅលើការពុំ ទទួលបាននូវអ្វីៗ ដែលយើងយល់ថា ជារបស់ដ៏សំខាន់គួរអោយចាប់ចិត្តជិតអារម្មណ៍អំណាចយសសក្តិត្រូវរលត់រលាយ-

www.budinst.gov.kh www.elibraryofcambodia.org

ដោយទទួល បានអភិញ្ញាតែភាពអាម៉ាស់ រួមទាំងជីវិតដែលជាវត្ថុដ៏មានតំលៃ ពុំអាចកាត់ថ្លៃបាន ក៏ត្រូវអន្តរធានផងដែរ ។ យោងតាមន័យពាក្យខាងលើនេះ យើងអាចកំនត់ ខ្លឹមសារបស្រួនៃទស្សនៈប្រធានបានថា ការធ្វើអ្វីៗដោយពុំវិភាគ អោយបានល្អិតល្អន់វាបណ្តាលអោយមនុស្សទទួលរងនូវការខូចខាតវត្ថុដ៏ សំខាន់គ្មានភាពល្បីដោយយសសក្តិ ថែមទាំងជីវិត ក៏ត្រូវស្លាប់បាត់បង់ ទៀតផង ។

២. <u>បកស្រាយ</u>

ផ្អែកលើន័យខាងលើបើយើងយកវាមកឆ្លុះបញ្ចាំងក្នុងប្រវត្តិសាស្ត្រ សង្គមជាតិកម្ពុជាខាពេលកន្លងទៅនេះ ពួកជ្រុលនិយម ប៉ុល-ពត បន្ទាប់ពី បានឡើងកាន់តាប់អំនាចនាកំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ គេបានបញ្ចេញនូវវិធានការបណ្តេញប្រជារាស្ត្រពីទីក្រុង ។ គេចល័តប្រជាជនឥតឈប់ឈរ ដោយគេកំនត់ថា គេនឹងបំបាត់អោយអស់នូវកម្មសិទ្ធិ ធ្វើអោយសង្គមមនុស្ស រស់នៅស្មើភាពគ្នា ។ មិនតែប៉ុណ្ណោះគេបាន កំទេចគ្មានសល់សាសារៀន មន្ទីរពេទ្យសប្បត្តិរម្យតមិជាតិ ហេដ្ឋារចនាសម្ព័ន្ធសង្គម សំលាប់បញ្ញាវន្ត ។ គេធ្វើបែបនេះ ព្រោះគេគិត ថា អ្វីៗទាំងនោះ ជាកំអែលប្រតិកិរិយា ។ អាស្រ័យដោយសារទង្វើបែបនេះជំរុញ របបពួកវាត្រូវដួលរលំយ៉ាងឆាប់រហ័ស គ្មានអ្វីអាចទប់ទល់បាន ។ ឈ្មោះនៃ របបនេះបានត្រូវអាសោចិត្តនលើឆាក អន្តរជាតិ ។ ពិសេសពួកនោះពុំអាចរក្សាជីវិត អោយស្ថិតនៅផែនដីខ្មែរតទៅ ទៀតបាន ។

ទន្ទឹមនឹងនេះដែរពួកហ្វាស៊ីសអាល្លឺម៉ង់ គេបានចចើងរាងបង្ហូត ឫទ្ធិបង្កាត់ភ្លើងសង្គ្រាមសកលលោកអោយឆេះសន្ធោសន្ធៅឡើង ។ គេធ្វើ ដោយពុំគិតប្រមាណដល់ទុក្ខវេទនារបស់មនុស្សរាប់សិបលាននាក់ ការរងិន

www.budinst.gov.kh www.elibraryofcambodia.org

ហោចសម្បត្តិដែលជាស្នាដៃមនុស្ស។ ចិត្តគេគិ ត្តោបក្តាប់ត្រួតត្រាពិភពលោក ធ្វើឱ្យពិភពលោកព្រឺស្ញើបញាក់សាច់កាលណាឮសូរឈ្មោះរបស់គេ ។ប៉ុន្តែមានឯណាបំនងរបស់អាល្មើម៉ង់ ត្រូវរលាយដូចផេះ ។ ជាតិខ្លួនត្រូវគ្រាំគ្រាមតិទូទៅសកលលោកថ្កោលទោស មេដឹកនាំជំរៃផ្សែត្រូវអន្តរាយជីវិតយ៉ាងទាន់ហន់ ។ បែបនេះមិន ខុសពីសុភាសិតបរទេសមួយឃ្លាថា «បុគ្គលដែលសាបព្រោះខ្យល់ រមែងទទួលព្យុះសង្ឃរា» ។

បើយើងបង្វែរទស្សនៈប្រធានអោយចូលខ្លួនទៅក្នុងអត្ថបទអក្សរសិល្ប៍ថ្នាក់ទី ១២ វិញម្តងក៏ឃើញថាអ្នកនិពន្ធខ្មែរ បានបង្កប់គំនិតនេះក្នុងរឿងរបស់គាត់ផងដែរ ។ យ៉ាងណាមិញរឿងភូមិតិរច្ឆានដែលជាវណ្ណកម្មរបស់លោក ខៀក-អំ និង ឌីក តាម បានគូសបញ្ជាក់អោយឃើញថា វត្តមានពួកអាណា-និគមនិយម បារាំងលើទឹកដីកម្ពុជា គេបានអនុវត្តនយោបាយកាប់សំលាប់ធ្វើទុក្ខបុកម្នេញរាស្ត្រខ្មែរឥតឈប់ឈរតាមរយៈការបង្ខំរាស្ត្រខ្មែរអោយពន្ធដារ កើនធ្វើទាហានច្បាំងបំរើប្រយោជន៍ពួកគេ ។ បាដេសយកអំនាចខ្លួនជាក់តុកត្រវាក់វាយដំអ្នកក្រាំងលាវ គ្មានត្រាប្រណី ។ គេពុំគិតដល់កង្វះខាតខ្មែរ ។ គេធ្វើយ៉ាងណាអោយតែចៅហ្វាយ ប៊ូហ្វាំងពេញចិត្ត និង បំប៉នដល់កិច្ចអភិវឌ្ឍន៍ប្រទេសបារាំង ។ អំពើដ៏កំព្រើលនេះជំរុញអោយបារាំងខាតបង់ជាបណ្តើរៗ នូវលាភសក្ការៈពីកម្ពុជា ដោយរាស្ត្រខ្មែរប្រឆាំងនឹងពួកគេទាមទារសិទ្ធិសេរីភាព និងឯករាជ្យជូនជាតិខ្លួន ។ ទន្ទឹមនឹងនេះ ឥទ្ធិពលបារាំងកាន់តែសាបរលាប ។ បាដេសក្តីក្តូចក្តី ត្រូវរាស្ត្រខ្មែរធ្វើបាតុកម្មព្រមានអោយពួកគេអន្តរធានជីវិតនៅនឹងកន្លែង ។

ជាមួយគ្នានេះដែរ ជុំវិញចលនាតស៊ូដែលដឹកនាំដោយនៅ- ជួន ។ យើងឃើញថា ការធ្វើរបស់ពួកគេនៅលើបារាំងនោះជាការសមស្របហើយ ។

www.budirst.gov.kh www.elibraryofcambodia.org

ប៉ុន្តែក៏អាចសន្មត់បានថា « ជាទង្វើកង្វះវិចារណញ្ញាណ» ផងដែរ ។ ពោលគឺគេធ្វើពុំមើលពីស្ថានភាពនៃ កំលាំងខ្លួនប្រៀបនិងកំលាំងបារាំង ។ គេពុំបានប្រមើលទៅលើគ្រោះថ្នាក់ដែលប៉ះពាល់ដល់សុវត្ថិភាពខ្លួននិងក្រុមស្ម័គ្រចិត្ត។ រែន យើងឃើញថា កុបកម្មដោយអាវុធរបស់ពួកគេត្រូវបានបញ្ចប់តែក្តី សង្ឃឹមរបស់ពួកគេនៅកណ្តាលផ្លូវពុំដល់គ្រើយ ភូមិស្រុកត្រូវបានស្គាយពីឈ្មោះក្រាំងលាវ ជា«ភូមិតិរច្ឆាន» ។ ខ្លួនគេព្រមទាំងបក្សពួក ត្រូវបានបារាំងសំពាយនិង បញ្ជូនទៅដាក់ក្នុងទៅក្នុងគុកនោះត្រឡាច ស្លាប់ចោលឆ្ងឹងនៅទីនោះ ។

ពិនិត្យមើលនៅក្នុងរឿងគួលីកំនែនបានបង្ហាញពីសកម្មភាពខុសបែបវេទនៃតួអង្គមួយចំនួនជាហេតុធ្វើអោយគេត្រូវបាត់នូវអ្វីៗសព្វបែបយ៉ាង ។ ក្នុងនោះ មានតាង៉ែត យាយម៉ុក ជាគោល ។ ព្រីទ្វាចារ្យទាំងពីររូបនេះ ទោះបីដឹងថា រាស្ត្រខ្មែរ រងទុក្ខវេទនាដោយពួកបរទេសត្រួតត្រាក្តី តែពួកគាត់នៅតែជឿថា «បញ្ហា នេះកើតពីកម្មពៀរវេរា » ។ ការជឿរបស់គាត់នាំអោយខ្លួនគាត់គិតពីបន់ស្រន់ចម្រើនអោយព្រះជាម្ចាស់ជួយ ។ ប៉ុន្តែមានឯណាព្រះជួយពុំបានជីវិតក៏ត្រូវស្លាប់ពេល ដែលរត់គេចពីស្រុក មកនៅភ្នំពេញ ។ ចំនែកខាងចៅហ្វាយស្រុក មេឃុំជាន់ អុងប៉ាវ ថាវ ពេលរាស្ត្រខ្មែរចិតក្នុងចង្កូមពួកអាណានិគម ។ ពួកគេគិតតែប្រព្រឹត្ត នូវអំពើពាលា ធ្វើបាបកូនក្រមុំរាស្ត្រដើរបំភិតបំភ័យកើនរាស្ត្រធ្វើជាកំនែនអោយបរទេស ។ អុងប៉ាវ ថាវ សង្កាត់កលិម អួសយកដីថ្មី ផ្ទះសំបែងពេលដែលលិម កំពុងទឹកចូលច្រមុះ ។ ទង្វើកង្វះវិចារណាញ្ញាណបានជំរុញអោយរាស្ត្រកើតក្តី ក្តៅក្រហាយ ជេរប្រទេចផ្តាសា រកអាក្រាតកើរីពួកនោះគ្រប់ៗមាត់ ។ តីធ្វើអោយ ពួកនោះសាបរណាបណោបឈ្មោះអ្វីៗដែលបានដោយក្តៅក្រហាយខ្លួនរស់តែឈ្មោះស្អុយច្រាស់ខ្ទុល ។

www.budirist.gov.kh www.elibraryofcambodia.org

មិនខុសពីរឿងគូលីកំនែនប៉ុន្មានទេ ។ លោកសួនសុរិន្ទជាម្ចាស់វណ្ណកម្មនៃរឿងព្រះអាទិត្យរះលើផែនដីចាស់ បានលាតត្រដាងពីករណីរបស់ថៅកែហុក ឧកញ៉ា សំបូរសម្បត្តិ តំណាងរាស្ត្រយើង បានជាន់ឈ្លីលើបំនងលួរបស់សម និង ភរិយា ដែលពួកគេបានសុំជ្រកកោន ធ្វើការអោយយកបៀវត្សចិញ្ចឹមខ្លួនប្រគល់ប្រាក់គ្រប់ចំនួនអោយគេវិញ ប្រមូលកម្មករបោះឆ្នោតអោយខ្លួន ។ ពួកទាំងបីនាក់នេះ បានប្តឹង ចោទប្រកាន់សម ជៀលតួះ សម ដោយពាក្យអសុរស ធ្វើអោយសមមានទោសជាបន្តបន្ទាប់ ។ ទង្វើនេះថ្វីត្បិតតែពេលនោះគេឈ្នះគេសំរេចបាន នូវអ្វីៗដែលគេចង់បានមែន តែវាគ្រាន់តែជាការបណ្តោះអាសន្ន ប៉ុណ្ណោះ ។ គឺមិនយូរមិនឆាប់វានឹងឆ្លើយតបពាក្យ សាមញ្ញថា «បាចអង្កាម បញ្ចាស់ខ្យល់ កម្មអកុសល តែងជួបផលជាអកុសល »។

ចុងក្រោយនេះគឺ ចំនុចដែលយើងមើលឃើញក្នុងរឿងថៅកែចិត្តចោរយកទៅឆ្លុះបញ្ចាំងលើទស្សនៈប្រធាន ។ យើងដឹងថាពូហាក់ចាត់ទុកថាជាអ្នកដែលធ្វើអ្វីៗដោយមិនសមហេតុផលដែរ ។ ជាក់ស្តែងគិតាត់បានយល់ព្រមនឹងថៅកែចិត្តចោរ បើកឡានបុកឡានថៅកែ ហុង លី ដើម្បីជួរយកប្រាក់១ម៉ឺនរៀល។ គាត់គិតតែពីបានខ្លួនឯង គិតតែពីចង់អោយគ្រួសារខ្លួនបានសុខឯអ្នកដទៃរងគ្រោះ គាត់ពុំនឹកនា ។ ទីបំផុតលុយក៏ពុំបានត្រូវថៅកែបំភ្លៃថាមិនដឹង ឮ ។ ពូហាត្រូវ ដេកក្រៀមក្រំ ក្នុងគុក មិនខុសពីការរស់តែខ្លួនតែស្លាប់ឈ្មោះសុងសូន្យ ។

ភ្លាប់នឹងនេះទៀតគឺថៅកែចិត្តចោរក៏សន្និដ្ឋានថាជាថៅកែដែលធ្វើអ្វីឥតវិភាគផងដែរ ។ ពោលគឺគេសំលឹងឃើញតែលាភសក្ការៈ , គេហ៊ានបំភ្លេចពាក្យសន្យាចេញ ពីបបូរមាត់ខ្លួនថ្មីៗ ដែលកម្មករួមអាជីពដឹងឮនឹងធ្វើសាក្សីអោយពួកវាគ្រប់ៗគ្នា ។ អំពើនេះថ្វីត្បិតតែអ្នកនិពន្ធពុំបានបង្ហាញពីផល -

www.budhist.gov.kh www.elibraryofcambodia.org

អវិជ្ជមាន ដែលថៅកែរូបនេះទទួលមែន ។ តែក្នុងដួងចិត្តរបស់ពួកហ៊ឹកមុក ក្រោមបង្គាប់ថៅ កែរូបនោះ កំពុងតែពុះកញ្ជ្រោលក្តៅរាប់រយអង្សា ។ កំដៅទាំងអស់នេះ វាក្រាកដជានឹងហូរបៀរស្រោចលើខ្លួនថៅកែចិត្តចោរអោយវិនាសអន្តរធានសព្វ បែប យ៉ាងនាថ្ងៃមួយពុំខាន ។

៣- <u>សរុបការពន្យល់</u>

រួមមកបញ្ហាដែលមនុស្សម្នាក់ៗចូលចិត្តដើរ បង្កសង្គ្រាមដំលោះរំខានសុភមង្គលអ្នកដទៃ ធ្មើទុក្ខបុកម្នេញលើអ្នកទន់ខ្សោយដោយអំណាចក្បត់នូវពាក្យសន្យា ប្រកាន់នូវជំនឿអ្វីមួយឥតថ្លឹងថ្លែង ទាំងអស់នេះកំនត់ថាជាទង្វើឥតពិចារណា ។ ដរាបណាមនុស្សប្រព្រឹត្តិបែបនេះនឹង ធ្វើអោយពួកគេរលាយអស់ រលឹងនូវទ្រព្យធន បុណ្យសក្តិ អាស្រូវ កេរ្តិ៍ ស្លាប់ទាំងខ្លួន ។ ហេតុផលបែបនេះ ឆ្លើយតបនឹងទស្សនៈដែលបានលើកឡើងថា «រាល់ទង្វើដោយកង្វះវិចារណញ្ញាណ ធ្វើអោយបាត់បង់សារៈប្រយោជន៍បាត់បង់កិត្តិយសបាត់បង់ជីវិត» នោះ ។

III- <u>យោបល់</u>

យោងលើអត្ថន័យដែលបានបកស្រាយរួមផ្សំជាមួយភស្តុតាងក្នុងសង្គមមនុស្ស និងក្នុងអក្សរសិល្ប៍ យើងអាចវាយតំលៃបានថា ទស្សនៈប្រធានមានន័យល្អជ្រាលជ្រៅ ក្រៃលែង ។ ដោយអកពីទស្សនៈនេះរួមចំនែកផ្តល់ជាគតិដល់ជនគ្រប់រូបអោយមើលឃើញយ៉ាងច្បាស់ពីផលអាក្រក់ ដែលកើតចេញពីសកម្មភាព ព្រៃផ្សៃ ភ្លើនភ្លើនភ្លេចខ្លួន បំពានសិទ្ធិមនុស្ស ដោយឥតគ្រិះរិះអោយបានវែងឆ្ងាយ ។ ផ្តើមចេញពីនេះគួរតប្បីអនុជន ទាំងឡាយបើមុននឹងហាស្តី មុននឹងធ្វើអំពើអ្វីមួយនោះ គោងប្រើពេលវេលា សិក្សាគិតគូរអោយ

www.budinst.gov.kh www.elibraryofcambodia.org

បានត្រប់ជ្រុងជ្រោយ ។ បើធ្វើបានបែបនេះវានឹង កាត់បន្ថយបាននូវគុណ វិបត្តិដែលនឹង កើតមានក្រោយ អំពើដែលម្នាក់ៗបានប្រព្រឹត្ត ។

បើគិតមុនក្រ	ផលល្អគង់ឃ្យរ	ជាងក្រមុនគិត
ប្រសិនបើខុស	មិនឆ្ងាយការពិត	ទៅនឹងគំនិត
នៃដំណូចៅ ។		

ម៉ិញ - លីចាន
វិទ្យាល័យបឹងត្របែក

www.budinst.gov.kh www.elibraryofcambodia.org

ប្រយោគទី២ : **សំឡេងវោហារសំឡេងមួយឃ្លាស្រដីថា « ការស្គាល់ពីកាលៈទេសៈនិងទីតាំងច្បាស់លាស់ធ្វើអោយទទួលបានជោគជ័យដ៏ត្រចះត្រចង់»។ ចូរបង្ហាញ ដោយគូរប់ខ្ទង់ហេតុ៣ពីក្នុងអក្សរសិល្ប៍ថ្នាក់ទី ១២ ។**

គំរោងតែង

១- ពន្យល់ពាក្យ

ការស្គាល់កាលៈទេសៈ = ការដឹងច្បាស់ពីពេលវេលា

ទីតាំង = មូលដ្ឋានស្ថានភាព ភូមិសាស្ត្រ

- ស្គាល់ពេលវេលា និងស្ថានភាពភូមិសាស្ត្រ → សំរេចជ័យជំនះ ឈ្នះឬសំរេចបានផលជ័ល្អប្រសើរ ។

២- បកស្រាយ

ក- ទាក់ទងសង្គមមនុស្ស

ឃ្លេញ → ដឹងតំរូវការអតិថិជន → ទាំនិញ + ផលិតទំនិញតំរូវការប្រើប្រាស់ + ជើសកន្លែងលក់ដូរសមរម្យ ⇒ ទំនិញលក់គ្មានសល់បានប្រាក់ចំនេញច្រើន

កសិករ → ស្គាល់រដូវធ្វើស្រែ វស្សា- ដាំដំនាំ- ខែប្រាំង + ជើសដីល្អ ជាំដុះ ក្បែរប្រភពទឹក ⇒ កសិផលល្អ កោគផលកើន ជីវភាពធូរធារ

ខ- ទាក់ទងអក្សរសិល្ប៍ថ្នាក់ទី ១២

*** រឿងភូមិគិរីប្លាន**

- បាតុករភូមិក្រាំងលាវ ដឹងបាដេសនិងបរិវារប្រមូលផ្តុំច្រើនប្រជារាស្ត្រភាគច្រើនកំពុងអានកំហឹងបាដេស+ លើកគ្នាទៅសាលាស្រុកសន្ធាប់ព្រម

www.budinst.gov.kh www.elibraryofcambodia.org

គ្នាលើបារាំង ⇒ កំទេចបាដេសនិងបរិវារបានដួចបំនង ។

* **រឿងគូលីកំឆែន**

- ម៉ឺងដឹងថា កំលាំងបារាំងស្រុតចុះ ពិភពលោកប្រឆាំងបារាំង

+ តស៊ូក្នុងតំបន់ដែលអំនោយផល ⇒ ដណ្តើមឯករាជ្យជូនកម្ពុជា បានដោយជោគជ័យ រួមរស់នឹងគ្នា រស់ ។

* **រឿងព្រះអាទិត្យថ្មើរលើផែនដីចាស់**

- **ថៅកែឃុក និង លោកយ៉ង** ដឹងថា មន្ត្រីខ្មែរវង្វេងប្រាក់ សង្គម អយុត្តិធម៌ រាស្ត្រនៅទន់ខ្សោយផ្នែកស្មារតីគ្មានបង្អែក+ ប្រឆាំងនឹងតវ៉ាខ្លួននៅផ្ទះខ្លួន ⇒ គេរួចពីការចោទប្រកាន់ រាស្ត្រពុំអាចចាប់កំហុសបានក្លាយជាតំនាងរាស្ត្រ

- សមដឹងថាចលនាសង្គមរាស្ត្រនិយម កំពុងមានចលនាពង្រីកជនបទ +សមទៅនៅស្រុកកំនើត ⇒ សមមានជីវភាពធូរធារ មានមុខមាត់ឡើងជាតំនាងកសិករ មានសិទ្ធិសេរីភាពពេញបរិបូរ ។

* **រឿងថៅកែចិត្តចោរ**

- ថៅកែចិត្តចោរ ក្តាប់បានស្ថានភាពពូហំ ពេលវេលាពូហំត្រូវការប្រាក់ជាបន្ទាន់ + តវ៉ា នឹងសមនៅផ្ទះខ្លួន ⇒ គេអាចប្រើសមធ្វើការតាមបំនងខ្លួនផុតពីទោស ។

<u>សេចក្តីបញ្ជាក់</u> : សំរាប់ពេលប្រលងបួនពុំចាំបាច់ ដាក់លេខ បញ្ជាក់ចំនែកនីមួយៗ ដូចក្នុងអធិប្បាយទេ ។ អ្វីដែលខ្ញុំដាក់គឺចង់បញ្ជាក់អោយបួនងាយស្រួល ចងចាំនិងស្គាល់ពីវិធានសរសេរលើផ្នែកនីមួយៗ ។

www.budinst.gov.kh www.elibraryofcambodia.org

សេចក្តីអធិប្បាយ

I- សេចក្តីផ្តើម

ដើម្បីជាផ្លូវធ្វើអោយមនុស្សអាចរកឃើញពន្លឺសុខៈរង្គនៈសុភមង្គល និងសំរេចបាននូវអ្វីៗ នោះបណ្តាបណ្ឌិត បញ្ញាវ័ន្ត ឬក៏ដូចជាទស្សនវិទូធំៗ តែងតែប្រើអស់បញ្ញាញាណបញ្ចេញជាមតិ យោបល់ប្លែកៗ ទៅតាមការរកឃើញរបស់ខ្លួន ។ ក្នុងចំនោមនោះយើង ឃើញមានសំនួនវោហារសំដីមួយម្តាត់ថា « ការស្គាល់ កាលៈទេសៈនិងទីតាំងច្បាស់លាស់ ធ្វើអោយទទួលបានផោគជ័យដ៏ត្រកះត្រចង់ » ។ តើសំដីនេះមានអត្ថន័យយ៉ាងណាខ្លះ ? ចុះក្នុងអក្សរសិល្ប៍ខ្មែរ ឬក៏ទី១២ បានបង្ហាញត្រង់ណាខ្លះ ដែលជាការឆ្លើយតបនឹងសំដីខាងលើនេះ ? ។

LIBRARY

II-តួសេចក្តី

១- ពន្យល់ពាក្យ

ការដែលមនុស្សម្នាក់ៗដឹងពីការបត់បែនការសម្រួលនៃរបៀបទៅតាមជាតិការវិវត្តពៃលវេលា នោះឈ្មោះថា « ការស្គាល់ពីកាលៈទេសៈ » ។ រីឯការដែលដឹងច្បាស់ពីស្ថានភាពភូមិសាស្ត្រ មូលដ្ឋានស្ថិតនៅទីណាមួយកំនត់បានថា « ការស្គាល់ទីតាំង » ។ រាល់បុគ្គលត្រប់រូបកាលណាយល់ដឹងនូវចំនុចទាំងពីរយ៉ាងខាងលើវាជំរុញអោយបុគ្គលទាំងឡាយនោះ អាចយោងចាប់បាននូវជ័យជំនះអាចទទួលបាននូវអ្វីៗគ្រប់យ៉ាង សមតាមចិត្ត ដែលខ្លួនប៉ងប្រាថ្នាជាក់ជាពុំខាន។

២- បកស្រាយ

ឈរលើអត្ថន័យខាងលើក៏យើងបានឃើញយ៉ាងប្រតុក្បុតនឹងភ្នែក

www.budinst.gov.kh www.elibraryofcambodia.org

ចំពោះពាណិជ្ជករទូទៅ ដែលគេអាចទទួលបានផលចំនេញច្រើនពីមុខរបរខ្លួន ទុនរបស់ពួកគេកាន់តែកើនចំរើនឡើងឥតឈប់ឈរ។លទ្ធផលនេះគឺផ្តើមចេញពីគេក្តាប់បានយ៉ាងណែនន្លូវស្ថានភាព នូវតំរូវការចាំបាច់នៃពលរដ្ឋក្នុងប្រទេសនីមួយៗជាក់ស្តែងនៅកម្ពុជាបច្ចុប្បន្នកំពុងត្រូវការកសាងប្រទេសខ្ទេចខ្ទីដោយសង្គ្រាម ។ ពួកគេបាន ផលិតឬនាំចូលនូវមុខទំនិញដែល បំរើអោយការសាងសង់គ្រប់ប្រភេទ ។ រួមផ្សំជាមួយនេះគេតែងបានជ្រើសរើសទីកន្លែងលក់ដូរទំនិញ ដែលអាចទាក់ទាញភ្នែកនិងអារម្មណ៍អតិថិជនអោយឆាប់ឃើញឆាប់ដឹងច្បាស់ លាស់ ។ ដោយឡែក កសិករ ដែលរស់ដោយកសិកម្ម ជាំជុះស្រូវ បន្លែ បន្ទុក និង ផ្លែឈើសព្វសារពើ ។ ពួកគេតែងតែ ពិនិត្យជាដំបូងនូវរដូវជាំជុះ ។ គឺថា បើរដូវវិស្សាគេជាំស្រូវ ។ រដូវប្រាំងគេជាំបន្លែបង្គារ ។ ព្រោះរដូវវាជាដើមចមនៃ ភាពងាយស្រួលដល់ការលូតលាស់ដំណាំដែលខ្លួនជាំជុះ ។ ទន្ទឹមនឹង នេះដែរគេ នៅបានជ្រើសរើស ជីពូជដំណាំ អោយសមស្រប ។ ពិសេសគឺប្រភពទឹកក្នុងការ ស្រោចស្រពដំណាំ ។ ជាការពិតណាស់ ជីវាបណាដែលកសិករច្បាមជាប់នូវចំនុច ទាំងពីរនេះ គេរមែងតែងតែទទួលបានទិន្នផលខ្ពស់ពីការងារខ្លួនជីវភាពរបស់ពួកគេធូរធារកើនឡើងជាលំដាប់ ។ ការបង្ហាញប៉ុណ្ណោះសបញ្ជាក់អោយឃើញថា «ការស្គាល់កាលៈទេសៈ និងទីតាំងច្បាស់លាស់ តែងទទួលបានជោគជ័យដ៏ត្រចះត្រចង់» ។

ប្រសិនបើយើងក្រឡេកមើលទៅក្នុងរឿងភូមិតិរច្ឆានវិញម្តង ។ រឿងបាន បកស្រាយពីចលនាជីវិតរបស់អ្នកស្រុកក្រាំងលាវ ដែលជាព្រឹត្តការណ៍ដ៏ធំធេងក្នុងប្រវត្តិសាស្ត្រខ្មែរ ។ បាតុភូតទាំងអស់យល់ពីពេលវេលាច្បាស់លាស់ត្រង់គេដឹងថា ពេលគេធ្វើនោះចំពេលដែលបាដេសនិងបរិវារកំពុងតំឡើងធ្នូងបញ្ចេញចង្កូមដាក់ប្រជារាស្ត្រពុំទាន់បង់ពន្ធកាតគ្រប់ចំនួន ហើយក៏

www.budirst.gov.kh www.elibraryofcambodia.org

ចំពេលក្រុមគ្រួសារខ្មែរ ជាច្រើនកំពុង ទ្រាំពុំបាននឹងគំនាបបារាំងដែលធ្វើ ទារុណកម្មលើប្តីលើកូនខ្លួន ។ ស្របគ្នានេះទៀតគេដឹងពីស្ថានភាពភូមិសាស្ត្រ ប្រយុទ្ធដោយកំលាំងលើបាដេស ពុំអាចតវ៉ៃខ្លួនបានទេ ព្រោះទីកន្លែងតយុទ្ធ របស់គេនោះមានមនុស្សកកកុញនិងពុំអោយសត្រូវខ្លួនបំពួនអាត្មាបាន ។បញ្ហា នេះហើយជាដើមហេតុ អាចអោយពួកគេអាចកំទេចបាដេស អោយស្លាប់នៅ និងកន្លែងបាន ។ ព្រមជាមួយនេះដែរគេបានក្របួចពួកដែលស្និទ្ធិនឹងបារាំង អោយរកច្រករត់ទៅណាពុំរួចក៏អន្តរធានក្នុងពេលជាមួយគ្នានោះទៅ ។

កំនែកឯរឿងគួលីគំណែនឯណោះវិញ ។ ម៉ឺងជាតំនាងអោយខ្មែរមួយ រូបដែលបានធ្វើអោយកម្ពុជាទទួលនូវឯករាជ្យនាឆ្នាំ ១៩៥៣ ។ គេក៏ជាតំនាង អោយយុវជនដែល សំរេចជោគជ័យក្នុងបញ្ហាស្នេហា ។ គីគេបានអ្នកគ្រួរស់ជា រាជការស់នៅយ៉ាងសុខសាន្ត ។ នេះគឺមកពីមូលហេតុអ្វី ? ។ យើងអាចឆ្លើយ បានថាមកពីម៉ឺងស្គាល់ ពីកាលៈទេសៈ និងទីតាំងច្បាស់លាស់នោះឯង ។ ដូយ៉ាងគីគេ ជ្រួតជ្រាបពីសភាពការណ៍សកលលោក ដែលបណ្តាប្រទេសចិត នៅក្រោមនឹម ត្រួតត្រារបស់បារាំង កំពុងសំពងព្រមៗគ្នាទេលើពួកបារាំង ដើម្បីអោយបារាំង ដកថយពីប្រទេសគេ ប្រគល់ឯករាជ្យពេញលេញដល់គេ ។ បញ្ហានេះជាកំលាំង ចលករជំរុញអោយបារាំងទន់ខ្សោយ ហើយត្រូវតែសំរេច កិត្តប្រគល់ស្វ័យភាពគ្រប់ ដល់កម្ពុជា ដែលគេកំពុងទាមទារអោយបារាំង ធ្វើដោយពុំខាន ។ ត្រង់នេះមាន ន័យថាម៉ឺង ស្គាល់ពី សភាពការណ៍ដូនជាម របស់បារាំងរួចហើយគេក៏បានយក ឱកាសនេះទៅចូលរួមក្នុងកំលាំងតស៊ូដែល ធ្វើសកម្មភាពនៅកន្លែងមានចំនួន ប្រជារាស្ត្រខ្មែររងគ្រោះដ៏ច្រើនកុះករ ។ ពួកគេមានគំនិតឯកច្ឆ័ន្ទ ស្រុះស្រួលមូលមតិគ្នា ផ្តាច់អំណាចត្រួតត្រារបស់ បារាំងពីទឹកដីរបស់ខ្លួនអោយអស់ជាសាពរ ។

www.budinst.gov.kh www.elibraryofcambodia.org

បើនិយាយពីលោក សួន សុរិន្ទ វិញ។ លោក បានយកទស្សនៈរបស់ប្រធានមកបង្កប់អោយឃើញផងដែរនៅក្នុងរឿងព្រះអាទិត្យរះលើផែនដីចាស់របស់គាត់ ។ ចំនុចនេះគឺនៅត្រង់ គាត់បានបង្ហាញពីករណីថៅកែហុក និង លោក យើង ដែលជាតំនាងរាស្ត្រ ។ អ្នកទាំងពីរដណ្តើមប្រៀបឈ្នះលើសមជាច់តែម្តង។ ដោយគេរលាស់ ខ្លួនចេញឃាតកម្មដែលបង្កដោយសម និងបានធ្វើអោយសមក្លាយជាទណ្ឌិត ដេកនៅគុកបានយ៉ាងងាយ ។ ឯលោកយើងធ្វើអោយសមរឹងថ្ពាម ពុំអាចតបតពីងពាក់ទំលាក់កំហុសចំពោះរូបគេបានក្នុងករណីដែលសមចោទគេថា «តំណាងរាស្ត្របោកប្រាស ជាជនរមិលគុណជាជនដល់ត្រីយសើយគួន»។ លទ្ធផលដែលអ្នកទាំងពីរសំរេចបានបែបនេះអាស្រ័យមកពីគេស្គាល់ ពីកាលៈ ទេសៈ គឺដឹងថាស្ថាប័នមានសមត្ថកិច្ចខ្មែរឈ្លក់វង្វេងនឹងទឹកប្រាក់ សង្គមខ្មែរ ពោរពេញទៅភាពលំអៀង ទៅរកនាយទុន និង អ្នកដែលមានតួនាទីខ្ពស់ ។ ពិសេសប្រជារាស្ត្រនៅមានការយល់ដឹងទាប ពុំទាន់អាចមានលទ្ធភាពប្រជែង យកឈ្នះអំពើបំពានច្បាប់របស់ពួកខ្លួនបាន ។ បន្ថែមពីលើនេះ ការវិវាទរបស់គេ នឹងសមចិតនៅផ្ទះរបស់គេ ។ ដូចនេះគេមានសិទ្ធិគ្រប់គ្រាន់ជា សំអាងថា «សមជាអ្នកសាបព្រោះអំពើអបលក្សណ៍ » ធ្វើអោយប៉ះពាល់ដល់ជីវិតនិង កិត្តិយស គេដោយចេតនាពុំអាចប្រកែកបាននៅលើគេហដ្ឋានខ្លួន ។

ទាក់ទិនទៅនឹងសមដែលជា តួអង្គក្នុងរឿងព្រះអាទិត្យថ្មី រះលើផែនដីចាស់ ។ លោក សួន សុរិន្ទ បានធ្វើអោយជីវិតក្នុងក្តីស្រមៃតួអង្គ នេះក្លាយជាការពិត ។ គឺមានន័យថា លោកបានធ្វើអោយសមផ្លាស់ជីវិតពីភាពគោកយ៉ាក តែលគោលគ្មានបង្អែក គ្មានជំរក គ្មានកិត្តិយស មកជាប្រជារាស្ត្រម្នាក់ដែលមានគឺរតជីវភាពថ្កុំថ្កើងរុងរឿង មានមុខមាត់ខ្ពស់ត្រដែតមានតួនាទី

www.buddhist.gov.kh www.elibraryofcambodia.org

ខ្ពង់ខ្ពស់និង ជាតំនាង ប្រកបដោយឋាមពលគួរអោយគោរពកោតសរសើរ ។ បំលាស់ប្តូរសភាពបែបនេះ គឺ អ្នកនិពន្ធចង់ស្តែងអោយដឹងថាមកពីសមជាមនុស្សដែលយល់បានទូលំទូលាយ នូវកាលៈទេសៈនៃប្រទេសនិងទីតាំងដែលខ្លួនសំរេច ចិត្តជ្រើសរើសយក ។ ជាសក្តីភាពគឺ សម មើលឃើញថា ចលនាសង្គមរាស្ត្រនិយម ក្រោមព្រះរាជកិច្ច ដីកនាំរបស់អង្គសម្តេចឪព្រះអង្គបានបាញ់មុខព្រួញឆ្ពោះទៅរកការអភិវឌ្ឍន៍ជនបទ តាមរយៈការពង្រីកប្រព័ន្ធធារាសាស្ត្រសំរាប់ធ្វើស្រែចំការ កសាងមន្ទីរ ពេទ្យ សាលារៀន ថ្នល់ ជួនដល់កូនចៅកសិករ ។ ពេលនោះសមសំរេចចិត្ត ចាកចេញពីផ្ទះលោករដ្ឋមន្ត្រីក្មេងចេញពីទីក្រុងមករស់នៅស្រុកកំនើតខ្លួនឯស្រែ ចំការដោយពុំ អួសបន្លាយពេលវេលាបណ្តោយខ្សែជីវិតអោយរស់នៅទីក្រុងតទៅទៀតនោះឯង ។

មិនខុសពីរឿងដូចដែលយើងបានរៀបរាប់ខាងលើឡើយ ។អ្នកនិពន្ធរឿងថៅកែចិត្តចោរក៏បានពន្លេច នូវតួអង្គថៅកែចិត្តចោរដើម្បីអោយយើងឃើញ ថា គេជាជនដែលយល់ពីពេលវេលាដែលត្រូវទាញផលនិងស្គាល់ពីទីតាំងដែល អោយគេអាចសំរេចបាននូវភ័ព្វវាសនាល្អតាមបំនងគេ ។ និយាយអោយចំទៅ នោះគឺមុននឹងប្រើពូហាំអោយផ្តាញ់ថៅកែហុង លី ដែលមានមុខរបរដូចខ្លួនអោយ ដួលបះជើងនោះ វាត្រូវនឹងពេលដែលកូនស្រីពូហាំត្រូវចូលរៀន ប្រពន្ធពូហាំ ឈឺ ម្តាយពូហាំចង់បានប្រាក់ធ្វើបុណ្យ ។ បញ្ហាទាំងបីនេះតំរូវអោយពូហាំត្រូវតែយល់ព្រម បើកឡានបុកឡាន ថៅកែហុង លី ដើម្បីបានប្រាក់អោយកូនបន្ត ការសិក្សានៅ អនុវិទ្យាល័យ បានប្រាក់ទៅព្យាបាលប្រពន្ធ និង បានប្រាក់ជូនម្តាយបំពេញកុសល ផលបុណ្យទៅអនាគត ។ ដូចនេះថៅកែ ចិត្តចោរសង្ឃឹមថា ពូហាំពិតជាដឹងធ្វើ តាមបញ្ជាខ្លួន នោះបីដឹងថាទង្វើរបស់គេពោរពេញទៅដោយគ្រោះថ្នាក់ និង ល្មើសច្បាប់ក្តី ។ ករណីមួយ

www.budinst.gov.kh www.elibraryofcambodia.org

ទៀតនៅពេលប្រកែកតឹងមាត់ នឹងពូហំ ថៅកែ ចិត្តចោរ បានកំនត់ការឈ្លោះទាស់ទែងគ្នាលើផ្ទះខ្លួន ។ មូលដ្ឋាននេះដែលនាំអោយថៅកែអាចទ្រទ្រង់ខ្លួនផុតពីគ្រោះថ្នាក់គួបផ្សំនឹងគេប្រើលុយជាអាវុធកាត់ផ្តាច់យុត្តិធម៌ អោយរលេះរលួយដាច់ពីសង្គមមនុស្ស ។

៣-<u>សរុបការពន្យល់</u>

រួមសេចក្តីមកយោលទៅលើភស្តុតាងដែលយើងបានទាញយកបញ្ជាក់ពីក្នុងសង្គមមនុស្ស និងពីក្នុងអក្សរសិល្ប៍ថ្នាក់ទី ១២ បានគួសបញ្ជាក់អោយឃើញថា អ្នកដែលស្គាល់បានច្បាស់ពីកាលៈទេសៈ ដែលហុចអោយនិងស្គាល់ពីស្ថានភាព ទីកន្លែងដែលខ្លួនត្រូវធ្វើ ។ អ្នកនោះរមែងតែងតែទទួលបានន័យភាពឈ្នះលើមុខ របរ សំរេចន័យបំណងដែលខ្លួនចង់បានទំលាយបានន័យរបញ្ជាស្មុគស្មាញ ដែលកើត មានចំពោះមុខឆ្លើយតបទៅនឹងសំនួនវោហារសំព្ធដែលប្រធានខាងលើបានលើក ឡើងពិតមែន ។

III-<u>យោបល់បញ្ចប់</u>

ដោយផ្អែកទៅលើការបកស្រាយយ៉ាងល្អិតល្អន់រួចមកហើយយើងអាចធ្វើការវាយតំលៃបានថា ទស្សនៈប្រធាននេះជាទស្សនៈប្រកបដោយអត្ថន័យអប់រំ ដ៏ជ្រាលជ្រៅក្រៃលែង ។ ប៉ុន្តែប្រសិនបើមនុស្សយើងធ្វើអ្វីៗមួយប្រើតែធ្វើការ សង្កេតលើកាលៈទេសៈ និងទីតាំង វានឹងអាចអោយមានការថ្លោះថ្លោយដោយ អន្លើខ្លះៗជាក់ជាពុំខាន ។ ដូចនេះមនុស្សចាំបាច់ត្រូវពឹងផ្អែកលើប្រាជ្ញា សមត្ថភាព ថាមភាពដឹកនាំនិងគ្រប់គ្រងបន្ថែមទៀតទើបភាពឈ្នះនឹងឋិតនៅក្នុងរវាងដៃ យើងយូរអង្វែងតរៀងរហូតទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រធានទី៣ : «គ្រប់ជាតិសាសន៍សុទ្ធតែមានជំនឿផ្សេងៗពីគ្នា » ។ តើជំនឿមាន ឥទ្ធិពលដូចម្តេចខ្លះចំពោះជីវិតមនុស្ស ? ។ ចូរបង្ហាញដោយភ្ជាប់ឧទាហរណ៍ ពីក្នុងអក្សរសិល្ប៍ ថ្នាក់ទី១២ ដែលអ្នកបានសិក្សារួច ។

គំរោងតែង

១- ពន្យល់ពាក្យ

ជំនឿ = ការជឿ គិតទាំងការជឿខុស និងការជឿត្រូវ

ឥទ្ធិពល = កំលាំងគ្របដណ្តប់ដែលអាចបង្កើតនូវអ្វីផ្សេងៗបាន

២- បកស្រាយ

ជំនឿមានឥទ្ធិពលចំពោះជីវិតមនុស្សដូចតទៅ ÷

ក- ជាកំលាំងធ្វើអោយមនុស្សមានសេចក្តីក្លាហានឥស្ប៉ិចំពោះឧបសគ្គ អោយមនុស្សព្យាយាម ញ៉ាំងកិច្ចការត្រូវធ្វើសំរេចដូចបំនង

- កសិករ ខំទ្រាំក្តៅ រងា ភ្លៀង ⇒ ខាង មុខបានផល
- ព្រះសង្ឃលះទ្រព្យទៅបួស ⇒ ផលនៅអនាគតជាតិ

ឧទាហរណ៍ : ពីរឿងតូមិតរឃ្លាន

- នៅ, ជួន, នាងនី, នាងប៊ី, រួមអ្នកស្រុកក្រាំងលាវ រួមគ្នាកំចាត់បារាំង ⇒ ជឿលើសមត្ថភាពពួកគេអាចដណ្តើមសិទ្ធិសេរីភាព សេចក្តីសុខពីបារាំងបាន ⇒ តស៊ូឡើងមិនតក់ស្លុតនឹង - ទារុណកម្ម ។

ខ- ជំនឿផ្តល់អោយកើតទ្រព្យជំរុញសេរីដល់មនុស្ស

- សិស្សជឿលើវិជ្ជាព្យាយាមរៀន ⇒ ចេះដឹង
- ពាណិជ្ជករជឿអាជីវកម្មខ្លួនខំរកតទៀត ⇒ អ្នកមានស្តុកស្តម្ភ

www.budinst.gov.kh www.elibraryofcambodia.org

ឧទាហរណ៍ ពីរឿងព្រះអាទិត្យថ្កើរលើផែនដីចាស់

- សមជឿលើនយោបាយទឹក នយោបាយអភិវឌ្ឍន៍ជនបទរបស់សម្តេចឪ ខំធ្វើការ ⇒ ជីវិតរុងរឿង

គ- <u>ជំនឿជាពួជ នៃសេចក្តីទុក្ខនិង សុខរបស់មនុស្ស</u>

- ជឿសិប៉ស័តពិចារណា ⇒ វិនាសន្ធូរប្រយោជន៍

- ជឿយកការជឿទាញយកផល ⇒ ចំរើនរុងរឿង

ឧទាហរណ៍ : រឿងគូលីកំឡេះ

- តាង៉ែក, យាយម៉ុក , ជឿផ្តាប់មុខ ⇒ ស្លាប់ , កូនចៅពុំបានឃើញមុខពុំបានធ្វើបុណ្យសមរម្យ ។

- ឧកាសក ខើចជើង ត្រូប៉ក់ លីម ជឿលើព្រះពុទ្ធសាសនាយកទ្រីស្តី មកប្រើប្រាស់សមស្រប⇒ បានសុភមង្គល ឈ្មោះជាអ្នកស្នេហាជាតិនាពិតៗ ។ គេបានសុខសាន្ត ផុតពីការធ្វើបាបរបស់ពួកប្រតិកិរិយា ។

ឃ- <u>ជំនឿធ្វើអោយមនុស្សកើតចិត្តសប្បុរសនិងកតញ្ញូ</u>

- ជឿធ្វើបុណ្យបានបុណ្យ តបគុណម៉ែឪបានបុណ្យ ⇒ ព្រមចំនាយអស់កំលាំងកាយ ប្រាជ្ញា ទ្រព្យជួយអ្នកដទៃ តបគុណមាតាបិតា

ឧទាហរណ៍ : រឿង ព្រះអាទិត្យថ្កើ + ថៅកែចិត្តចោរ

- យាយប៉េងយាយប៉ោះជួយប្រពន្ធសំ ⇒ ជឿលើអំពើល្អរបស់គាត់នឹងបានផលល្អ ។

- ជឿលើគុណម្តាយ ⇒ ហ៊ានបរឡានបុកគេដើម្បីបានប្រាក់ជួនម្តាយធ្វើបុណ្យតបគុណ ។

ង- <u>ជំនឿជាទំនប់ទប់ចិត្តមនុស្សកុំអោយមនុស្សឃ្លាតចាកពីឧត្តមគតិខ្លួន</u>

www.budinst.gov.kh www.elibraryofcambodia.org

- ប្រុងធ្វើខុស ⇒ ដកខ្លួនថយ
- គិតថាធ្វើត្រូវ ⇒ គាំទ្រអ្នកដែលល្អ - ប្រកាន់ផ្លូវល្អ

ឧទាហរណ៍ : ស្បែង ព្រះអាទិត្យថ្មី + ថៅកែចិត្តចោរ

- សមធក់ប្រាក់គេ រួចយកអោយគេវិញ ⇒ ជឿអ្វីដែលខ្លួនធ្វើនឹងនាំអោយខ្លួនមានតំលៃ

- ម៉េង ទ្រី គង់ គាំទ្រ ពួហាំ ⇒ ជឿថាទង្វើគេនឹងធ្វើអោយសង្គមមានយុត្តិធម៌+កាច់បំបាក់បានថៅកែចិត្តខ្មៅបួស្បា រកសុភមង្គលដល់កម្មករទូទៅ។

I-សេចក្តីផ្តើម

លើលោកយើងនេះ មានសាសនាជាច្រើនដែលមនុស្សតែងនាំគ្នាគោរពរួមមានសាសនាមហាម៉ាត់ យេស៊ូ សាសនា តៅ ពុទ្ធសាសនា ព្រហ្មញ្ញសាសនា ។ ជនជាតិខ្លះនាំគ្នាគោរពសត្វធម្មជាតិ។ ប្រការដែលគេនាំគ្នាគោរពបែបនេះ ដោយគេមានជំនឿថា សាសនាទាំងអស់នោះផ្តល់នូវផលប្រយោជន៍ដ៏ប្រសើរចំពោះរូបគេ ។ តើជំនឿវាមានឥទ្ធិពលដូចម្តេចខ្លះចំពោះជីវិតមនុស្ស ? ចុះក្នុងអក្សរសិល្ប៍ខ្មែរថ្នាក់ទី ១២ បានបង្ហាញពីទំនាក់ទំនងនៃជំនឿជុំវិញជីវភាពមនុស្ស យើងបែបណាខ្លះ ?

II-ត្រួសេចក្តី

១- ពន្យល់ពាក្យ

ពាក្យថា « ជំនឿ » ក្នុងប្រធានេះចង់សំដៅទៅលើការជឿខុស

www.budinst.gov.kh www.elibraryofcambodia.org

នឹងការជឿត្រូវ ។ ទោះបីជាការជឿបែបណាក៏ដោយ« សុទ្ធមានឥទ្ធិពលចំពោះជីវិតមនុស្សទាំងអស់ » ។ នោះគឺបានសេចក្តីថា ការជឿជាកំលាំងដ៏ខ្លាំងក្លាគ្របដណ្តប់លើស្មារតីចិត្តគំនិត ការរស់នៅរបស់មនុស្សអោយទទួលបានន្ទូវផលអ្វីមួយទៅតាមទំហំនៃការជឿរបស់ខ្លួនគេម្នាក់ ។ ។

២- <u>បកស្រាយ</u>

ឈរលើការនិទស្សន៍ ទាក់ទងទៅនឹងស្មារតីមនុស្សបានស្តែងអោយយើងឃើញយ៉ាងច្បាស់ថា « ជំនឿជាកំលាំងធ្វើអោយមនុស្សមានសេចក្តីក្លាហានពុះពារចំពោះឧបសគ្គ អោយមនុស្សមានចិត្តព្យាយាមធ្វើអោយកិច្ចការដែលខ្លួន បំពេញ សំរេចន្ទូវបំនង » ។ ករណីដូចជាកសិករដែលខិតខំបំពេញការងារក្រោមថ្ងៃក្តៅ ភ្លឿងខ្យល់ត្រជាក់ញាក់ញ័រណ្តំធ្មេញ មិនហ៊ានឈប់បង្អង់ដៃ ។ នេះមកពីគេជឿជាក់ក្នុងចិត្តថា « នៅពេលវេលាណាមួយនោះគេនឹងទទួលបានផលជាផ្កាផ្លែ » ពីទង្វើដែលគេបានធ្វើ ។ ម្យ៉ាងទៀតមនុស្សខ្លះបានផ្លាស់ភេទជាត្រហស្ថ ចូលខ្លួនសាងផ្នួសជាព្រះសង្ឃ ដោយតាំងចិត្តលះបង់ន្ទូវ កិលេស មិនស្តាយទ្រព្យ សម្បត្តិ សុខចិត្តរស់នៅក្នុងវត្តអារាមដ៏ស្ងាត់ជ្រងំ ក៏មកពីគេមានជំនឿលើ គុណព្រះរតនត្រ័យជាកំលាំងញ្ជឹងចិត្តគេអោយជ្រះថ្លាញ៉ឹងជីវិតរបស់គេដល់ទៅ ទីដ៏សែនមនោរម្យ ។

ក្រឡេកទៅមើលក្នុងរឿងភូមិតិរច្ឆាន នៅជួនឆាងនី ឆាងបី ដែលហ៊ានចេញមុខធ្វើជា« មេខ្យល់» បំផុសប្រជារាស្ត្រ ភូមិក្រាំងលាវទាំងមូលកំចាត់បាជេស មកពីពួកគេទាំង នោះមានជំនឿថា «ពួកគេពិតជានិងអាចធ្វើអោយបារាំងរត់ផាស ក្រញាំ ដកខ្លួនចេញពីទឹកដីខ្លួនយ៉ាងពិតប្រាកដ » ។ ដូចដែលគេបានទស្សទាយ ទុកលើសកម្មភាពរបស់ពួកគេមែន ទោះបីបាជេសមានកងការពារប្រដាប់ដោយអាវុធគ្រប់ដៃក៏ពួកនោះពុំអាចធ្វើជារបាំងការពារ-

www.budinst.gov.kh www.elibraryofcambodia.org

បាដេសផុតពីផ្តន្ទាទោសរបស់ ក្រុមចលនាប្រឆាំងនៅ ជូន នាងនី នាង ប៊ី បានឡើយ ។

ម្យ៉ាងវិញទៀត «ជំនឿផ្តល់នូវទ្រព្យដ៏ប្រសើរដល់មនុស្ស »។ យ៉ាងណាមិញ សិស្សមួយភាគធំ ដែលតែងតែ ស្រវាស្រទេញ សិក្សាឥតមានខ្ចិលច្រអូស ខំរៀនទាំងថ្ងៃទាំងយប់ ។ពាណិជ្ជករខំរកស៊ីឥតឈប់ឈរមិនទំនេរដែ។ មូលហេតុដែលគេប្រកាន់ជំហរបែបនេះព្រោះគេមើលឃើញ នឹងជឿថា ទ្រព្យសម្បត្តិនឹងមានដល់រូបគេ នៅពេលណាដែលគេមានសមត្ថភាពខ្ពង់ខ្ពស់នៅពេលគេចាស់ជរាទៅនោះ ។

ស្របគ្នានេះដែរ សមដែលជាតួអង្គឯកក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ គេមានការជឿជាក់យ៉ាងមុតមាំ លើនយោបាយអភិវឌ្ឍន៍ជនបទរបស់អង្គ សម្តេចឪជាព្រះបិតាកសិកម្មជាតិ ដែលព្រះអង្គយកព្រះទ័យទុកដាក់ធ្វើនយោបាយទឹក កសាង គមនាគមន៍ សាលារៀន មន្ទីរពេទ្យ សំរាប់កសិករខ្មែរគ្រប់រូប។ ជំនឿនេះញុំងអោយសមឈប់រស់នៅទីក្រុងចូលរួមយ៉ាងសកម្មក្នុងចលនាសង្គម រាស្ត្រនិយមនៅស្រុក កំនើតខ្លួន ។ចុងបំផុតសមទៅជារាស្ត្រមានជីវភាពសំបូរសប្បាយ មានសព្វមានគ្រប់ មិនក្រីក្រដូចពេលមុនៗទៀតសោះឡើយ ។ ចំនុចនេះ ហើយដែលថា ជំនឿធ្វើអោយកើតទ្រព្យនោះ ។

ក្រៅពីទ្រព្យជំនឿក៏ជាពួជនៃសេចក្តីសុខនិងទុក្ខរបស់មនុស្សផងដែរ ។ គឺមានន័យថា បើបុគ្គលម្នាក់ដែលយល់ថា អំពើដែលខ្លួនធ្វើមិនប៉ះពាល់ដល់អ្នក ដទៃមិនធ្វើអោយអ្នកដទៃរងគ្រោះដោយសារខ្លួនគ្រានោះ ហើយដែលផលសុខ ចំរើននឹងកើតមានដល់បុគ្គលនោះពុំលែងឡើយ ។ ទន្ទឹមនឹងនេះជំនឿអាចប្រជួច បានទៅនឹងថ្នាំ ដែលមាន ជាតិពុលធ្វើអោយមនុស្សជួបនូវការចុកចាប់ពេញផ្សា គ្មានលោះថ្ងៃណាមួយឡើយ ។ ផលវិបាកនេះ

www.budinst.gov.kh www.elibraryofcambodia.org

កើតពីជំនឿ ខុសឆ្គងនោះឯង ។

ដើម្បីជាការបញ្ជាក់លើចំនុចនេះយើងឃើញអ្នកនិពន្ធរឿងគួលីកំណែនបានលើកឡើងពីបុគ្គលពីរក្រុមដែលទទួលផលផ្សេងគ្នាជុំវិញជំនឿដូចគ្នា។អ្នកនោះគឺតា ង៉ែត យាយម៉ុក ជំនឿជាពូជនៃទុក្ខរបស់គាត់ ។ ដោយតាត់គ្រូវស្លាប់ ក្រោមទឹងន់នៃគ្រាប់បែកចក្រពត្តិ ស្របទៅនឹងការ ជឿរបស់គាត់ថា «ខ្មែរឆងទុក្ខ ដោយមានកម្មពៀរវេរាអន្ទោលតាមខ្លួនកន្លងមក »។ ចំនែកខាងគ្រូសូត្រ ម៉ក់ឧបាសក ខើចជើង ពួកគេជឿថា «ទុក្ខខ្មែរពុំមែនមកកម្មពៀរទេ តីមកពីគំនាបសង្គម និងការត្រួតត្រារបស់បរទេស » ។ ក្រោយពីឈ្វេងយល់ឃើញដូចនេះ គេបានបង្វែរគំនិតចូលរួម កំលាំងជាមួយអ្នកស្នេហាជាតិខ្មែរវាយបណ្តេញពួក បរទេសចេញពីទឹកដីខ្លួន ។ ពូជសុខក៏បានធ្លាក់ដល់ដៃពួកគេដូចចិត្តដែលគេប៉ងប្រាថ្នាកន្លងមក ។

ឥទ្ធិពលមួយបែបទៀតនៃជំនឿនោះ «គឺ វាជាវត្ថុជំរុញអោយមនុស្សកើតឡើងក្នុងខ្លួននូវចិត្តសប្បុរស់ចិត្តកតញ្ញូ » ដូចដែលយើងបានឃើញមនុស្សភាគច្រើនណាស់សុខចិត្តចំនាយធនធាន ជីវិតផ្គាល់ខ្លួន កសាងនូវសមិទ្ធិនានាបំរើផលប្រយោជន៍មនុស្សទៅឥតស្តាយស្រនោះ ។ នេះក៏ព្រោះតែគេជឿថាការបរិច្ចាគរបស់គេ នឹងនាំជីវិត ខ្លួនទៅកាន់សុគតិភាពនាពេលណាដែលគេលាចាកលោកនេះទៅ ។ រីឯកូនចៅដែលខិតខំ ប្រណិបតន៍តបស្នងគុណមាតាបិតាជារឿយៗ ។ ដោយមកពីគេមានជំនឿថា គេនឹងទទួលបាននូវសុភមង្គលនិងភាពចំរុងចំរើនពី កតញ្ញូធម្មិខ្លួនចំពោះមាតាបិតា ។

ភ្ជាប់នឹងន័យនេះយើង សង្កេតឃើញជាក់ស្តែងពីករណីយាយប៉ែង និងយាយប៉ោះក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ។ ដូចចាស់ទាំងពីរបូចាត់ទុកថាមនុស្សសប្បុរស ។ តោរមងារនេះមានប្រភពចេញពីជំនឿនៃការ

www.buddhistgov.kh www.elibraryofcambodia.org

ជួយជ្រោម ជ្រែងអស់ពីសមត្ថភាព របស់គាត់សង្គ្រោះប្រពន្ធសមពេលឆ្លងទន្លេ ។ ព្រមជាមួយគ្នានេះដែរ ពួហាំ ក្នុងរឿងចៅកែចិត្តចោរ ដែលបានប្រថុយជីវិត មិនខ្លាចមាន ទោសចំពោះមុខច្បាប់ ក៏កើតពីប្រភពនៃជំនឿនេះដែរ ។ ពោលគឺគាត់សង្ឃឹមក្នុងខ្លួនថា បើសិនជាបានប្រាក់ពីចៅកែចិត្តចោរ ១ ម៉ឺនរៀលមកកូនគាត់ប្រាកដជា មានអនាគត ប្រពន្ធគាត់ពិតជានឹងសះស្បើយពីជំងឺ ។ ពិសេសម្តាយរបស់នឹងគាត់ បានធ្វើបុណ្យទានតាមប្រពៃណីជាតិ ។ នាពេលនោះហើយដែលគាត់នឹងទទួល នាទីជាឪពុកប្រកបដោយព្រហ្មវិហារធម៌ជាសុស្វាមីនិង ជាកូនកតញ្ញូនោះ ។

ចុងក្រោយនេះយើងឃើញថា «ជំនឿជាទំនប់ទប់ចិត្តមនុស្សកុំអោយមនុស្សឃ្លាតចាកពីឧត្តមគតិខ្លួន»។ ត្រង់នេះចង់បង្ហាញថាការជឿរបស់មនុស្សលើអ្វីមួយដែលខ្លួនបានគិតទុក វានឹងប្រមុំ ចិត្តមនុស្សមិនអោយក្បត់នូវគំនិតខ្ពង់ខ្ពស់ខ្លួនជាដាច់ខាតជាសក្តីភាព លើន័យនេះគឺ តួអង្គសមតែម្តង បន្ទាប់ពីបានឆក់កាបូបមាសប្រាក់របស់ប្រពន្ធចៅកែសំបូរសម្បត្តិរួចមក គេនៅពុំសុខឡើយ ។ គេយល់ថា អំពើខ្លួនជាបាបកម្មធ្ងន់ណាស់ ដែលធ្វើអោយម្ចាស់ទ្រព្យកើតទុក្ខវឹងវៃ ស្តាយទ្រព្យដែលខ្លួនបាត់បង់ ។ ជំនឿនេះបានជំរុញអោយសមយកទ្រព្យដែលខ្លួន ឆក់បានទៅប្រគល់អោយម្ចាស់គេវិញ ទោះបីខ្លួនត្រូវទទួលរងនូវទារុណកម្មឬ ទណ្ឌកម្មបែបណាក្តី ។ ដោយឡែកតង់ ទ្រី មានដែលជាកម្មករួមអាជីពរបស់ពួហាំ ព្រោះតែគេមានជំនឿទៅលើសច្ចធម៌ យុត្តិធម៌តំរូវអោយគេបង់សេធលុយ ស្លូក ប៉ាន់ ចិត្តដ៏ខ្មៅក្រខ្វក់ដែលចៅកែទិញចិត្តខ្លួនអោយឆ្លើយថា «គេពុំបានជាប់ទាក់ ទងទៅនឹងការប្រើអោយពួហាំលើកឡានទៅបុកឡានចៅកែហុងលី ឡើយ» ។ពួកគេសុខចិត្តបាត់អាជីពដោយនៅតែតាំទ្រខាងពួហាំជានិច្ច ។ សេចក្តីដែលបាន លើកឡើងប៉ុណ្ណោះបញ្ជាក់ថា

www.budinst.gov.kh www.elibraryofcambodia.org

ជំនឿធ្វើអោយមនុស្សមិនអាចក្បត់ខុត្តមគតិខ្លួននោះ ។

៣- <u>សរុបការពន្យល់</u>

សរុបសេចក្តីមក យើងអាចឆ្លើយបានថា ជំនឿជាវត្ថុជំរុញអោយមនុស្សក្លាហាន អត់ធ្មត់នឹងការងារ- ធ្វើអោយមនុស្សកើតក្រឡុក កើតក្តីសុខផងទុក្ខផង អោយកើតនូវចិត្តកតញ្ញូនិងសប្បុរសនិងជាគ្រឿងទប់ចិត្តមនុស្សកុំអោយប្រាសចាក ចិត្តពីខុត្តមគតិខ្លួន ។ ដោយសារតែយ៉ាងនេះ ហើយបានជាគ្រប់ជាតិសាសន៍ក្នុងលោកពុំអាចផ្តាច់ខ្លួនពីជំនឿផ្សេងៗបាននោះ ។

III-<u>យោបល់បញ្ចប់</u>

ឆ្លងតាមការបកស្រាយខាងលើ យើងឃើញថាជំនឿពិតជាវត្ថុពុំអាចខ្វះ បានក្នុងជីវិតមនុស្សម្នាក់ៗ ឡើយ ។ ពីព្រោះដរាបណាមានជំនឿវានឹងអោយមនុស្សទំលាយបានរាល់ការលំបាក វាផ្សាំងចិត្តមនុស្សអោយបែរមុខឆ្ពោះទៅរកមាគ៌ាដ៏ប្រពៃវ ដែលមនុស្សទូទៅចង់បាន ។តែមនុស្សក៏គួរតែចៀសវាងដែរនូវជំនឿណាដែលអន់ថយ ស្មោក គ្រោក មិនទាន់សម័យ ។ នោះទើបយើងអាចរក្សាតំលៃនៃជីវិតអោយខ្ពស់ត្រដែតតរៀងរហូតទៅ ។

ជឿខុសនាំខ្លួនធ្លាក់អន្លង់ ទុក្ខតព្វជពន្យល់សន្តាន
ជឿត្រូវនាំខ្លួនបានសុខសាន្ត ឈ្លោះផ្តើមជាតិផ្តាន់តរឿងទៅ។

ម៉ិញ - លីថាន
សាស្ត្រាចារ្យអក្សរសាស្ត្រវិទ្យាល័យបឹងត្របែក

www.budinst.gov.kh www.elibraryofcambodia.org

ឃ្លាឧទាហរណ៍ ៖ទស្សនៈបួនលើកឡើងថា « មន្ត្រីបុគ្គលិករដ្ឋដែលពុំបានបំពេញករណីយកិច្ចវិជ្ជាជីវៈទៀងទាត់ ចាត់ទុកថា ជាអ្នកប្រព្រឹត្តបាបកម្មយ៉ាងធ្ងន់ធ្ងរចំពោះសង្គមជាតិ » ។ ចូរអ្នកបង្ហាញដោយលើកឧទាហរណ៍ពីក្នុងរឿងគូលីកំនែន និងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ។

គំរោងតែង

១- ពន្យល់ពាក្យ

ករណីយកិច្ចវិជ្ជាជីវៈ = កិច្ចដែលគួរធ្វើចំពោះការងារទាក់ទងមុខរបរជំនាញផ្សេងៗ ។

បាបកម្ម = អំពើអាក្រក់ អំពើមិនត្រឹមត្រូវមន្ត្រីបុគ្គលិករដ្ឋពុំបានធ្វើការងារត្រឹមត្រូវទាក់ទង់នឹងមុខរបរជំនាញខ្លួន ចាត់ទុកជាអ្នកដែលបានធ្វើនូវអំពើអាក្រក់ដល់ជាតិនិងប្រទេសខ្លួន ។

២- បកស្រាយ

អាជ្ញាធរគ្រប់ជាន់ថ្នាក់ = ពុំយកចិត្តទុកដាក់ដោះស្រាយបញ្ហារាស្ត្រពុំអើពើធ្វើអោយវិស័យនានាមានចំណែន សាបព្រោះអំពើពុករលួយ⟹ ក្បត់ប្រយោជន៍ ជាតិធ្វើអោយជាតិលិចលង់ ។

នាយទាហាន គឺបកេងបៀវត្សពលទាហាន មិនធ្វើជាគំរូល្អដល់ថ្នាក់ក្រោម ប្រើឥទ្ធិពលរំលោភលើរាស្ត្រ ⟹ ទាញជាតិធ្លាក់ក្នុងហាយនភាព

*** បកស្រាយពីអក្សរសិល្ប៍**

- ករណីកិច្ចវិជ្ជាជីវៈដែលមន្ត្រីបុគ្គលិក ត្រូវបំពេញចំពោះសង្គមជាតិរួមមាន÷ ស្រលាញ់ការងារ, ប្រើសមត្ថភាពដែលមានបំពិជាតិ, ធ្វើការអោយម៉ត់ ចត់, អ្វីៗទាំងអស់គឺមិប្រយោជន៍ពលរដ្ឋខ្លួន ។

www.budinst.gov.kh www.elibraryofcambodia.org

ក- មន្ត្រីរាជការដែលពុំបានបំពេញករណីយកិច្ចវិជ្ជាជីវៈក្នុងរឿង គ្វូលីកំនែន

- មេឃុំជាន់ = សង្កត់ករាស្ត្រ កេងលើរាស្ត្រពេលប្រមូលធ្វើកំនែន គំរាមកំហែងរាស្ត្រផ្តាច់ថ្នាក់លើ ។

- ចៅហ្វាយស្រុក ប្រើអំណាចសាបព្រោះអំពើពាលាបើកឱកាសអោយពួកអាណានិគមជ្រក់ជ្រៃធ្វើបាបរាស្ត្រពុំរីរវល់ទុក្ខវេទនារាស្ត្រ កើបមាស ប្រាក់ ដើម្បីមានប្រាក់ ប្រើពាក្យអសុរសគ្មានសីលធម៌ក្នុងខ្លួន ។

* **បាបកម្មធ្ងន់ធ្ងរសន្ធមជាតិ**

- រាស្ត្រទុរភិក្ស ស្លាប់, បែកបាក់គ្រួសារ

- ជីវភាព ដុនដាប, ជាតិបាត់បង់អធិបតេយ្យភាព

ខ- មន្ត្រីរាជការដែលពុំបានបំពេញករណីយកិច្ចវិជ្ជាជីវៈក្នុងរឿង ព្រះអាទិត្យ ថ្មីរះលើផែនដីចាស់

- ពេទ្យនរា មិនមើលជំងឺជនក្រីក្រគ្មានលុយប្រើពាក្យដៀលត្មះលើជីវិតរាស្ត្រក្រីក្រ

- ភ្នាក់ងារប៉ូលីស រំលោភលើសិទ្ធិរាស្ត្រ ចាប់ចង់ដាក់គុករាស្ត្រគ្មានរកហេតុផលបង្កភាពអយុត្តិធម៌ ។

- មេការត្រួតត្រាគុក ស៊ីសំនួក- ប្រព្រឹត្តលំអៀងច្បាប់

- លោកយ៉ែង មិនបានជួយស្រាយទុក្ខរាស្ត្រ សំលុតបំភ័យរាស្ត្រ រមិលគុណរាស្ត្រ ។

www.budinst.gov.kh www.elibraryofcambodia.org

ផលចក្ខុកធម្មរង្សី

I-សេចក្តីផ្តើម

ក្នុងលោកនេះមិនថាប្រទេសតូចឬប្រទេសធំនោះទេ តែងតែកើតមានវិបត្តិសុគស្មាញចំពោះបញ្ហាក្នុងសង្គមខ្លួនជានិច្ច។វិបត្តិនេះមួយផ្នែកកើតពីបុគ្គលមួយចំនួនដែលចិតក្នុងជួរអ្នកដែលមានតួនាទីបំរើកិច្ចការងាររដ្ឋនីមួយៗនោះឯង ។ ហេតុនេះហើយទើបមានទស្សនៈមួយលើកឡើងថា។«មន្ត្រីបុគ្គលិករដ្ឋដែលពុំបានបំពេញករណីយកិច្ចវិជ្ជាជីវៈទៀងទាត់ចាត់ទុក ជាអ្នកប្រព្រឹត្តបាបកម្មយ៉ាងធ្ងន់ធ្ងរចំពោះសង្គមជាតិ» ។ តើទស្សនៈនេះបង្កប់នូវខ្លឹមសារដូចម្តេចខ្លះ? ក្នុងរឿងគួលីកំនែន និងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ មន្ត្រីបុគ្គលិករដ្ឋណាខ្លះដែលបាន ប្រព្រឹត្ត អំពើស្របតាមទស្សនៈប្រធាននេះ ?

II-តួសេចក្តី

១- ពន្យល់ពាក្យ

នាយជាមនុស្សគួរតែធ្វើការងារផ្សេងៗទៅតាមចំនេះដែលខ្លួនចេះចាំ និងបានរៀនសូត្រកន្លងមក ដើម្បីចិញ្ចឹមខ្លួនឯង ផងរួមចំនែកអភិវឌ្ឍន៍ជាតិផង។ សកម្មភាពនេះត្រូវនឹងន័យរបស់ពាក្យថា« បំពេញករណីយកិច្ចវិជ្ជាជីវៈ » ដោយឡែកពាក្យ « បាបកម្ម » សំដៅលើអំពើអាក្រក់ ឬអំពើមិនត្រឹមត្រូវ ។ ឈរលើអត្ថន័យនៃពាក្យទាំងនេះយើងអាចកំនត់បានពីការយល់ឃើញនៃម្ចាស់ទស្សនៈប្រធានថា មន្ត្រីបុគ្គលិករដ្ឋអំណាចពុំព្រមបំពេញភារៈការងារដែលខ្លួនគួរធ្វើដោយការងារនោះទាក់ទងទៅនឹងមុខជំនាញឬ បុខរបខ្លួនចេះអោយបានសព្វគ្រប់ ល្អិតល្អន់ទេនោះមានឈ្មោះថាជាអ្នកបានធ្វើនូវអំពើអាក្រក់ដ៏ធំធេង

www.budnet.gov.kh www.elibraryofcambodia.org

ចំពោះរាស្ត្រនិងប្រទេសរបស់ខ្លួន ។

២- <u>បកស្រាយ</u>

ធម្មតាជាតិ នីមួយៗរមែងតែងតែមានមនុស្សសំរាប់ធ្វើការងារចាត់ចែងកិច្ចការទូទៅនិងមានមនុស្សសំរាប់បំរើការងារនានា ។ អ្នកទាំងនោះទទួលប្រាក់បៀវត្សពីរដ្ឋដែលយើងនិយមហៅថា«មន្ត្រីបុគ្គលិករដ្ឋ»។ បើយើងនិយាយពីអាជ្ញាធរគ្រប់ជាន់ថ្នាក់ ដែលអាចសន្មត់ថា ពុំបានបំពេញករណីយកិច្ចវិជ្ជជីវៈនោះអាស្រ័យដោយសារពួកគេ ពុំបានយកចិត្តទុកដាក់ធ្វើការងារដែលរដ្ឋប្រគល់អោយទេ គេបែរជាយកមុខតំណែងរបស់ខ្លួន ទៅប្រព្រឹត្តន្ទួរអំពើខុសច្បាប់រំលោភបំពានលើសិទ្ធិសេរីភាពរាស្ត្រ ។ គេមិនរវីរវល់ដោះស្រាយនូវរាល់បញ្ហាដែលកើតមានក្នុងមូលដ្ឋានខ្លួនបន្តិចសោះឡើយ ។ ការប្រព្រឹត្តបែបនេះជាអំពើក្បត់ជាតិ បង្ក អោយជាតិលិចលង់ទៅក្នុងភក់ជ្រាំ ។ ទន្ទឹមនឹងនេះដែរចំពោះនាយទាហានមួយ ចំនួនដែលពុំបានយកឋានៈរបស់គេទៅការពារសុវត្ថិភាពជូនរាស្ត្រឡើយគេបែរជា បង្កឱកាសអោយអ្នកនៅក្រោមបង្គាប់ខ្លួនសាបព្រោះនូវភាពអានាធិបតេយ្យ គំរាមកំហែងរាស្ត្រ តាមអំពើចិត្ត ។ ករណីខ្លះទៀតនាយទាហានមួយចំនួនកិបកេង ប្រាក់បៀវត្សពលទាហានចូលដៃជើងនិងជនទុច្ចរិតរកស៊ីខុសច្បាប់ ។ ការក្បត់នឹងវិជ្ជាជីវៈបែបនេះរបស់នាយទាហាន វានឹងធ្វើអោយសង្គមជាតិមានភាពច្របូកច្របល់ ដែលជាបុព្វហេតុទាញជាតិទាំងមូលអោយចូលទៅក្នុងហាយនភាព ។ សេចក្តីខាងលើនេះជាការឆ្លើយតបមួយផ្នែកតូចតាមទស្សនៈប្រធានដែលបានលើកឡើងស្រាប់ ។

តាមច្បាប់ប្រទេស មន្ត្រីបុគ្គលិករដ្ឋត្រូវបំពេញករណីកិច្ចចំពោះសង្គមជាតិ ដោយម្នាក់ៗ ត្រូវប្រកាន់ជំហរស្រលាញ់ការងារត្រូវធ្វើការអោយម៉ត់ចត់ ។ សំខាន់ជាងនេះត្រូវចំនាយកំលាំងកាយអាយុជីវិត ដើម្បីការពារ -

www.budhist.gov.kh www.elibraryofcambodia.org

ផលប្រយោន៍ជាតិទាំងមូល ។ ប៉ុន្តែមន្ត្រីបុគ្គលិករដ្ឋ ក្នុងរឿងគូលីកំណែនពុំ បានធ្វើនូវអ្វីៗដូចដែលរៀបរាប់ រួចមកហើយនេះទេ ។ ករណីដូចជាមេឃុំផាន់ គេដើរទារពន្ធដារពីរាស្ត្រ សង្កត់ករាស្ត្រអោយលៀនអណ្តាត។ មិនតែប៉ុណ្ណោះ មេឃុំផាន់បានអនុវត្តទស្សនៈ «ត្រីងៀតឆ្មៀតពង» ។ គឺគេបានឆ្មៀតពេលដែលរាស្ត្រមានរវល់ពុំបាន ទៅធ្វើគូលីកំនែនតាមការកំនត់ ។ គេបំភ័យរាស្ត្រអោយផ្តាក់លុយកាក់ ។ លុយ កាក់ទាំងនោះត្រូវចូលក្នុងហោប៉ៅមេឃុំផាន់ ។ លើសពីនេះទៀត មេឃុំផាន់ជា អ្នកមិនពូកែខាងលើកស្ទួយរាស្ត្រអោយមានជីវភាពមុនខ្លួននោះទេ តែគេពូកែខាងវាយអែបស៊ីអប រកស្រីញី ផ្តាប់ផ្តុនចៅហ្វាយស្រុកដែលជាមន្ត្រីពាល ។ បំនងគេគឺធ្វើយ៉ាងណារក្បាបុណ្យសក្តិខ្លួន ដើម្បីទាញយកឥទ្ធិពលពីបុណ្យសក្តិនោះកើប មាស ប្រាក់ពីលើទឹកភ្នែករាស្ត្រ ។

មិនខុសគ្នាពីមេឃុំផាន់ប៉ុន្មានទេ ។ ចៅហ្វាយស្រុកក៏ជាមន្ត្រីមួយរូបដែលពុំវិវរវល់ទាល់តែសោះក្នុងការបំពេញការងារស្របនឹងតួនាទីខ្លួនដែលជាចៅហ្វាយស្រុក ។ គេទំលាប់ដើរជ្រៀតជ្រកតាមភូមិឃុំសប្បាយក្នុងផ្លូវកាមគុណ ។ ជាក់ស្តែងគឺសប្បាយនិងនាងវ៉ែនដែលជានារីលក់ខ្លួន ដោយអំណាចទឹកប្រាក់ដែលគេបានអោយ ។ ព្រមជាមួយគ្នានេះទៀត ចៅហ្វាយស្រុករូបនេះបានប្រើកលល្បិចពិសពុល ប្រើលុយបំនងអោយនាងហេងដែលជាគូដណ្តឹងលឹម ធ្វើជាស្រីលួចលាក់ខ្លួន ។ តែនាងហេងបដិសេធ គេបានគំរាមកំហែងចាប់ចងធ្វើបាប ដល់ឪពុកម្តាយនិងនាងហេង ព្រោះខឹងថានាងមិនលះក្រោមឥទ្ធិពលដ៏ឆ្កួតលីលើរបស់ខ្លួន ។ សាហាវជាងនេះទៀតចៅហ្វាយស្រុកនិយមប្រើពាក្យសំដីអសុរស គ្មានសីលធម៌ទៅលើចាស់ទុំ ដែលអាចបង្កើតកុហកលួនខ្លួនបាន ។ ការបំពេញ ករណីយកិច្ចវិជ្ជាជីវៈមិនត្រឹមត្រូវរបស់

www.badmis.gov.kh www.elibraryofcambodia.org

មន្ត្រីបុគ្គលិករដ្ឋ ដូចដែលយើងបានបង្ហាញ ខាងលើ ញុំងអោយប្រជារាស្ត្រ
រងទុក្ខវេទនាព្រាត់និរាសកូនចៅ ឪពុកម្តាយស្លាប់បាត់បង់ជីវិត ។ ម្នាក់ៗមាន
ជីវិតប្រៀបដូច «អំពៅនៅកណ្តាលឃ្មាប » ។ គេគេចទៅណាក៏ពុំរួចដូចពាក្យ
ចាស់បូរាណលើកឡើងថា « ចុះទឹកក្រពើ ឡើងលើខ្លា » ដូចនោះឯង ។

ងាកមកមើល រឿងព្រះអាទិត្យរះ លើផែនដីចាស់ ឯណោះវិញ ។
មន្ត្រីបុគ្គលិករដ្ឋ បន្ថែមទាំងតំនាងរាស្ត្រផងដែរ ។ ពួកគេទាំងនោះសុទ្ធតែបាន
យកករណីយកិច្ចវិជ្ជាជីវៈទ្រាប់តូចអង្គុយគ្រប់ៗគ្នា ។ ក្នុងនោះជាដំបូងយើង
ឃើញមានគ្រូពេទ្យនរា ជាភស្តុតាងស្រាប់ ។ គ្រូពេទ្យរូបនេះបានក្បត់នឹងវិជ្ជា
ជីវៈខ្លួនត្រង់គេគ្មានមនសិការចំពោះការងារ ។ គេពុំបានបំពេញតួនាទីជាគ្រូ
ពេទ្យដែលត្រូវសង្រ្គោះអ្នកជំងឺគ្រប់រូបដោយចិត្តសប្បុរសឡើយ ។ ជាក់ស្តែង
នៅពេលដែលសមទៅអញ្ជើញ គេមកជួយសំរាលកូនអោយប្រពន្ធខ្លួនគេបាន
សំលឹងឃើញសមជាអ្នកក្រីក្រ គេពុំព្រមទៅតាមសំនូមពរសមឡើយ ។ គេ
បោះពាក្យសំដីថា «គេរៀនសូត្រអស់លុយកាក់ច្រើនណាស់ គេពុំអាចប្រើ
ពេលវេលាចំនេះដឹងទៅ មើលជំងឺអ្នកដែលគ្មានផលប្រយោជន៍ផ្តល់អោយគេ
នោះឡើយ » ។ សំដីប៉ុណ្ណោះ ពោរពេញទៅដោយខ្លឹមសារច្បាស់លាស់ស្តែង
អោយឃើញពីចិត្តរបស់គ្រូពេទ្យនរា ដែល « គេធ្វើការងាររដ្ឋដោយយេរ
លើគំនិតអត្ថទត្ថភាពជាមូលដ្ឋាន»។ គំនិតនេះ ជាប្រភពធ្វើអោយសង្គមជាតិ
ជួបនូវភាពអាប់អួរ ។ រាស្ត្រក្រីក្រដែលជាអ្នកជំងឺ ពិតជាដូចសំដីសមថា
«រង់ចាំតែថ្ងៃស្លាប់តែប៉ុណ្ណោះ» ។ ទីបំផុតទង្វើពេទ្យនរា បានធ្វើអោយអ្នកជំងឺ
អស់ជំនឿលើគ្រូពេទ្យ ។ សមត្រូវព្រាត់ពីប្រពន្ធគ្មានថ្ងៃវិលត្រឡប់មកវិញ
នៅពេលសំរាលកូនពុំបានដោយគ្មានអន្តរាគមន៍តាមក្បួនវេជ្ជសាស្ត្រទំនើប
របស់គ្រូពេទ្យនរានោះទៅ ។

www.bunnat.gov.kh www.elibraryofcambodia.org

រួមជាមួយគ្នានេះដែរ លោក សួន សុរិន្ទ បានពន្លេចអោយយើងឃើញពីករណីភ្នាក់ងារប៉ូលីស ដែលបានប្រព្រឹត្តរំលោភយ៉ាងពេញទំហឹងទៅលើសិទ្ធិពលរដ្ឋ ។ ដូចជាគេបានធ្វើការឃាត់ឃាំងឃុំសម និងប្រពន្ធដោយការចោទប្រកាន់គ្មានភស្តុតាងគ្មានយុត្តិធម៌ ។ គឺមានន័យថា គេបានធ្វើរំលងនឹងវិជ្ជាជីវៈជាប៉ូលីស ដែលមុននឹងផ្តន្ទាទោសឬចាប់ចង បុគ្គលណាម្នាក់ចាំបាច់ត្រូវធ្វើការស្រាវជ្រាវ តាមដានរកភស្តុតាងអោយបានគ្រប់សព្វជាមុនសិនមុននឹងធ្វើការ ពិន័យជាក់ទោសបុគ្គលនោះ ។ តើមានប៉ូលីសប៉ុន្មាននាក់ទៀតដែលបានយកអាវុធ យកអំណាច ជាអ្នកដែលមានតួនាទី ការពារសុវត្ថិភាពសង្គមជាតិទៅធ្វើ អោយសង្គមជាតិជួបតែអសន្តិសុខ គ្មានសណ្តាប់ធ្នាប់ គ្មានយុត្តិធម៌សង្គមនោះ ។ យើងជឿថា ប្រសៅលជាមិនអត់ទេមើលទៅភ្នាក់ងារប៉ូលីស របៀបភ្នាក់ងារ ប៉ូលីសដែលពោកសួន សុរិន្ទ បានបង្ហាញក្នុងរឿងរបស់គាត់ ។ បើប្រសិនជាសង្គមជាតិមានមន្ត្រី បុគ្គលិកប្រភេទនេះច្រើនមែននោះវាមិនខុសពី « យកពង មាន់ទៅធ្វើក្អែក យកដែកទៅធ្វើជាងដែក» នោះឡើយ ។ អាវុធនិងសិទ្ធិអំនាច ដែលជាតិប្រគល់អោយក្រុមម៉ូលីសពុំបានបំពេញករណីយកិច្ចវិជ្ជាជីវៈប្រាកដជា នឹងក្លាយទៅជាវត្ថុសំលាប់ជាតិអោយស្លាប់បាត់បង់ជីវិតពុំខាន ។

ទន្ទឹមនឹងការបញ្ជាក់ពីភាពមិនអើពើបំពេញករណីយកិច្ចវិជ្ជាជីវៈរបស់ភ្នាក់ងារប៉ូលីសរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់នៅបានលើកពីសកម្មភាពក្បត់ករណីយកិច្ចវិជ្ជាជីវៈ របស់នាយមេការត្រួតត្រាពន្ធនាគារម្នាក់ទៀត។ ធម្មតាអ្នកមានទោសកំហុសចាំបាច់ត្រូវទទួលការពិន័យទៅតាមទោស កំហុសរបស់ខ្លួនទើបស្របតាមគតិច្បាប់ ។ តែមិនដូច្នេះទេ ទណ្ឌិតឈ្មោះហួរត្រូវបានទទួល អាទិភាពដេកនៅ ស្ទឹងក តាប់ប្រសើរជាងទណ្ឌិតដទៃ ក្នុងនោះ

www.budinst.gov.kh www.elibraryofcambodia.org

មានសមផងដែរ ។ តើនេះមកពីមូលហេតុអ្វី ? ។ នេះគឺមកពីការបំពេញ
ករណីយកិច្ចវិជ្ជាជីវៈពុំបាន សមស្របរបស់មេការត្រួតត្រាគុកនេះឯង ។គេបាន
ទទួលសំនែនដ៏ក្រាស់ក្រែលពីទណ្ឌិតហួរ ។ គេបានផ្តល់ឱកាសអោយជននោះ
បង្កអនាធិបតេយ្យតាមអំពើចិត្តក្នុងពន្ធនាគារ ។គេបានទុកចោលតួនាទីកែលំអ
ចរិតពាលបំពារបំពានច្បាប់ដល់ជនទុច្ចរិតមួយកន្ទុប ។ទង្វើបែបនេះហើយ
ដែលធ្វើអោយភាពច្របូកច្របល់ក្នុងពន្ធនាគារបានកើតមានឡើង ។ មេត្រួត
ត្រាគុកកាន់ជើងទណ្ឌិតហួរ រួចវាយដំច្រំធាក់ សមបន្ថែម ពីលើពួកដែដល់
ដែលធ្លាប់ស៊ីសំនែនទណ្ឌិតហួរចេញមុខជាអង្គរក្សការពារគេនៅក្នុងគុក ។
ចំណុចនេះជាភាពអាប់អួរមួយដ៏ធំធេងក្នុងវង្វង់សង្គមជាតិនោះ ។

ជាទីអវសាននេះ លោកសួន សុរិន្ទនៅបានឆ្លៀតបើកកកាយអោយ
យើងបានឃើញបានឮនឹងត្រចៀក ពាក្យប្រមាថក្តែងៗរបស់តំណាងរាស្ត្រ
បោកប្រាសឈ្មោះយើង ដែលបានពោលពាក្យអសុរស ដៀលត្មះសមថា «ឆ្កួត
ឯងមករំលឹក បើកកកាយគុណអញ្ចឹងមិនកើតទេឯងក៏ដឹងស្រាប់ហើយថា ការ
បោះឆ្នោតវាជាករណីយកិច្ចរបស់ឯងដែលជាពលរដ្ឋ គ្មានតបានបង្ខំឯងថា
អោយបោះឆ្នោតអោយគ្នាឯណា ឥឡូវឯងមកនិយាយអីឆ្កួតៗអញ្ចឹង។ ទៅចេញ
ទៅគ្មាមិនត្រូវការទទួលមនុស្សរបៀបឯងអញ្ចឹងទេ» ។ សំដីប៉ុណ្ណោះចង់ឆ្លុះ
បញ្ចាំងអោយឃើញថា យើង ជាតំណាងរាស្ត្រដែលរមិលគុណរាស្ត្រ។
គេពុំបានធ្វើសកម្មភាពអោយស៊ីនឹងពាក្យ «តំណាងរាស្ត្រ»ទេ ។ សំដីនេះគួរ
អោយឈ្មោះថា «ចៅហ្វាយរាស្ត្រ ឬអ្នកហុតឈាមរាស្ត្រ»វិញ ។ ព្រោះគេ
មិនយកចិត្តទុកដាក់បំរើផលប្រយោជន៍រាស្ត្របែរជា យកអំណាចដែលរាស្ត្រ
ប្រគល់អោយបីតស្រួបយកចំណេញពីរាស្ត្រហួតក្លាយខ្លួន ទៅជាសេដ្ឋីលើ
សមុទ្រទឹកភ្នែករាស្ត្រ។ បើយ៉ាងនេះឯណាទៅគាំពារឯរឿងនៃសង្គមជាតិ ។

www.radiotvfo.gov.kh www.elibraryofcambodia.org

ទេប្រសិនបើមន្ត្រី រាជការ រដ្ឋ តំណាងរាស្ត្ររបៀបតែម្យៀយើងជាតិពិតជាជួប តែនឹងឱនភាព ជីវភាពរាស្ត្រជុនដាបក្បាននឹបញ្ចប់ ។ គឺចង់និយាយថា មន្ត្រីបុគ្គលិកតំណាងរាស្ត្រពុំព្រមបំពេញករណីយកិច្ចវិជ្ជាជីវៈ ជូនរដ្ឋបានល្អបានទៀងទាត់ត្រឹមត្រូវតាមគោលការណ៍កំណត់រៀងច្បាប់រដ្ឋរាជាអណ្តូយអាក្រក់បំផុតសរាប់ទឹកដីនិងរាស្ត្រស្ងួតត្រង់ទូទៅ ។

៣- <u>សរុបការពន្យល់</u>

រួមសេចក្តីមកមន្ត្រី បុគ្គលិករដ្ឋដែលរដ្ឋបានប្រគល់ការងារអោយខ្លួនធ្វើស្របតាមជំនាញតាមឯកទេសតាមសមត្ថភាព ដែលខ្លួនធ្វើបានប៉ុន្តែគេបានទុកចោលការងារនោះ ឬ បើធ្វើដែរលុះត្រាតែគេទទួលបានផ្លែវិជ្ជប្រយោជន៍ ដ៏លើស លប់ ក្បត់ឧត្តមគតិ ក្បត់មនសិការខ្លួន គ្មានសតិសម្បជញ្ញៈមើលអោយឃើញសខ្មៅ ។ ភាពព្រងើយកន្តើយភាពអគតិលើការងារបែបនេះ ជាប្រភពធ្វើអោយជាតិ ជំបទុរភិក្ស អយុត្តិធម៌សង្គម ជាតិដើរថយក្រោយ ។ ប្រការនេះឆ្លើយតបនឹង ទស្សនៈដែលបានស្រដី «មន្ត្រីបុគ្គលិករដ្ឋដែលពុំបានបំពេញ ករណីយកិច្ចវិជ្ជាជីវៈ ទៀងទាត់ ចាត់ទុកជាអ្នកប្រព្រឹត្តបាបកម្មយ៉ាងធ្ងន់ធ្ងរចំពោះសង្គមជាតិ» នោះ។

III- <u>យោបល់បញ្ចប់</u>

ផ្អែកលើ បំនកស្រាយផ្សេងៗជុំវិញភស្តុតាងដែលយើងបានបង្ហាញពីក្នុងសង្គមមនុស្ស និងពីវណ្ណកម្ម ដ៏ល្អឯករបស់អ្នកនិពន្ធអក្ស រសិល្ប៍ថ្នាក់ទី ១២ អាចអោយយើងវាយតំលៃបានថា ទស្សនៈដែលបានលើកឡើងក្នុងប្រធានមានអត្ថន័យ លួតួរអោយកោតសរសើរក្រៃលែង ។ ពីព្រោះទស្សនៈនេះចូលរួមចំនែកពញ្ជាក់ស្មារតី ដល់មន្ត្រីបុគ្គលិករដ្ឋគ្រប់រូប អោយភ្ញាក់រលឹកប្រឹងប្រែងធ្វើការងារបំរើ សង្គមជាតិ អោយអស់ពីចិត្តពីថ្លើម ស្របតាមទំនុកចិត្តចិត្តរបស់រដ្ឋ ។ ដូចនេះបំនាក់ថាមានឈ្មោះជាពលរដ្ឋដែលមានភ័ព្វវាសនាមានលទ្ធភាព ធ្វើការងារ រដ្ឋត្រូវតែលះបង់ចោលគំនិតទ្រឹស្តីស្តួរ -

www.budinst.gov.kh www.elibraryofcambodia.org

ក្បតវិជ្ជាជីវៈ ម៉ាៗយកតែសិងអោយអស់ពី ក្នុងខ្លួន ។ នោះទើបអ្នកមាន ឈ្មោះថា ស្ថាបនិកដែលពុំអាចខ្វះបាននៃជាតិ ។ ពិសេសអ្នកនឹងមាន ឈ្មោះថា សសរដ៏រឹងមាំទល់ទ្រសង្គមជាតិ អោយមានវឌ្ឍនភាព និង កិត្យានុភាពដ៏ល្បីរន្ទឺលើលោកយើងនេះ ។

ជាតិរឹងមិនពឹងមន្ត្រីពុក តែជាតិត្រូវការអ្នកចេះឈឺឆ្អាល
ជាតិសុខមិនពឹងបុគ្គលិកពាល អោយជាតិដុះដាលចំរើនទៅមុខ ។

ម៉ិញ - ឈឺចាន

សាស្ត្រាចារ្យវិទ្យាល័យ បឹងត្របែក

www.budinst.gov.kh www.elibraryofcambodia.org

ប្រធានទី ៥ : មានសុភាសិតខ្មែរមួយឃ្លាថា«ឈើពុកកុំដាក់គូថអង្គុយ» ។ ចូរអ្នកមកស្រាយសុភាសិតដោយផ្អែកទៅអក្សរសិល្ប៍ថ្នាក់ទី១២ ដែលអ្នកបានសិក្សារួចហើយ ។

គំរោងតែង

ចំណោមការស្រាយ

១-ឧទ្ធរណ៍

- ឈើពុកឈើមិនខ្លឹម ឈើផុយរលួយដោយទឹក →វាជាជំរកនៃសត្វអសិរពិស បើអង្គុយលើ ⇒ សត្វនោះចេញមកខាំឬ ទិចអោយមានរបួសមានការចុកចាប់ ។

- ឈើពុកបើហ៊ានអង្គុយលើអាចធ្វើអោយអ្នកអង្គុយដួលរលំ បះដៃជើង ⇒គ្មានចំនែកទប់ទល់ទំងន់ខ្លួនដែលអ្នកអង្គុយ ដាក់គូថលើវា ។

២-ឧទ្ធរណ៍

- ឈើពុក →រាស្ត្រក្រីក្រទន់ខ្សោយភាគច្រើន

- កុំដាក់គូថអង្គុយ → កុំមើលងាយ រមិលគុណ ចាត់ទុកថាគេខ្លាច បើហ៊ានធ្វើបែបនេះ ។

- វិនាសខ្លួន បាត់បង់នូវអ្វីៗទាំងអស់ ⇒ពួកគេមានកំលាំងច្រើន

- ហ៊ានមើលងាយរងគ្រោះដោយការប្រឆាំងតប

ឧទាហរណ៍ពីអក្សរសិល្ប៍ទី ១២

* រឿងភូមិតិរច្ឆាន

- ពារាំងធ្វើចាបខ្មែរ ជាន់ឈ្លី លើជាតិទន់ខ្សោយ ⇒អន្តរាយដោយការប្រឆាំងតប ។

www.buddhist.gov.kh www.elibraryofcambodia.org

- នៅ ជូន + អ្នកក្រាំវែលាវ ពួតដៃកំទេច

- នាងនី- នាងប៊ីចេញតវ៉ា ឥតខ្លាចនឹងការមើលងាយរបស់បាដេស និងពាក្យព្រហើនរបស់ខ្មែរចិនបារាំង

* <u>រឿងគួលីកំនែន</u>

- ជប៉ុន- បារាំង- ចក្រពត្តិអាមេរិក ចង់ក្តោបកម្មជាអោយចិតនៅជាឈ្នាន់ សំរាប់បំរើសង្គ្រាម និង អាណានិគម ខ្មែរ គ្រប់រូបជំទាស់

- រាស្ត្រខ្មែរគ្រប់រូប តវ៉ា មានលឺម នូដួង ម៉ឺង រហូតបានឯករាជ្យ

- ម៉ឺង តវ៉ា បារាំង ពេលកំហែងគំរាមខ្លួន- ការពារបុគ្គលិកដែលត្រូវបរទេសមើលងាយ- តស៊ូជាមួយបង

- ចៅហ្វាយស្រុកមើលងាយ ស្ត្រីភេទទន់ខ្សោយ- យសសក្តិ

- បដិសេធសំដី ចេះហ្វាយស្រុកយកនាងជាស្ត្រីកំនាន់តាមអ្នកយកគាប់ គួរគឺ មេឃុំជាន់

*<u>រឿងព្រះអាទិត្យថ្ងឹរលើផែនដីចាស់</u>

- នាយទុន ដែលជាថៅកែធំៗចាត់ទុកកម្មករដូចសំរាមដោយយល់ថាកម្មករកោតញញើតកំលាំងទឹកប្រាក់ខ្លួន ។

- សមជំទាស់នឹងអំពើថៅកែហុកវិលោភប្រពន្ធ ។

- ជជែកវែកញែកនឹងថៅកែ សេង ហុង ដែលទាត់ចោលកម្មករខ្មែរលែងអោយធ្វើការ ។

*<u>រឿងថៅកែចិត្តចោរ</u>

- ថៅកែជាន់ឈ្លីលើកម្មករ នឹងថាកម្មករកោតញញើតខ្លួន ។

- ពូហាំតាមសងុំញទារប្រាក់ តំលៃការងារខ្លួនដែលបានធ្វើអោយថៅកែ ចិត្តចោរ + បកអាក្រាតថៅកែ + ប៉ូលីស ។

www.buddhist.gov.kh www.elibraryofcambodia.org

- កម្មករទាំងអស់សុខចិត្តអត់ការធ្វើតែពុំព្រមគាំទ្រអំពើព្រៃផ្សៃរបស់ចៅកែចិត្តចោរ ។

៣- <u>សរុប</u>

- បង្ហាញ អត្ថន័យរួមនៃសុភាសិត

⌘⌘⌘

ពិសេចក្តីអធិប្បាយ

I-<u>សេចក្តីផ្តើម</u>

ឆ្លងកាត់ការរស់នៅយូរអង្វែង ចាស់ចូរាណខ្មែរយើង លោកតែងប្រមើលឃើញនូវបញ្ហាជាច្រើន ក្នុងសង្គមមនុស្ស ។ បញ្ហាដែលចោទមានឡើងហើយនោះបាន បង្កើតនូវគំនិតប្លែកៗធ្វើអោយអ្នកជួបនូវបញ្ហាទាំងនោះទទួលផលល្អនិងផលអាក្រក់ ។ ដូចនេះដោយមានបំនងចង់អោយកូនចៅទទួលបាន តែផលល្អដូចតាយើងបានលើកនូវសុភាសិតមួយឃ្លាទុកជាការទូន្មានកូនចៅជំនាន់ក្រោយថា « ឈើពុកកុំជាក់គូថអង្គុយ » ។ តើសុភាសិតនេះមានអត្ថន័យសំខាន់ៗដូចម្តេចខ្លះ ? ក្នុងអក្សរសិល្ប៍ខ្មែរថ្នាក់ទី១២ មានផ្នែកណាខ្លះដែលឆ្លើយតបសុភាសិតនេះ ? ។

II-<u>តួសេចក្តី</u>

១- <u>ន័យត្រង់</u>

ភាគច្រើននៃសុភាសិតខ្មែរ យើងតែងតែបញ្ចូលនិវាទ ការអប់រំផ្តល់ជំ បូន្មានដោយយោងទៅលើធម្មជាតិ មកធ្វើជាប្រធានបទ ។ យ៉ាងណាមិញសុភាសិតដែលយើងនឹងលើកមកស្រាយនាពេលនេះបញ្ជាក់ថា « ឈើពុក

www.budinst.gov.kh www.elibraryofcambodia.org

កុំដាក់គួចអង្គុយ» ។ «ឈើពុក» អាចពន្យល់តាមន័យត្រង់ថាជា ឈើដែលមិនខ្លឹមឈើដែលមានសាច់ធុសៗ ឈើដែលស្អុយរលួយ ដោយឥទ្ធិពលទឹកភ្លៀងឬកំដៅ ថ្ងៃ ។ ជួបនូវឈើប្រភេទនេះ ជូនតាខ្មែរប្រដៅថា « កុំដាក់គួចអង្គុយ » លើអោយ សោះ ។ តើនេះមកពីមូលហេតុអ្វី ?

តាមធម្មតាឈើពុកផុយ ជាជំរកដ៏ប្រសើរនៃការស្នាក់ អាស្រ័យនៅរបស់ពពួកសត្វល្អិតដែលមានអសិរពិស រួមមានខ្លួយ ក្អែប ខ្យាជ្រី ពស់ផ្សេងៗ។ នៅពេលណាដែលយើង ដាក់បង្គុយទៅលើវា សត្វដែលនៅក្នុងអំពុក ឈើនោះនឹងវារចេញមកខាងក្រៅខាំ ទិច ឬ ចឹក បង្កអោយយើងមានរបួសទទួលរងនូវការឈឺចាប់ពេលផ្សា ។ ករណីខ្លះអាចអោយយើងស្លាប់បាត់បង់ជីវិត ក៏សឹងមាន ។ ម្យ៉ាងវិញទៀតឈើដែលពុក ពុំមានស្ថានភាពរឹងមាំដែលអាចទប់ទល់ នឹងទំងន់បង្គុយរបស់យើងដែលមាន ទំងន់សង្កត់ធ្ងន់ទៅលើវាបានទេ ។ ពេលនោះហើយដែលធ្វើអោយប្រេះបែក ។ គ្រានោះហើយអ្នកនឹងអស់ជំហរជួល ផ្ងារដៃផ្ងារជើងរងនូវគ្រោះថ្នាក់ដល់រូបរាងកាយ ។ ដូចជាត្រូវមុខមាត់រយៈដៃ ជើងជាដើម ។ ហេតុនេះបើបង្រួមសុភាសិតនេះតាមន័យត្រង់ចង់បញ្ជាក់ដោយខ្លឹថាការអង្គុយលើឈើដែលមានភាពផុយរលួយ នោះវានឹងធ្វើអោយអ្នកអង្គុយលើ នោះមានគ្រោះថ្នាក់ផ្សេងៗដោយសារសត្វមានពិសយាយីឬពីការបែកបាក់នៃឈើនោះ ។

២- ន័យធៀប

បើពិនិត្យលើន័យធៀបមកសង្គមមនុស្សវិញ ។ «ឈើពុក» ។ ចង់ប្រដូចមកអ្នកដែលមានឋានៈទន់ទាប ឬរាស្ត្រ ប្រជាក្រីក្រទូទៅ ។ « កុំដាក់គួចអង្គុយ» ចង់សំដៅលើន័យថាមិនអោយអ្នកដែលមានឥទ្ធិពលមានអំណាច

www.budinst.gov.kh www.elibraryofcambodia.org

មានកំលាំង ច្រើនប្រមាថមើលងាយ រមិលគុណ ឬ ចាត់ទុកថាអ្នកទន់ខ្សោយ ទាំងនោះ មិន ហ៊ានធ្វើអ្វីខ្លួន នៅពេលដែលខ្លួន រំលោភជិះជាន់លើ គេហួស ហេតុនោះ ។ ការប្រមាថលើមនុស្សដែលប្រដូចឈើពុក វាពិតនឹងធ្វើអោយ ពពួកជិះជាន់វិនាស អន្តរាយខ្លួន បាត់បង់នូវអ្វីៗទាំងអស់ ដែលខ្លួនប៉ងប្រាថ្នា ជាក់ជាពុំខាន ។

ក្នុងន័យនេះ យើងសង្កេតឃើញថា បារាំងបានទាត់ចោលនូវគំនិត «ឃើញខ្លាក្រាបស្មានថាខ្លាសំពះ » គេប្រើគ្រប់ល្បិចកលគាបសង្កត់តាម រូបភាព ទារពន្ធដារ ប្រមូលខ្មែរអោយធ្វើទាហានច្បាំងការពារពួកគេ ។ គេហ៊ានធ្វើបែប នេះដោយគេនឹកថា ខ្មែរជាឈើពុក ពុំមានគំនិតឯណាគាស់ រំលើងសើរើ ឧយោបាយដ៏ខ្ទៅក្រខ្ទក់របស់គេឡើយ ។ មើលចុះមានឯណា ប្រជារាស្ត្រខ្មែរក្រាំង លាវ ដែលជាតីនាងអោយធន្ទះខ្មែរទូទៅប្រទេសក្រោក ឡើងពួកដៃគ្នាបំបាក់បារាំង អោយភ្លឺភ្នែកជាបន្តបន្ទាប់ ។ ករណីដូចជាក្រុម តស៊ូរបស់អ្នកក្រាំងលាវដឹកនាំ ដោយនៅនិងជួនបានហ៊ឹក ក្បួនយុទ្ធសាស្ត្រ ស្ទាត់ជំនាញ រួមនឹងប្រើអាវុធបូរាណ វាយសំពងទៅលើ បារាំង និងបក្សពួក អោយអន្តរាធានរត់ផាសក្រឡាំ ។ ចំណែកឯ នារីៗខ្មែរដែលមាននាងនី នាងប៊ី ជាគំនាង គេមិនខ្លាចញញើតនឹងអាវុធនឹងពាក្យ ជំរាបកំហែងរបស់ពួកចៃ បារាំងបន្តិចសោះឡើយ ។ ដូចជាគេបានឱយាយតបត យ៉ាងមុះមុតចំពោះពួក នោះថា « សូមថីមានប្រសាសន៍អោយស្រួលមកមើល ព្រោះយើងខ្មែរដូចគ្នា ទេតើ ! នែណោក បើពួកខ្ញុំ មិនស្លាប់ដោយសារថីទេ ! ក៏ស្លាប់ដោយចាស់ជរា ឬជំងឺដែរកុំមកក្អេងក្អាងចំពោះពួកខ្ញុំ » ។ ទន្ទឹមនឹងនេះ នាងតន់ ក៏បានបញ្ជៀ ប្រពិកមួផ្លូវចិត្តរបស់ខ្លួនថា « បំនាច់នឹងស្លាប់ត្រូវរកសម្លៅ រកខុសរកត្រូវ ជួនប៊ីនិងខ្មែរ រងទុកអោយលើញដួងៗ » ។

www.budinst.gov.kh www.elibraryofcambodia.org

អ្វីៗដែលបញ្ជាក់ខាងលើនេះ គឺជារឿងដែលបារាំង គិតមិនដល់ថា «គំនិតប្រមាថមើលងាយ» ធ្វើបាបតាមជនបទស្រុកស្រែចំការ និងធ្វើអោយពួកគេជួបនូវបញ្ហាបែបនេះសោះឡើយ ។ រាស្ត្រខ្មែរត្រូវបានមេធាវីសញ្ជាតិ បារាំងគាំទ្រដោយឈរលើហេតុផលថា «បារាំងបានធ្វើជ្រុលលើខ្មែរដោយអយុត្តិធម៌ និងសាហាវយង់ឃ្នងពន់ពេក» ។

ងាកទៅមើលលើទំព័រឿងគូលីកំនែនឯណោះវិញ ។ ពួកបារាំង ជប៉ុន ចក្រពត្តិ អាមេរិច គេបានជ្រលក់ជាតិ និងរាស្ត្រខ្មែរទៅក្នុងភក់ជ្រាំដ៏សែនជ្រៅ ដើម្បីបំរើគំនិតថា «ទន្លេដប់មិនស្កប់សមុទ្រ» ។ ពោលគឺមហាអំណាចទាំងអស់នេះបានទំលាក់ខ្លួនដ៏ធំមាំទៅលើឈើពុក គឺខ្មែរយើងតែម្តង។ ពួកគេប្រាកដក្នុងចិត្តថា «ខ្មែរជាជាតិមួយដែលនរណាធ្វើអ្វីៗដោយមិនត្រឹមត្រូវលើខ្លួនក៏ខ្លួននៅតែ ទ្រាំទទួល យកដោយឥតឥរ៉ាអ្វីទាំងអស់» ។ គំនិតមើលងាយនេះបានជំរុញអោយពួកនោះត្រូវវិនាស ។ តួយ៉ាងនួងម៉ុងលីមរួមនិងរាស្ត្រខ្មែរដទៃទៀតបាន សហការគ្នាចូលតស៊ូក្នុងព្រៃ រហូតដល់បានសំរេចជោគជ័យលើពួកមហាអំណាចទាំងនោះ ។ អ្នកតស៊ូខ្មែរមិនខ្លាចការបំភ័យរបស់បារាំង មិនខ្លាចការស្លាប់ មិនទន់ជ្រាយ និង បុណ្យសក្តិទឹកប្រាក់លង់ខ្លួនទៅតាមពួកទាំងនោះងាយៗ ។ ភស្តុតាងលើចំនុចចុងក្រោយនេះដូចដែលនាងហេងបានបដិសេធដាច់អហង្ការ មិនទទួលចៅហ្វាយស្រុកចៃបារាំងជាប្តីលួចលាក់ ។ គឺបានសេចក្តីថានាងពុំអនុញ្ញាត្តិអោយមន្ត្រីបែបនេះជាប់ឈ្លើលើកិត្តិយសនាងបានឡើយ ។

រួមនឹងនេះរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ មានផ្នែកមួយចំនួនដែលអាចឆ្លើយតបតាមន័យធៀបនៃសុភាសិត «ឈើពុកកុំដាក់គូថអង្គុយ» ផងដែរ។ ជាសេក្តីភាពត្រង់អ្នកនិពន្ធបានប្រាប់ពីសកម្មភាពរបស់ថៅតែ សេង ហុង គេ

www.khmerstudy.info www.libraryofcambodia.org

បណ្តេញកម្មករខ្មែរ ដោយបញ្ជូលជំនួសមកវិញនូវកម្មករបរទេស ។ ភាព ប្រមាថ លើសមត្ថភាពកម្មករជាតិខ្មែរបែបនេះ ញុំាងអោយសមន្ត្រីពុំបាន គេនិយាយតបត យ៉ាងខ្លាំងចំពោះថៅកែ សេង ហុង «បើទុកជាលោកមិន បញ្ឈប់ ក៏ខ្ញុំឈប់ដែរ» ។ សមមិនព្រមរស់ និងធ្វើការក្រោមការគាបសង្កត់ របស់ សេង ហុង តទៅទៀតទេ។ នេះជាក្រិត្យក្រម «ជរាបណាមានការសង្កត់ សង្កិន វាត្រូវតែមានការរើបំរះ»ចៀសពុំរួច ។ ជាមួយគ្នានេះដែរ សម បន្ទាប់ ពីទទួលពតិមានស្តីពីថៅកែ ហុក ពាល «ចិត្តជាទេវទត្តមាត់ជាទេវតា» រំលោភដោយចេតនា លើប្រពន្ធខ្លួនរួចមកគេមានកំហឹងឆេះឈួលប្តូរស្តាប់រស់ នឹងថៅកែរូបនោះ ដើម្បីកុំអោយគេ ធ្វើអ្វីតាមទំនើងចិត្ត ។ ប្រតិកម្មរបស់សម បានធ្វើអោយថៅកែហុកព្រលឹងនៅចុងសក់ ។ ព្រោះគេពុំនឹកថា ការដាក់គួថ អង្គុយរបស់គេលើឈើពុកបង្កអោយមានអាសន្ន ដល់រូបគេបែបនេះសោះ ។

ទាក់ទងទៅនឹងរឿងថៅកែចិត្តចោរដែលហ៊ានមាក់ងាយលើស្មារតី កម្មករ ។ គឺក្រោយពីពួហាំ ធ្វើការអោយខ្លួនបានសំរេចរួចហើយ ថៅកែ រូបនេះ បានក្រឡាស់ពាក្យសំដី ដោះយករួចខ្លួន ។ គេពុំព្រមប្រគល់លុយអោយពួហាំ តាមការសន្យា ។ គេនឹកថា ពួហាំពិតជាអនុលោមតាមការបំភ័យរបស់ខ្លួន ។ ប៉ុន្តែផ្ទុយ ស្រលះឈើពុកដួចពួហាំ នៅតែតាមទារលុយពីថៅកែប្រកិតហើយ ព្រមទាំងឆ្លើយ យ៉ាងម៉ឺងម៉ាត់ថា « បើជាប់គុកក៏ជាប់ចុះតែរឿងមិនទារលុយគឺ គ្មានផ្លូវចប់ជាដាច់ខាត » ។ ឋិតនៅក្នុងភាព ទាល់ច្រកថៅកែចិត្តចោរប្រើ ស្មៀតថ្មី ប្រើលុយដ៏ខ្មៅ ក្រខ្វក់ទាក់ទាញចិត្តកម្មករ ដទៃទៀតអោយឆ្លើយ តាំទ្រខ្លួន ។ ជាលទ្ធផលកម្មករ រួមអាជីពរបស់ពួហាំសំរេចចិត្តព្រមគ្នាថា « មិន យកលុយថោក ទាប គេសុខចិត្ត អត់ការអ្វី ត្រង់ថា ឆ្លើយបំផ្លើសការពិត -

www.budinst.gov.kh www.elibraryofcambodia.org

ការពារថៅកែចិត្តចោរ គឺគេពុំអាចទទួល យកបានឡើយ ។ ទាំងអស់នេះ ហើយដែលបញ្ជាក់ថា « ឈើពុកកុំដាក់គួថអង្គុយ» នោះ ។

៣- <u>សរុបមតិ</u>

រួមសេចក្តីមកយើងឃើញថា សុភាសិត «ឈើពុកកុំដាក់គួថអង្គុយ» គឺមានទំនោរសំខាន់ទៅរកការប្រៀនប្រដៅមនុស្សអោយបញ្ឈប់រាល់សកម្ម ភាពមើលស្រាលធ៌ោះមនុស្សជួចគ្នា ។ដោយកុំនឹកស្មានតែម្នាក់ឯងថាអ្នកក្រ អ្នកទន់ខ្សោយសុទ្ធតែល្ងីល្ងើបណ្តោយអោយខ្លួនធ្វើបាបញ៉ាំញីតាមតែចិត្ត ។ គឺគេ ពិតជាតបតដើម្បីការពារសិទ្ធិសេរីភាពខ្លួន ។ ត្រង់នេះគឺមិនខុសពីសត្វ តែបន្តួចខ្សាវីរ ដែលនៅក្នុងឈើពុក ពុំនៅស្មៀមឡើយ ទាល់ដែលសត្រូវ ខ្លួនប៉ង ដោយចេតនាយាយីដល់ ការរស់នៅដ៏សុខសាន្តរបស់គេនោះ ។

III-<u>យោបល់បញ្ចប់</u>

សុភាសិត « ឈើពុកកុំដាក់គួថអង្គុយ » ជាសុភាសិតមានថវិ អប់រំផ្នែកចរិយាសាស្ត្រ ដល់មនុស្សទូទៅអោយប្រកាន់ចិត្ត ថ្លៃថ្នូរត្រូវចេះ អោរអាំណៃ ដល់មនុស្សជួចគ្នា មិនត្រូវវាយឫកកើងឯងម្ចើងហួសហេតុ បែបនេះ ដំកើងខ្លួនស្មើមេឃដោយកាត់ទុកអ្នកទន់ទាបក៏ឯងខ្លួនជាជីនោះទេ ។ ទាល់ បច្ចុប្បន្ននេះមនុស្ស ម្នាក់ៗអាចសិទ្ធិស្មើគ្នា ការណាអាចការប្រមាថ ធ្វើ អោយប៉ះពាល់ដល់កិត្តិយស និងភាពថ្លៃថ្នូរដល់រូបគេដោយចេតនានោះការ ក្រោកទាមទារសិទ្ធិកុំអោយមានការរំលោភពិតជាលេចរូបរាងជាក់ជាពុំខាន ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រធានទី៦ : «រឿងភូមិគិរច្ចានបានបកអាក្រាតពីនយោបាយដ៏ពិសពុលរបស់អាណានិគមនិយមបារាំង ចំពោះកម្ពុជា» ។ ចូរបង្ហាញ ។

គំរោងតែង

១- ពន្យល់ពាក្យ

បកអាក្រាត = លាតត្រដាង វែកញែកអោយឃើញច្បាស់

នយោបាយដ៏ពិសពុល = ល្បិចកលដ៏ខ្មៅក្រខ្វក់ វិធីគ្រប់គ្រងដឹកនាំគួរអោយស្អប់ខ្ពើម

២- បកស្រាយ

- ក្រាប់ពីសារបាននៃបារាំងឈានជើងចូលកម្ពុជា (ដាក់នឹមត្រួតត្រាលើកម្ពុជា ទាញយកផលប្រយោជន៍ពីកម្ពុជា ពង្រឹងអំណាច អភិវឌ្ឍលើគ្រប់វិស័យប្រទេសខ្លួន)

*នយោបាយដ៏ពិសពុលបារាំងរួមមាន ÷

- ដកហូតសិទ្ធិត្រួតត្រាអំនាចពីកម្ពុជា លើគ្រប់វិស័យ
- ផ្សាយវប្បធម៌ ខ្លួនបំបាត់ វប្បធម៌ខ្មែរ
- ធ្វើប្រជាភិថុតិ ដើម្បីជាខែល បិទបាំងមុខមាត់អាក្រក់
- ប្រើវិធានការអមនុស្សធម៌ ,ភាពអយុត្តិធម៌ រំលោភលើច្បាប់សិទ្ធិមនុស្សជំរុញអោយខ្មែរស្អប់ជំនួសគេ
- ប្រើឥទ្ធិពលអំណាច ទឹកប្រាក់ ទិញខ្មែរវង្វេងជាតិ អោយធ្វើបាបខ្មែរជួចគ្នា (បង្កើតភាពបែកបាក់សាមគ្គីខ្មែរ)
- បំបាត់ឆន្ទៈឥស្សរបស់ខ្មែរ ដែលប្រឆាំងនឹងពួកគេអោយបាត់បង់

www.budinst.gov.kh www.library.rajanibudda.org

ទស្សនៈអធិប្បាយ

I-សេចក្តីផ្តើម

អក្សរសិល្ប៍មានតួនាទីផ្តល់គតិអប់រំ ផ្តល់ចំនេះពីងផ្សែងៗ បង្កើនន្ធវ៍គំនិតប្លែកៗដល់មនុស្ស ។ ក្រៅពីនេះអក្សរសិល្ប៍ ក៏បានឆ្លុះបញ្ចាំងរាល់រឿងរ៉ាវដែលកើតមានពីអតីតកាល បង្ហាញពីបុគ្គលិកលក្ខណៈសម្បត្តិនៃជនណាម្នាក់ឬមួយក្រុមតាមរយៈ សិល្ប៍វិធីខ្ពស់របស់អ្នកនិពន្ធ ។ ក្នុងនោះយើងក៏បានឃើញថា «រឿងភូមិតិរច្ឆានជារឿង ដែលបានបកអាក្រាតពីនយោបាយដ៏ពិសពុលរបស់អាណានិគមនិយមបារាំងចំពោះកម្ពុជា » តើនយោបាយពិសពុលទាំងនោះមានអ្វីខ្លះ ?

II-តួសេចក្តី

១-ពន្យល់ពាក្យ

ឆ្នាំ ១៨៦៣ ដល់ ១៩៥៣ រាស្ត្រខ្មែរ រស់នៅទូរទុក្ខក្រៀមក្រំ ។ ប្រទេសជាតិត្រូវខ្មេចខ្ចាំ ។ជនបទនិងទីក្រុងពោរពេញទៅដោយភាពអយុត្តិ-ធម៌ ។ អ្វីៗទាំងនេះកើតពីនយោបាយដ៏ពិសពុលអាណានិគមនិយមបារាំង ។ ពាក្យ«នយោបាយ ដ៏ពិសពុល» ចង់សំដៅលើល្បិចកលដ៏ខ្មៅកខ្វក់ ឬវិធីដ៏កន្ទ្រាប់ក្រងគួរអោយស្អប់ខ្ពើមបំផុត ។ ផ្អែកលើន័យនេះ ទស្សនៈប្រធានចង់និយាយថា រឿងភូមិតិរច្ឆានគឺជារឿងដែល បានលាតត្រដាងអោយឃើញច្បាស់ពីល្បិចកលដ៏ខ្មៅ កខ្វក់របស់បារាំងពេលដែលគេឈានជើងមកធ្វើអាណាព្យាបាលនៅកម្ពុជា ។

www.budinst.gov.kh www.elibraryofcambodia.org



២- បកស្រាយ

វត្តមានបារាំងលើប្រទេសកម្ពុជា គឺគ្មានអ្វីក្រៅពីមានបំនងទាញយកផលប្រយោជន៍ពីកម្ពុជា ដើម្បីអភិវឌ្ឍន៍មនោគមវិជ្ជា សេដ្ឋកិច្ចអំនាចរបស់ខ្លួនឡើយ ។ ស្ថិតក្នុងវត្តបំនងនេះ សំរាប់កម្ពុជាបារាំង អនុវត្តជាដំបូងនូវនយោបាយហួតសិទ្ធិអំណាចពីកម្ពុជា ។ ពោលគឺបានរៀបចំក្បាលម៉ាស៊ីនដឹកនាំពីថ្នាក់កំពូលដល់ថ្នាក់ក្រោមជំនួសខ្មែរយើង ។ យ៉ាងណាមិញទូទាំងប្រទេសមានបុគ្គលិងជាអ្នកកាន់ការ ។ គេមានសិទ្ធិបញ្ជាកាន់តាប់ផ្នែក សំខាន់ៗនៅក្នុងប្រទេស រួមមានកងទ័ពរដ្ឋបាល ទំនាក់ទំនងក្នុងក្រៅប្រទេសជាដើម ។ តាមមូលដ្ឋានខេត្តស្រុក ក៏បានគ្រប់គ្រងដោយបារាំង ។ ករណីមួចជានៅកំពង់ឆ្នាំងមានបាដេសជាអ្នកគ្រប់គ្រង ។ តាមរយៈនយោបាយនេះ ហើយដែលបារាំងអាចបង្កព្យុះភ្លៀងតាម ចិត្តចង់លើប្រជារាស្ត្រខ្មែរគ្រប់ច្រកល្ហក ។

ទន្ទឹមនឹងនេះបារាំងបានប្រើនយោបាយមួយទៀតគឺ ការបញ្ចូលវប្បធម៌របស់គេអោយគ្របដណ្តប់វប្បធម៌ខ្មែរ ។ ក្នុងនោះគេបានយកភាសាគេប្រើជំនួសជាផ្លូវការជួសភាសាខ្មែរ ។ គេនាំចូលនូវសិល្បៈរបស់ជាតិគេមកប្រទាញសិល្បៈខ្មែរអោយស្រុតចុះ ។ ជាក់ស្តែងបារាំងបានយកការរាំរែកបែបសញ្ជាតិគេមក បង្ហាញនាពេលដែលសំដែងអបអរជោគជ័យគេនៅក្រុងភ្នំពេញ ។ ហេតុអ្វីបានជា ប្រើនយោបាយបែបនេះ ? ។ បារាំងបានយល់យ៉ាងច្បាស់លាស់ថា « វប្បធម៌ជាតិ មួយរលត់ ជាតិនោះរលាយ » ។ មានន័យថាកាលណាជាតិមួយរលាយវប្បធម៌ ហើយនោះទាំងរាស្ត្រទាំងជាតិត្រូវបាត់បង់នូវអត្តសញ្ញាណជាតិ ។ ពេលបាត់បង់ ចំនុចនេះ ខ្មែរនឹងទន់ជ្រាយគ្មានមនសិការជាតិដែល ទីបំផុតទៅខ្មែរ នឹងរលាយឈ្មោះពីសកលលោក ។

www.budinst.gov.kh www.elibraryofcambodia.org

ជាធម្មតា បារាំងជាមហាអំនាចដូចនេះគេមានការយល់ដឹងជ្រៅជ្រះស្គាល់ពីម្រភពធន្លឹងស្ថិរភាពអំណាចរបស់ពួកគេ ។ ផ្តើមចេញពីសមត្ថភាពនេះហើយដែលបារាំងបានប្រើប្រាស់ក្នុងកម្ពុជា ដែលយើងចាត់បញ្ចូលថាជា «នយោបាយដ៏ពិសពុល»មួយផែរនោះ ។ នោះគឺការធ្វើប្រជាភិថុតិបន្លំភ្នែកបំភាន់ចិត្តខ្មែរអោយយល់ថា ពួកគេមានទស្សនៈខ្ពង់ខ្ពស់ បំរើជំនឿជាតិខ្មែរពិតៗ ។ ទង្វើរបស់គេនោះ គឺ គេរៀបចំពិធីបុណ្យរបៀបខ្មែរ ដោយនិមន្តព្រះសង្ឃ៥០០អង្គធ្វើ បុណ្យយ៉ាងគគ្រឹកគគ្រេង ។ នយោបាយនេះបានធ្វើអោយបារាំងទទួលបាននូវការ គាំទ្រយ៉ាងខ្លាំងពីមជ្ឈដ្ឋានប្រជារាស្ត្រ ។ ខ្មែរដែលពុំបានយល់ពីបញ្ហានេះជឿស្លុងថា បារាំងជាអ្នកមានជំនឿលើព្រះពុទ្ធសាសនាចេះធ្វើបុណ្យទានតាមប្រពៃណីខ្មែរ តាមពិតនេះគ្រាន់តែជាល្បិច «ខ្មោចដ៏រីសារស្លាប់យកចង្កេះបាំង » តែប៉ុណ្ណោះខ្មែរដែលបានស្គាល់ពីសារជាតិពិតរបស់បារាំង នាពេលនោះគឺ គេបានថ្កោលទោសរិះគន់ត្រង់ៗទៅអ្នកដឹកនាំបារាំងដោយចាត់ទុកថា បារាំងបានយកព្រះពុទ្ធ សាសនាជាឡប់ខ្មែ ដើម្បីទាញយកផលប្រយោជន៍ខ្លួនតែម្យ៉ាងគត់ ។

ក្រៅពីនេះទៀត បារាំងបានប្រើវិធានការហិង្សាប្រព្រឹត្តអំពើអមនុស្សធម៌បង្កើតភាពអយុត្តិធម៌ ប្រាសចាកទាំងស្រុងទៅច្បាប់សិទ្ធិមនុស្ស ។ រូបភាពបែបនេះគឺត្រូវបានបង្ហាញយ៉ាងច្បាស់ត្រឡែកថា បាដេសដែលរ៉ស៊ីដង់ប្រចាំខេត្តកំពង់ធ្នាំង គេបានដាក់បញ្ជាអោយកាប់សំលាប់ខ្មែរ ដែលពុំគោរពតាមបំនងគេ ដាក់គុក ច្រវាក់ វាយដំធ្វើ ទារុណកម្ម ដូចសត្វតិរច្ឆាន ។ បាដេសពុំបានទទួលស្គាល់ទុក្ខវេទនាខ្មែរកើតពីទុរភិក្ស ពីការប្រកបរបរអាជីវកម្មពុំមានភាពជឿនលឿនឡើយ ។ គេគិតតែពីតំរូវអោយបង់ពន្ធដល់គេអោយខាងតែបានដើម្បី បំពេញដល់កិច្ច អភិវឌ្ឍន៍នៅប្រទេសបារាំង ។ ដូចដែល

www.budinst.gov.kh www.elibraryofcambodia.org

សំដីនាងនី បញ្ជាក់ថា «លោកធ្វើ ចៅហ្វាយលើខ្មែរ លោកយល់ឃើញត្រឹម តែប្រាក់ប៉ុណ្ណោះ ចង់ខ្មែរ ធ្វើស្រែមិនបាន ចង់ខ្មែរដាច់ពោះស្លាប់លោកអត់ឈឺក្បាលទេ លោកគិតពីសង្កើញទារពន្ធអោយបាន ។ នេះឬដែលហៅថា អ្នកអាណាព្យាបាលនោះ ?» ។ ឯនាងប៊ីក៏បានបក អាក្រាតថា «យើស ! លោកបារាំង លោកឯងអាងសាសន៍ លោកត្រួតត្រាលើក្បាលខ្មែរ លោកចង់ជាន់ឈ្លីលើខ្មែរថ្មើរម៉ានបានថ្មើរនោះ ! តើលោកទុកខ្មែរជាមនុស្សម្នាដូចលោកដែរឬទេ ? ឬមួយខ្មែរជាសំរាមមិនស្មើនឹងបាតជើងរបស់ លោកនោះ ? » ។ សំដីប៉ុណ្ណោះជាភស្តុតាងត្រប់ត្រាន់ល្មម ពីនយោបាយដ៏ឃោរឃៅរបស់បារាំងសំរាប់ពលរដ្ឋខ្មែរ ។

នយោបាយដ៏មហាពិសពុលមួយបែបទៀត របស់បារាំងដែលយើងបានដឹងតាមរយៈរឿងភូមិតិរច្ឆាណនោះ គឺការ «ខ្ចីដៃខ្មែរអោយសំលាប់ខ្មែរ » ឬក៏អាចនិយាយថា «ការបំបែកបំបាក់កំលាំងសាមគ្គីរវាងខ្មែរនឹងខ្មែរ » ។ ជាសក្ខីភាពដូច យើងបានឃើញស្រាប់តែ បារាំងបានផ្តល់នូវបុណ្យសក្តិ ជះទឹកលុយទៅលើខ្មែរ មួយចំនួនដែលគេអាចដឹងថា ពួកនោះអាចបំរើមហិច្ឆតាពួកគេបានធ្វើសកម្មភាពផ្តាល់ចំពោះខ្មែរ ។ ក្នុងនោះមានចីសួន កងរក្សាស្រុកខ្មែរនិងកងការពារបារាំងជាច្រើននាក់ទៀត ។ វិធានការបែបនេះជំរុញអោយខ្មែរមានគំនិតអទិភាពនឹងគ្នាយកគ្នាជាសត្រូវ ។ យ៉ាងណាមិញសំដីរបស់បាតុករភូមិក្រាំងលាវបានបាញ់ព្រួញឆ្ពោះទៅរកចីសួន ដោយកំហឹងថា « ហ៊ឺ ! លោកចី ចៃបារាំងលោកឯងប៉ិនបកប្រែណាស់ ចេះយកគាប់គួរចៅហ្វាយនាយអោយលោតកញ្ឆេង សង្កត់សង្កិនខ្មែរគ្នាឯង » ។ និយាយបែបនេះពុំមែនយើងគាំទ្រខ្មែរចៃបារាំងនោះទេប៉ុន្តែយើង ក៏អាចពិចារណារកឃើញនូវមូលគល់បានថាទាំងអស់នេះកើតពីល្បិចរបស់បារាំងដ៏អាក្រក់បានឡើយ។

www.budinst.gov.kh www.elibraryofcambodia.org

ចុងក្រោយនេះយើង ក៏មើលឃើញថាបារាំងបានអនុវត្តនូវវិធានការបំបាក់ស្មារតីតស៊ូរបស់ខ្មែរកុំអោយមានគំនិតប្រឆាំង នឹងពួកគេទៅថ្ងៃមុខទៀត ។ ជាក់ស្តែង គឺ ក្រោយពីការស្លាប់របស់បាដេសរួចមកវ៉េស៊ីដង់ស៊ុបបើរីយើរ បានចេញបញ្ជាចាប់បញ្ជូនមេដឹកនាំការបះបោរខ្មែរមាន នៅ ជួន ប៊ិន ប៉ាង ម៉ៅ ពត ទៅដាក់គុកនៅកោះត្រឡាច ។ បាតុករដែលចូលរួមតស៊ូត្រូវទទួលរងនូវការ បាញ់រះសំលាប់ចោលដូចសត្វតិរច្ឆាន ។ ជាពិសេស ភូមិក្រាំងលាវត្រូវបានបារាំងអោយប្តូរឈ្មោះថា «ភូមិតិរច្ឆាន» ព្រមទាំងពិន័យយ៉ាងធ្ងន់ធ្ងរដល់អ្នកស្រុក ទាំងនោះចេញប្រាក់កាក់ធ្វើបុណ្យទាន ដើម្បីលុបលាងទោសដែលខ្លួនបានធ្វើចំពោះបាដេសចិត្តខ្មៅបូស្យថែមទៀតផង ។ អំពើនេះគឺបារាំងគេមានបំណងចង់ព្រមានខ្មែរក្រោយៗកុំអោយធ្វើដូចអ្នកភូមិក្រាំងលាវទៀត ទោះបីថាអំពើដែលខ្លួន ធ្វើនោះត្រឹមត្រូវក្តី មិនត្រូវតវ៉ាប្រឆាំងទេ ។ បើនរណាហ៊ានប្រឆាំងគេគឺមិនខុស ពី «យកពងមាន់ទៅជល់នឹងថ្ម» ពោលគឺគេនឹងសំលាប់ចោលដូចអ្នកស្រុកក្រាំង លាវជាគំរូស្រាប់ ។

៣- <u>សរុបការពន្យល់</u>

រួមមកនយោបាយពិសពុលរបស់បារាំង ដែលរឿងភូមិតិរច្ឆានបានបង្ហាញយើងដែលរួមមាននយោបាយ ត្រជាក់តែស៊ីជំរៅ គួរអោយស្អប់ខ្ពើមនិងនយោបាយក្តៅគួរអោយយើងឈឺចាប់គ្មានថ្ងៃបំភ្លេចបាន ។ គេប្រើអំនាចត្រួតត្រាយកវប្បធម៌គេមកផ្សព្វផ្សាយយកខ្មែរអោយសំលាប់ជាតិខ្មែរ ។គេសងសឹកដោយកំហែលគ្មានពិចារណា ធ្វើយ៉ាងណាអោយតែគេបានថ្កើង ។

III-<u>យោបល់បញ្ចប់</u>

ផ្អែកទៅលើការវិភាគទៅនេះយើងអាចវាយតំលៃបានថា ទស្សនៈ

www.budhist.gov.kh www.elibraryofcambodia.org

ប្រធានពិតជាមានខ្លឹមសារដ៏ជ្រាលជ្រៅក្រៃលែង ។ ដោយសារទស្សនៈប្រធាន នេះផ្តល់ការយល់ដឹងមួយផ្នែកធំ ស្តីពីឧបាយកលខ្មៅក្រខ្វក់ របស់ពួកបរទេស ប្រព្រឹត្តកន្លងតាមរយៈរឿងភូមិតិរច្ឆាន ដែលជាហេតុធ្វើអោយយើងមានស្មារតី ប្រុងប្រយ័ត្នកុំអោយលង់ខ្លួនទៅតាម ឧបាយកលទាំងនោះ តទៅថ្ងៃមុខទៀត។ ជួចនេះក្តុង នាទីជាខ្មែរត្រូវតែប្រកាន់ជំហរវីរបុរិង ស្នេហាជាតិ មាតុភូមិកុំមានទស្សនៈថា អំពើដែលបរទេស ធ្វើមកលើសុទ្ធតែល្អដោយបំភ្លេចចោលអ្វីដែលជាស្មាដៃខ្លួននិងត្រូវ ពង្រឹងតំនិតធ្វើជាម្ចាស់ប្រទេសអោយបានដោយខ្លួនឯង នោះទើបជាតិបានចំរើន។

www.budinst.gov.kh www.elibraryofcambodia.org

ប្រធានទី៧ : «អក្សរសិល្ប៍ថ្នាក់ទី ១២ ជាឯកសារពិគ្រោះដ៏សំខាន់សំរាប់អោយអ្នកសិក្សាស្រាវជ្រាវរកនូវវឌ្ឍនភាព ។ ចូរបង្ហាញ ។

គំរោងតែង

១- ពន្យល់ពាក្យ

ឯកសារពិគ្រោះ = កំរងអត្ថបទ - លិខិតផ្តល់ជំនួយ- ផ្តល់មតិយោបល់ល្អ។ មានតំលៃ

វឌ្ឍនភាព = ភាពរីកចំរើន, ភាពល្អតលាស់

២- បកស្រាយ

ក- រឿងភូមិតិរច្ឆាន

- វិបត្តិស្រុកខ្មែរ ដោយគ្មានឯករាជ្យ → ផណ្តើមឯករាជ្យ

- កង្វះឧត្តម គតិជាតិលក់ខ្លួនបំរើសត្រូវជាតិវិនាស → កែខ្លួន

- ផលវិបាកអាក្រក់នៃការតស៊ូ → កុំតក់ក្រហល់ - ឯកភាពស្គាល់ពីស្ថានការណ៍ទូទៅច្បាស់លាស់ ។

ខ- រឿងតូលីកំនែន

- វិនាសកម្មកើតពីជំនឿ → កែច្នៃជំនឿទាញយកប្រយោជន៍

- សង្គ្រាមនាំជាតិតូចតាចវិនាស → អោយប្រទេសផុតពីមូលដ្ឋានបរទេស

- ជោគជ័យនៃជីវិត → ស្គាល់ក្រឹត្យក្រមសង្គម

គ- រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់

- រាស្ត្រវេទនា កើតពីការគិតពុំដល់ → ថ្លឹងថ្លែងមុននឹងសំរេចធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

- ភាពអយុត្តិធម៌សង្គមជាតិរីករាល → បំបាត់ចោយអោយអស់

- សម័យសង្គមរាស្ត្រនិយមជាតិចំរើន → អភិវឌ្ឍន៍ជនបទទីក្រុង

ឃ- រឿងចៅកែចិត្តចោរ

- អន្ទាក់មូលធនពិសពុលធ្វើអោយវិបត្តិសង្គមកើតឡើង→ កុំចាញ់បោកមូលធនរំដោះខ្លួនពីគំនាបសង្គម ។

អត្ថបទអក្សរសិល្ប៍ថ្នាក់ទី ១២

I-សេចក្តីផ្តើម

អក្សរសិល្ប៍ថ្នាក់ទី ១២ ត្រូវបានក្លាយជាប្រទីបបំភ្លឺ អោយអ្នកដែលបានសិក្សាស្វែងយល់រឿងទាំងនោះ យល់ផ្ទុះឆ្លាយរាល់អាថិកំបាំង នៃអតីតកាលរបស់ប្រទេសកម្ពុជា ក្រោមក្រលាំដែ ពួកអាណានិគមនិយមចាស់ថ្មីនិងអំណាច ទីកន្ត្រាក់ដែលសាបព្រោះឡើងពីស្មាដៃវណ្ណៈមូលធន ។ ពតិមានទាំងនេះជាវត្ថុ ដែលតំរូវអោយទស្សនៈមួយអាចកំនត់ថា«អក្សរសិល្ប៍ថ្នាក់ទី១២ជាឯកសារ ពិក្រោះដ៏សំខាន់សំរាប់អោយអ្នកសិក្សាស្រាវជ្រាវរកផ្លូវវឌ្ឍនភាព» ។ តើចំនុច ត្រង់ណាខ្លះ ដែលបញ្ជាក់ថា អក្សរសិល្ប៍ថ្នាក់ទី១២ ជាអក្សរសិល្ប៍មានិលក្ខណៈបែបនេះ ?

II-ខ្លួនសេចក្តី

១- ពាក្យពាក្យ

ធម្មតាមនុស្សយើងពុំអាចយល់ដឹងបានគ្រប់សព្វដោយខ្លួនឯងនោះទេ។ បុគ្គលម្នាក់ប្រាថ្នាត្រូវពឹងផ្អែកនូវកំរងអត្ថបទសៀវភៅក្នុងខ្លាតសៀវភៅអក្សរ-

www.budinst.gov.kh www.elibraryofcambodia.org

សិល្បៈដើម្បីជាជំនួយដល់ការយល់ពីអត្ថន័យនៃបញ្ហាស្នារតី នៅតាមតំនាក់កាលៈទីមួយៗ នៃសង្គមមនុស្ស ។ អ្វីៗទាំងនោះហើយដែលហៅថា «ឯកសារពិត្រោះ»។ រីឯពាក្យពាក្យ «វឌ្ឍនភាព» ចង់សំដៅលើភាពរីកចំរើនភាពរុងរឿងនោះឯង ។ តាមរយៈ ពាក្យទាំងពីរនេះយើងអាចនិទស្សន៍ពីនិតប្រធាននេះដោយខ្លីបានថា អក្សរសិល្ប៍ ថ្នាក់ទី ១២ ជាកំរងអត្ថបទដ៏ពិសេសមានប្រយោជន៍សំរាប់ធ្វើអោយអ្នកសិក្សាទូទៅរកឃើញនូវវិធីថ្មី មធ្យោបាយថ្មីល្អៗដើម្បីភាពរីចំរើនដល់ខ្លួននិងជាតិមាតុភូមិខ្លួន ។

២- <u>បកស្រាយ</u>

ភាពវិជ្ជមានចិត្ត ផ្តិតជាប់ក្នុងរឿងភូមិតិរច្ចានដែលធ្វើអោយអ្នកសិក្សាទាំងឡាយក្តុកក្តួលអួលអាក់ ឈឺចាប់ជំនួសនោះ គឺទុក្ខវេទនា របស់ប្រជារាស្ត្រខ្មែរទូទាំងប្រទេស ក្នុងនោះប្រជារាស្ត្រខ្មែរ ភូមិក្រាំងលាវជាតំនាង ។ បើពិនិត្យទៅលើបញ្ហានេះអាចកំនត់ថា គឺផ្តើមចេញពីប្រទេសខ្មែរ ត្រូវបាត់បង់ទូវឯករាជ្យ ។ បានសេចក្តីថា ប្រទេសខ្មែរត្រូវចិតនៅក្រោមនឹមត្រួតត្រារបស់បារាំង ។ ការលើកយ៉ាងនេះរបស់អ្នកនិពន្ធ ជំរុញអោយអ្នកសិក្សាមើយឃើញពីតំលៃនៃ «ឯករាជ្យជាតិ» ។ ឯករាជ្យជាកត្តាធ្វើអោយជាតិល្អតលាស់។ តំហរិញ្ញវែបនេះក៏បាន ចារឹកជ្រាប់អោយឃើញស្រាប់នៅក្នុងរឿង គឺខ្មែរស្នេហាជាតិ នៅក្រាំងលាវមានទៅ ជួនជាដើម ។ ពួកគេហ៊ានបូជាអ្វីៗទាំងអស់ដើម្បីដណ្តើមអំណាច់ ពីបារាំងមកកាន់កាប់ក្នុងដែវិញ ដោយសំលាប់បាវេសអេជិះជាន់ខ្មែរ ។ ដូចនេះការសំរេចចិត្តរបស់ពួកគេផ្តោតទៅលើឯករាជ្យ ។ បើខ្មែរអានឯករាជ្យហើយខ្មែរ នឹងបានសុខ ជាតិនឹងសប្បាយរុងរឿងជាក់ជាពុំខាន ។

www.budinst.gov.kh www.elibraryofcambodia.org

អបជាមួយនេះដែរ រឿងចង់អោយអ្នកសិក្សាពិចារណាទៅលើបួរ ហេតុអ្វីដែលនាំអោយបារាំង ធ្វើបាបខ្មែរ បានបារាំងអាចពង្រីកឥទ្ធិពលខ្លួនលើខ្មែរបាន លើតែជាជនអរទេស ពុំកើតលើដីខ្មែរផងនោះ ? ។ ចំលើយនៃសំនួរនេះគឺ អ្នកនិពន្ធខ្មែក អំ និង ឌឹក តាមបានបញ្ជាក់អោយយើញថា វាអាស្រ័យពីខ្មែរកង្វះនូវឧត្តមគតិ លក់ខ្លួនបំរើបរទេស ហើយធ្វើលើសបរទេសបញ្ជាទៀត ដើម្បីរក្សាកិត្តិយសនិង ពំនែងខ្លួនដែលលើកបន្ទុបដោយបារាំង ។ នេះគឺសមរឹងពាក្យចាស់បូរាណខ្មែរ មួយឃ្លាលើកឡើងថា «ខ្មោចស្រុកអោយដែរទើបខ្មាចព្រៃចូលស្រុកបាន » ។ ជននោះគឺយើងបានស្គាល់ច្បាស់មានចីស្ងួនជាអាទិ៍ ។ បើដូចនេះ វឌ្ឍនភាពនៃប្រទេសក្រៅពីឯករាជ្យខ្មែរចាំបាច់ត្រូវប្រកាន់ជំហរ ស្រលាញ់ជាតិអោយបានខ្ពស់កុំលក់ឧត្តមគតិបំរើនយោបាយបរទេសអោយមកបំផ្លិចបំផ្លាញជាតិឯងអោយសោះ ។

ចំនុចមួយទៀតចាត់បញ្ចូលជាឯកសារពិគ្រោះសំរាប់ អ្នកសិក្សាដែរនោះគឺទាក់ទងទៅនឹងបញ្ហាតស៊ូរំដោះជាតិ ។ ទង្វើរបស់ប្រជារាស្ត្រក្រាំងលាវរួមនឹងរាស្ត្រខ្មែរព្រៃខ្មែរធ្វើ នៅលើបារាំងជាការសមស្របហើយ ។ ប៉ុន្តែគួរតែមានទស្សនៈថា «សំលាប់បនុស្សពុំមែនជាបញ្ហាសំលាប់របបនយោបាយមួយអោយដួលរលំទាំងស្រុងនោះទេ » ។ បើចង់សំរេចលុះត្រាតែផ្តាច់ប្រព័ន្ធំរបស់របប ឬអាណានិគមនិយមនោះអោយអស់ ។ គឺចង់និយាយថាយើងត្រូវគិតទៅលើផល វិបាកដែលកើតមានក្រោយពីទង្វើខ្លួនតើអាចមានសុវត្ថិភាពដល់ខ្លួននិងជាតិឬទេ ? ដូចនេះជាកតិដល់អ្នកសិក្សារឿងក្រាប់ថាគួរធ្វើអ្វីកុំតក់ក្រហល់ត្រូវពិនិត្យមើលក្រាប់ជ្រុងនៃបញ្ហា ទើបធានាបាននូវជោគជ័យជាស្ថាពរ ។

www.budinst.gov.kh www.elibraryofcambodia.org

ងាកមកមើលក្នុងរឿង **គូលីកាំនែន** វិញម្តង ។ លោកអ៊ីមថុក បានប្រើសិល្បវិធីមួយ ដោយអោយតួអង្គតាង៉ែត យាយម៉ុក ដែលជាអ្នកប្រតិបត្តិឥតឈ្លើងឈ្លាតទៅតាមឱវាទសាសនាថា «វេទនាមកពីកម្មពៀ» ត្រូវស្លាប់ដោយសារគ្រាប់បែក ចក្រពត្តិក្រោមទីសក្ការបូជានៅមុខវត្តឧណ្ណាលោម ។ សិល្បវិធីនេះទុកជា កម្មវត្ថុសំរាប់អោយអ្នកសិក្សាឃើញថា «ទុក្ខវេទនាខ្មែរមកពីអាណា និគមនិយម និងចក្រពត្តិ » ។ ពួកនោះពុំដែលផ្តល់ឱកាសដល់អ្នកដែលល្អត្រឹមត្រូវស្លូតត្រង់ដូចតាង៉ែត យាយម៉ុកម្តងឡើយ ។ បំរាប់បញ្ហាបែបនេះគឺអ្នក និពន្ធចង់តួសបញ្ជាក់ថា «សំរាប់ចក្រពត្តិអាណានិគមមិនត្រូវទន់ជ្រាយឱនក្បាលសុំសុខទេ មានតែការតស៊ូវាយបណ្តេញពួកគេទេទើបគេអាចប្រគល់សេចក្តីសុខ សុភមង្គលអោយយើង » ។ យ៉ាងណាមិញ លីម ម៊ឹង នួដួង ដែលយល់ពីបញ្ហា នេះគេ សំរេចយកការតស៊ូ ជាមូលដ្ឋាន ។ ចុងបំផុតភាពសុខដុមរមនាបានធ្លាក់ មកលើដៃគេដូចបំនង ។

ជានួទៅមិនថា ជាតិណាដូចជាតិណាទេ ។ បើជាតិនោះស្គាល់តែពីសង្គ្រាមជាតិនោះតែងតែជួបនូវមហន្តរាយ ។ ក្នុងន័យនេះយើងសំឡឹងឃើញនៅក្នុងរឿងគូលីកំនែនបារាំង ជប៉ុន អាមេរិក បានប្រជែងគ្នាយកកម្មជាធ្វើជាមូលដ្ឋានសឹកដើម្បីឈ្នានពានលើប្រទេសដទៃ ។ អ្នកដែលរងគ្រោះគឺម្ចាស់ប្រទេស ។ ភាពមហន្តរាយនេះបានបំភ្លឺអោយ អ្នកសិក្សាថ្លឹងថ្លែង អោយឃើញទៅអនាគតត្រូវធ្វើយ៉ាងណាអោយជាតិចៀសផុតពីប្រការដូចបង្ហាញខាងលើ ទើបជាតិមានពន្លឺរស្មីដូចអរិយប្រទេស ។

ចំនែកឯរឿងព្រះអាទិត្យថ្មីរះលើដែនដីចាស់ ក៏បានផ្តល់ជាយោបល់ថ្មីប្លែកៗក្នុងការ ជ្រើសរើសតំនាងរាស្ត្រ ។ តំនាងរាស្ត្រជាអាយុជីវិតនៃរាស្ត្រ

www.budinst.gov.kh www.elibraryofcambodia.org

រើសមនុស្សខុសនឹងត្រូវរងទុក្ខវេទនា គ្មានទីបញ្ចប់ ។ ម្ចាស់ឆ្មោតនឹងមានវិប្បដិសារី តែស្រដីពុំចេញបាន ។ ករណីជូចលោកយើងដែលអ្នកនិពន្ធកំនត់ថាជា «អ្នកនយោបាយចោកប្រាស់ » គេបានជាន់ឈ្លីមើលងាយសមរៀលគួរសមយ៉ាងធ្ងន់ធ្ងរ ។ គេបានទំលាក់កំហុសលើក្រុមសម ដោយនិយាយថា «គេមានបំផុសអោយ ក្រុមសមបោះឆ្នោតអោយគេឯណា ។ គេពុំទទួលយកសំនើសង្រ្គោះពីសមឡើយ»។ ប៉ុណ្ណោះអ្នកសិក្សាគួរតែយល់ហើយចងចាំទុកជាមេរៀនប្រចាំខ្លួនដើម្បីកុំអោយមានរឿងអាស្រូវបែបនេះកើតឡើងនាពេលខាងមុខ ។ ក្រៅពីនេះរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ ដដែលជាឯកសារមួយស្តែងពីភាពវឹកវរក្នុង សង្គមដែលកើតឡើងពីអំពើអយុត្តិធម៌ ។មន្ត្រីពុករលួយអាជ្ញាធរប៉ូលីសមិនប្រកាន់យុត្តិធម៌ធ្វើបាបអ្នកស្លូតត្រង់កាន់ជើងអ្នកមានប្រាក់ ។ អីចឹងទេសំរាប់ជាតិរុងរឿងចាំបាច់ត្រូវបោសសំអាតអោយអស់នូវស្ថានភាពបែបនេះ ដោយឈរលើទស្សនៈ «បើមិនជួយចែវចូកកុំយកជើងរាទឹក »ជាធំ ។

និយាយពីរឿង ថៅកែចិត្តចោរឯណោះវិញ ។ បញ្ហាថ្មីដែលធ្វើអោយយើងដែលជាអ្នកសិក្សានាំគ្នាស្រាវជ្រាវរកនូវការពិតនៃការរងទារុណកម្មរបស់ពូហាំនោះកកើតឡើងពីការចាញ់ប្រៀបអន្ទាក់ នាយទុនដែលបានរាយប្រទាក់ចាប់យកមនុស្សដូចពូហាំអោយលង់ខ្លួនដកចេញពុំរួច ។ ជាតិកតាងគីក្រោយពីពូហាំធ្វើការអោយខ្លួនបានដោយជោគជ័យគេបែរជារលាស់ គេចយករួចខ្លួន ។ ពេលទាល់ច្រកគេងាកមកខាំត្របាក់ពូហាំ ឥតត្រាប្រណី ។ បទពិសោធន៍នេះជាគន្លឹះដល់អ្នកសិក្សាអោយដឹងថា ម្នាក់ៗ មិនត្រូវចាញ់បោកនាយទុនទេ ។ ពួកនោះមិនខុសពីផ្លែល្វា ដែលល្អតែក្រៅ ឯខាងក្នុងស្អុយរលួយយកជាការពុំបានឡើយ ។

www.buddhist.gov.kh www.elibraryofcambodia.org

៣- សរុបការពន្យល់

រួមមកអក្សរសិល្ប៍ថ្នាក់ទី ១២ បានរំលឹកអ្នកអានអោយដឹងច្បាស់ពី ផ្លូវដើរឆ្ពោះរកវឌ្ឍនភាព គឺចាំបាច់ត្រូវធ្វើអោយប្រទេសមានឯករាជ្យកុំលក់ខ្លួន បំរើប្រយោជន៍បរទេសធ្វើការងារអ្វី ត្រូវពិនិត្យពិចិ័យអោយបានល្អិតល្អន់ បញ្ចៀសជាតិពីសង្គ្រាមបំបាត់អាយុត្តិធម៌សង្គម ។ ចំនុចទាំងអស់នេះហើយគឺជាឯកសារពិគ្រោះដែលអ្នកនិពន្ធរឿងថ្នាក់ទី១២បានបង្កប់ក្នុងរឿងរបស់លោកនោះ

III-យោបល់បញ្ចប់

យោលតាមសេចក្តីដូចបានបកស្រាយរួចមកហើយនេះ យើងអាចវាយតំលៃបានថាអក្សរសិល្ប៍ថ្នាក់ទី ១២ ពិតជាបានធ្វើអោយអ្នកអានរាវរកផ្លូវដើរ សំរាប់ធ្វើអោយជាតិនិងខ្លួនមានវឌ្ឍនភាពពិត ។ ។ ដោយសាររឿងទាំងនេះបាន ធ្លុះកកាយ នូវចំនុចជាច្រើនប្រគល់ដល់អ្នកសិក្សាអោយមានលទ្ធភាពគ្រប់គ្រាន់គួរជ្រើសរើសយកមធ្យោបាយណាមួយ ដែលអាចធានាកិត្តិយសជូនជាតិនិងធ្វើអោយខ្លួនជុតពីគ្រោះថ្នាក់ ។ ដូចនេះគួរតែអ្នកសិក្សាគ្រប់រូបយកនូវគំនិតខាងលើ នៅអនុវត្តអោយបានល្អ ប្រសើរនោះអ្នកនឹងមានឈ្មោះថាកុលបុត្រដ៏ឆ្នើមប្រចាំប្រទេសជាពុំខាន ។

មានលក់ជុំនិងលក់រាយនូវសៀវភៅអាន

គ្រប់មុខវិជ្ជា រឿងរូបភាព ចំរៀង KARAOKE

១_តូបលេខ ៧៥ ផ្សារអូឬស្សី

ទូរស័ព្ទដៃលេខ: ០១៨ ៨១៤ ២២៥

២_តូបលេខ ៦៨ ផ្សារធំថ្មី

ទូរស័ព្ទដៃលេខ: ០១៨ ៨១៥ ៦៩៣

សូមអរគុណ !

www.budinst.gov.kh www.elibraryofcambodia.org

ប្រធានទី៨: «កិត្តិយសនិងភាពថ្លៃថ្នូរជាវត្ថុដែលមនុស្សម្នាក់ៗចង់បាន»។ តើក្នុងអក្សរសិល្ប៍ថ្នាក់ទី ១២ បាននែនាំធ្វើដូចម្តេចខ្លះដើម្បីទទួលបាននូវវត្ថុទាំងពីរយ៉ាងនេះ ?

គំរោងតែង

១- ពន្យល់ពាក្យ

កិត្តិយស = កេរ្តិ៍ឈ្មោះដ៏រុងរឿង

ភាពថ្លៃថ្នូរ = ភាពមានតំលៃ, ភាពខ្ពង់ខ្ពស់

២- បកស្រាយ

ក- រឿងភូមិតិរច្ឆាន នែនាំមនុស្ស

- ហ៊ានពលី ជីវិតដើម្បីមាតុភូមិ
- ប្រឈមមុខភាពអយុត្តិធម៌

ខ- រឿងគូលីកំនែន នែនាំ

- ភក្តីភាព មិនឈ្លក់វង្វេងអំនាច
- ការពារយុត្តិធម៌ប្រែក្លាយកំហឹងជាធន្ទះប្រយុទ្ធ

គ- រឿងចៅកែចិត្តចោរ

- រ៉ាប់រងនូវភិបត្តិគ្រួសារ
- ហ៊ានលះបង់អ្វីៗទាំងអស់ដើម្បីវែកមុខជនក្រឡិចក្រឡុច

ឃ- រឿងព្រះអាទិត្យថ្ងៃរះលើផែនដីចាស់

- ជួយគ្នាពេលមានអាសន្ន
- ទទួលកំហុសដែលខ្លួនបានធ្វើ
- មិនក្បត់ឧត្តមគតិ ក្បត់ខ្លួនឯង

www.budinst.gov.kh www.elibraryofcambodia.org

- តស៊ូក្នុងជីវិត

ផែនចង្កើតអធិប្បាយ

I-សេចក្តីផ្តើម

មនុស្សក្នុងលោកតែងតែរិះរកគ្រប់រូបភាពដើម្បីញុំងជីវិតរបស់ខ្លួន អោយទទួលបាននូវការគោរពការសរសើរពីមជ្ឈដ្ឋានមនុស្ស ដូចៗគ្នា។និយាយ អោយចំគឺ «កិត្តិយសនិងភាពថ្លៃថ្នូរ» នោះឯង» ។ តើកិត្តិយសនិងភាពថ្លៃថ្នូរ បានដោយរបៀបណា ? តើក្នុងអក្សរសិល្ប៍ខ្មែរថ្នាក់ទី ១២ បានខែនាំដូច ម្តេចខ្លះដើម្បីអោយទទួលបាននូវវត្ថុទាំងពីរយ៉ាងនេះ ?

II-តួសេចក្តី

១-ពន្យល់ពាក្យ

ប្រការដែលមនុស្សទៅទីណាកន្លែងណាក៏ មានគេស្គាល់ឈ្មោះគេ រំលឹកឃើញឈ្មោះឥតភ្លេច គេចង់ជួបមុខ ។ នោះហើយហៅថា «កិត្តិយស» ។ ចំពោះ «ភាពថ្លៃថ្នូរ» ចង់ដៅទៅលើភាពមានតំលៃ ភាពខ្ពង់ខ្ពស់ឧត្តុង្គឧត្តម គ្រប់ពេលវេលាទោះបីរស់ក៏ដូចជាស្លាប់ក៏ចិតក្នុងភាព មួយដ៏សមរម្យបំផុត ។ យោលលើ អត្ថន័យពាក្យទាំងពីរដូចបានបញ្ជាក់ដោយខ្លីនេះ ទស្សនៈប្រធាន ចង់អោយប្រមូល ផ្តុំនូវចំនែកផ្សេងៗចេញពីក្នុងវណ្ណកម្មអ្នកនិពន្ធខ្មែរ អក្សរសិល្ប៍ថ្នាក់ទី ១២ ដែល លោកមានបំនងទូន្មាន បង្ហាញផ្លូវសំរាប់អោយ យើងទទួលបាននូវកេរ្តិ៍ឈ្មោះដ៏ រុងរឿងនិងមានតំលៃពុំអាចកាត់ថ្លៃបាននោះ។

២-បកស្រាយ

ទស្សនៈរបស់មនុស្សមួយចំនួនតែងកំនត់ដោយឥតខ្វាចរអែងថាទ្រព្យ

www.budinst.gov.kh www.elibraryofcambodia.org

នេះមួយវានឹងធ្វើអោយមនុស្សលេចឈ្មោះត្រដែតនិងធ្វើខ្លួនគេមានឥស្សរភាព គ្រប់កាលៈទេសៈទាំងអស់ ។ ប៉ុន្តែមិនដូចនោះទេ ភាពល្បីឈ្មោះនិងភាពខ្ពង់ខ្ពស់បែបនេះមិនអស្ចារ្យ មិនល្បីរន្ទឺ ដែលធ្វើអោយស្ថិរភាពយូរអង្វែងនោះទេ ។ គឺវាអាចរលុបបាត់បន្តិចម្តង ។ នាតំនាក់កាលមួយពុំខាន ។ ពិសេសគឺនៅពេលដែលអ្នកនោះបានលាចាកលោកនេះទៅ ។

បើយើងប្រៀបបញ្ហានេះទៅនឹងកវីប្រជាប្រិយ៍ខ្មែរមួយរូប នាមភិរម្យ ភាសាអ៊ូ ហៅង៉ុយ ។ យើងឃើញលោកជាគ្រួសកសិករក្រ គ្មានធនធានច្រើនចុះហេតុអ្វីក៏ឈ្មោះគាត់ ភាពថ្លៃថ្នូររបស់គាត់នៅតែរស់រវើកក្នុងសន្តានចិត្តកូនខ្មែរខ្លាំងម្ល៉េះ ? ។ វត្ថុទាំងពីរដែលកវីទទួលបានគឺគ្មានអ្វីក្រៅពីការទទួលបានពីមរតកប្រៀនប្រដៅប្រកបដោយគតិបណ្ឌិតសំរាប់ជំរុញអោយកូនខ្មែរដើរកផ្លូវល្អ ធ្វើអោយជាតិរស់ជានិច្ចលើសកលលោកយើងនេះទេ ។

មិនខុសពីនេះដែរអក្សរសិល្ប៍រឿងភូមិតិរច្ឆានក៏បានលើកឡើងរំលឹកដល់យើងថា ភាពល្បីឈ្មោះភាពថ្លៃថ្នូររបស់មនុស្ស អាស្រ័យលើមនុស្សហ៊ានពលីជីវិតដើម្បីមាតុភូមិហ៊ានប្រឈមមុខដណ្តើមយុត្តិធម៌ ជួនសង្គមមនុស្សទូទៅ ។ យ៉ាងណាមិញវីរភាពរបស់នៅជួន ប្រជារាស្ត្រភូមិក្រាំងលាវភូមិព្រៃខ្មែរដែល បូជាជីវិតបណ្តេញបារាំងតំរូវអោយបារាំង ប្រគល់មកជួនកម្ពុជានូវសិទ្ធិ សេរីភាពឯករាជ្យ បូរណភាពទឹកដី បានញុំងអោយពួកគេមានឈ្មោះបោះសំលេងមានឧត្តមភាពជិត ជាប់ជានិច្ចក្នុងក្រអៅបេះដូង ខ្មែរជាច្រើនឆ្នាំ។ ឈ្មោះគេត្រូវ បានចារឹកទុកក្នុងក្រាំងមាសនៃប្រវត្តិសាស្ត្រថា ជាវីរជនជាកុលបុត្រ ដ៏ឆ្នើម សំរាប់ជាតិ និង អរិយបុគ្គលដែលខ្មែរគ្រប់រូបជំនាន់ក្រោយធ្វើវន្ទនកិច្ចតរៀងមក ។

www.budinst.gov.kh www.elibraryofcambodia.org

ដោយឡែករឿងគូលីកំនែនបានផ្តល់ជាឱវាទលើបញ្ហានេះថា មនុស្ស
ចាំបាច់ត្រូវរក្សាអោយបាននូវភក្តីភាព មិនត្រូវមានគំនិតរៀចវេរទៅតាម
អំនាចទឹកប្រាក់បុណ្យសក្តិ សំភារៈអួសទាញនោះឡើយ ។ ករណីនាងហេង
ដែលជាគូដណ្តឹងលឹម នាងមិនលុះក្រោមឥទ្ធិពលសព្វបែបយ៉ាងរបស់
ចៅហ្វាយស្រុកនាងសុខចិត្តគេចខ្លួនតក្រុកតាមអនាគតឪពុកក្មេក ម្តាយក្មេក
រហូតស្លាប់បាត់បង់ ជីវិតដោយសារគ្រាប់បែកចក្រពត្តិ ។ មរណភាពនាង
ហេងពិតជាធ្វើអោយនារីខ្មែរ មានការក្តុកក្តួលរំជួយចិត្ត និងសំដែងនូវគារវ
កិច្ចរាប់សិបតំន ។ ព្រោះទង្វើ របស់នាងជាគតិភ្លឺស្វាងបំផុតដែលនារីខ្មែរទូទៅ
ធ្លាប់ប្រកាន់យកពីដើមរហូតដល់បច្ចុប្បន្ន ។ បន្ថែមពីលើនេះទៀតរឿងនៅ
បានចង្អុលអោយយើងទាញយកកិត្តិយស និងភាពថ្លៃថ្នូរមួយបែបនោះគឺការ
មិនចុះញ៉ែមការបំបាក់ធន្ទះតស៊ូ ការចេះប្រែក្លាយ កំហឹងឈឺចាប់ទៅការប្រយុទ្ធ
មុះមុតការពារជាតិអោយបានថ្កុំថ្កើង ។ តួយ៉ាងយើងឃើញ នូ ដួង ដែល
ធ្លាប់ជាប់គុក ដោយសារការបះបោរប្រឆាំងបារាំងក្រោយពីគេបានលួចរត់
គេចពីគុក គេនៅតែមិនបោះបង់ចោលគំនិតរើបំរះរំដោះ ជាតិ រំដោះប្រជា
រាស្ត្រពីកណ្តាប់ដៃបារាំងឡើយ ។ គេបានតស៊ូសាជាថ្មី ដោយថែមទាំងអួស
ទាញមុឺងជាបួនបង្កើតលឹម ដែលមានគំនិតដូចខ្លួន ចូលព្រៃប្រឆាំងនឹងបារាំង
រហូតសំរេចបានជ័យជំនះដ៏ត្រចះត្រចង់ ។

នាគំនាក់កាលថ្មីមកទៀតដោយយើងមើលទៅលើរឿងថៅកែចិត្តចោរ
ឯណោះវិញ ។ ពេលដែលសង្គមជាតិខ្មែរពុំទាន់រឹងដៃជើង ជីវភាពរាស្ត្រពុំទាន់
មានលំនឹង សង្គមពោរពេញទៅដោយ អំពើល្មើសច្បាប់ ពួកថៅកែដែលមាន
ទ្រព្យកំពុងប្រជែងគ្នាធ្វើជាសេដ្ឋីនោះ ។ អ្នកនិពន្ធបានស្រាយអោយយើង
ឃើញថា កិត្តិយសនិងភាពថ្លៃថ្នូរនឹងកើតមានឡើងបានត្រូវប្រមូលផ្តុំទៅលើ

www.budnet.gov.kh www.elibraryofcambodia.org

ការរ៉ាប់រងអោយ បាននូវភិបត្តិចំបងក្នុងគ្រួសារ ត្រូវហ៊ានលះបង់សុភមង្គលផ្ទាល់ខ្លួនដើម្បីវែកមុខ ជនក្រឡិចក្រឡុចអោយសាធារណជនមើលឃើញច្បាស់នឹងភ្នែក ។ ជាភស្តុតាងបញ្ជាក់លើចំនុចនេះគឺអ្នកនិពន្ធបានអោយពូហាំសុខចិត្តធ្វើអំពើមួយ ដែលយើង អាចចោទប្រកាន់ថាជាអំពើល្ងង់ខ្លៅសំរាប់ប្លន់យកប្រាក់១ម៉ឺនរៀលពីថៅកែចិត្តចោរទៅផ្តុងផ្តើមអោយកូនបានរៀនសូត្រចេះដឹងនឹងគេយកទៅសង្គ្រោះជីវិតប្រពន្ធ ដែលកំពុងតំរាមកំហែងជីវិតដោយស្តេចមច្ចុរាជ និងសំរាប់តបស្នងគុណម្តាយចាស់ជរា ។ សកម្មភាពនេះពូហាំពុំមែនមិនដឹងថាជា អំពើមិនត្រឹមត្រូវទេតែ ក្នុងនាទីជាឪពុក ជាប្តី ជាកូនគាត់ត្រូវតែធ្វើ ដើម្បីទំលាយភាពតានតឹងក្នុងរង្វង់គ្រួសារអោយបាន ។ មិនតែប៉ុណ្ណោះពូហាំ ក៏ជួចជាកម្មករទាំងអស់ជាអ្នកដែល ក្រាញនឿលយ៉ាងស្វិតស្វាញបកអាក្រាតពីចាគុពិតរបស់ថៅកែចិត្តចោរ ដែលពុំព្រមទទួលស្គាល់ពាក្យសន្យានិងកំហុសដែលគេបានរួចចំនែកខុស ។ ដោយអ្នកទាំងនោះសុខចិត្តទទួលទោសមុខច្បាប់និងសុខចិត្តខាតបង់ផលប្រយោជន៍ផ្ទាល់ ខ្លួនតែត្រង់អោយចុះចាញ់គំនិតបោកបញ្ឆោតពាក្យបាតដៃជា ខ្លួងដៃរបស់ថៅកែ ចិត្តចោរគឺមិនព្រមជាដាច់ខាត ។ ចុងក្រោយពូហាំត្រូវជាប់គុក ប៉ុន្តែពុំកំនត់ថាគាត់ជាជនដែលមានឈ្មោះអាក្រក់ឥតតំលៃនោះទេ ។ គាត់នឹងត្រូវបានអ្នកផងស្ងប់ស្ងែងដោយសារតែគាត់ជាអ្នកដែលមានគំនិត សើរើនិយមគាស់រំលើងជនឱកាសនិយមអោយអស់ពីសង្គម នៅពេលដែលសង្គមកំពុងតែចិតក្នុងអាត់ជ្រោះនោះ ។ នេះសបញ្ជាក់អោយដឹងថា «គុកអាចឃុំឃាំងរូបរាងកាយមនុស្សបានប៉ុន្តែគុកពុំអាចឃុំឃាំងឧត្តមគតិមនុស្សបានទេ » ។

ចំនែកខាងរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់វិញម្តង ។ ការទួទ្ងានរបស់អ្នកនិពន្ធគឺមាន លក្ខណៈឆ្លើយតបយ៉ាងប្រតុក្រុ ទៅនឹងពុទ្ធិវាទរបស់

www.budinst.gov.kh www.elibraryofcambodia.org

ព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើង ។ លោកបានប្រាប់ថាកិត្តិយសនិងភាព ថ្លៃថ្នូររបស់មនុស្សវាចិតនៅលើមនុស្សចេះជួយយកអាសាគ្នាពេលក្រីក្រលំបាក ចៀសវាងនូវ ការលួចឆក់ចេះទទួលកំហុសដែលខ្លួនបានធ្វើ ។សំខាន់ជាងនេះ ទៀតគឺមនុស្សត្រូវមានគំនិតពុះពារនឹងជីវិត កុំអស់សង្ឃឹមអោយសោះ ។ តើមានភស្តុ តាងត្រង់ណាដែលជាតំនាងនូវអត្ថន័យទាំងអស់នោះ ។

នាមជាមិត្តភក្តិចិត្តមួយថ្លើមមួយ ម៉ីនិងម៉ុមបានផ្តល់ជំរកស្នាក់នៅ ដល់សមនិង នាងសយ ជួយចិញ្ចឹមគ្នាពេលអត់ការធ្វើពេលមានជំងឺជួយផ្តល់ ជាកំលាំងចិត្តពេលសមជាប់ពន្ធនាគារពីបទចោទប្រកាន់ដោយអយុត្តិធម៌ ។ យាយប៉េងយាយប៉ោះជាធ្មបបូរាណបានដុតដៃដុតជើងបញ្ចេញអស់សមត្ថភាព ដែលមានជួយសំរាលកូនប្រពន្ធសម ជួយចាប់កុសលផលបុណ្យសំរាប់សម យកទៅធ្វើបុណ្យសពប្រពន្ធជាដើម ។ បន្ថែមពីលើនេះទៀតសមមិន ព្រមធ្វើជាជនអន្ទពាល តាមការបបួលរបស់អ្នកជិតខាង ។ ឯការដែលសម ហ៊ានលួចកាបូបថៅកែ សំបូរសម្បត្តិ ក្រោយពីបានពិចារណារួចមកគេបាន យកទៅប្រគល់អោយម្ចាស់គេវិញ ជាការរំលស់ទោសកំហុសខ្លួន ។ ទាក់ទង នឹងលោករដ្ឋមន្ត្រីក្មេង គេបានយកសមទៅព្យាបាលជំងឺ ជួយសមអោយមាន ជីវិតសមរម្យ ឆ្លើយតបទៅនឹងរថយន្តរបស់លោកបើកទៅបុកសមអោយមាន របួស ។ ចំពោះរូបសមផ្ទាល់តែម្តងគេបាន ព្យាយាមចិញ្ចឹមជីវិតដោយសុចរិត ទ្រាំទ្រគ្រប់ការលំបាកគាំងពីនៅទីក្រុង រហូតទៅនៅជនបទក្រោយពីកិច អភិឌ្ឍន៍ជនបទដែលជាព្រះតំរិះដ៏ភ្លឺស្វាងនៃ អង្គសម្តេចឪមក ។ រួមមកអាច បញ្ជាក់ថា បុគ្គលដែលយើងបានបរិយាយខាងលើ ពិតជាមនុស្សដ៏ល្អពិតជា អ្នកដែលនឹងទទួលបាននូវកិត្តិយស ភាពថ្លៃថ្នូរ សក្តិសម និងអំពើដែលខ្លួន បានម្រេីតតួដែលអ្នកនិពន្ធបានលាតត្រដាង ជាគំរូស្រាប់ ។

www.budalist.gov.kh www.elibraryofcambodia.org

៣- <u>សរុបការពន្យល់</u>

សរុបសេចក្តីមក កិត្តិយសនិងភាពថ្លៃថ្នូរជាវត្ថុដ៏សំខាន់សំរាប់មនុស្ស ។ ការទទួលបាននូវវត្ថុទាំងពីរយ៉ាងនេះចាំបាច់មនុស្សត្រូវតែមានជំហរតស៊ូនឹងជីវិត កុំចុះញ៉ែមភាពអយុត្តិធម៌ ត្រូវហ៊ានលះបង់អ្វីៗដែលខ្លួនមានដើម្បីសមូហភាព ដើម្បីសង្គមជាតិ ចៀសវាងនូវអំពើស្មោកគ្រោកថោកទាបហ៊ានទទួលខុសត្រូវ ចំពោះអ្វីដែលខ្លួនបានធ្វើ ។ ការអនុវត្តបែបនេះទោះទីបច្ចុប្បន្នជាតិ ឬអនាគតជាតិ ឈ្មោះអ្នកនឹងក្រអូបច្រាស់ឲ្យល់ខ្លួនអ្នកនឹងមានការគោរពស្រលាញ់ការគាំទ្រពីសំនាក់មនុស្សទូទៅ ។

III-<u>យោបល់បញ្ចប់</u>

ទស្សនៈប្រធាននេះពិតជាមានខ្លឹមសារជ្រាលជ្រៅបំផុត សំរាប់យើងដែលជាអនុជនយកទៅត្រិះរិះពិចារណាទាញយកប្រយោជន៍រៀងៗខ្លួន ។ ពីព្រោះទស្សនៈនេះបានក្រើនរំលឹក យើងអោយស្គាល់ពីវិធានការកសាងខ្លួនអោយទៅជាជនប្រសើរបរិបូរណ៍ទៅដោយគុណធម៌សក្តានុភាពនិងអច្ចរិយភាព។ដូចនេះយើងទាំងអស់គ្នាបំនាច់នឹងកើតជាមនុស្សតោងតែកែខៃលៃលកយ៉ាងណាធ្វើអ្វីមួយជាជំនែលលួមុននឹងស្លាប់បាត់បង់ទេវិញ ដើម្បីបន្សល់ទុកនូវកេរ្តិ៍ឈ្មោះល្បីរន្ទឺការស្រណោះអាឡោះអាល័យក្នុងប្រវត្តិសាស្ត្រជាតិនិងចិត្តនៃជនគ្រប់ៗរូប ។

ទូកចរចេញទៅ	តែកំពង់នៅ	យីនយូរមិនឆាប់
ប្រៀបនឹងមនុស្ស	រស់តែងនឹងស្លាប់	ប៉ុន្តែកិត្តិស័ព្ទ
	ជិតជាប់សង្គម ។	

ម៉ិញ្ញេ- ឈីថាន
វិទ្យាល័យបឹងត្របែក

www.budinst.gov.kh www.elibraryofcambodia.org

ប្រធានទី៩ : អ្នកនិពន្ធក្នុងអក្សរសិល្ប៍ថ្នាក់ទី១២ បានបញ្ចប់រឿងរបស់គាត់ដោយប្រើសិល្ប៍វិធីតែងផ្សេងៗ ពីគ្នាទៅតាមស្ថានភាពពិតនៃសង្គមនិងទស្សនៈផ្ទាល់របស់ខ្លួន ។ ចូរបង្ហាញពីសិល្ប៍វិធីនោះរួចប្រាប់ពីគោលគំនិតសំខាន់ៗរបស់អ្នកនិពន្ធរឿងទាំងនោះផង ។

គំរោងតែង

១- ពន្យល់ពាក្យ

- បញ្ចប់រឿង = ផ្នែកចុងក្រោយនៃរឿង
- សិល្ប៍វិធីតែង = សិល្ប៍នៃការតែង, ល្បិចកលនៃការតែង

២- បកស្រាយ

ក- រឿងភូមិតិរច្ឆាន

*បញ្ចប់រឿង

- ទុទ្ទិដ្ឋិនិយមក្នុងការតស៊ូ→អ្នកតស៊ូរងនូវការលំបាកពុំសំរេចបាននូវជោគជ័យតាមចន្ទៈខ្លួន
- អាណានិគមនិយមមានប្រៀបនៅឡើយ

* គោលគំនិត

- បណ្តុះនូវបទពិសោធន៍សំរាប់ការតស៊ូនាពេលខាងមុខ
- បណ្តុះកំហឹងឈឺចាប់របស់រាស្ត្រ ចំពោះបរទេសឈ្លានពាន
- បង្ហាញពីនយោបាយនៃការគ្រប់គ្រងនិងការពារជាតិនៅមានកំរិត

ខ- រឿងចៅកែចិត្តចោរ

*បញ្ចប់រឿង

- អំនាចធ៌តប្រាត់ឈ្នះ អ្នកតស៊ូត្រូវរងទណ្ឌកម្មចាត់ប្រមោជន៍

www.buddhist.gov.kh www.elibrary.camboda.org

*គោលគំនិត

- បកអាក្រក់ពីភាពអយុត្តិធម៌សង្គម ក្នុងប្រទេសបង្គពីនាយទុន
- ប្រាប់ពីភាពទន់ជ្រាយរបស់ក្រុមមានសមត្ថកិច្ចខ្មែរក្នុងការរក្សាច្បាប់
- ផ្តល់ជាគតិសំរាប់អ្នកមានគំនិតតស៊ូប្រឆាំងនាយទុន

៥) - រឿងគ្លីកំនែន

*បញ្ចប់រឿង

ដោយបង្ហាញភាពសុទិដ្ឋិនិយមក្នុងការតស៊ូ

*គោលគំនិត

- បណ្តុះជំនឿជឿជាក់លើស្មារតីស្នេហាជាតិ
- ភាពទ្រុឌទ្រោមនៃ ពួកជិះជាន់ត្រប់ប្រទេសកើតពីកំលាំងសាមគ្គីជាតិរួមនឹងជាតិនានាក្រោមនីមអាណានិគម

៦ - ព្រះអាទិត្យថ្មីរះលើផែនដីចាស់

*បញ្ចប់រឿង

- បរិយាកាសរំភើបរីករាយ ខ្ពង់ខ្ពស់របស់កសិករក្រោមនយោបាយដ៏កនរំផ័ក្តីស្វាងនៃអង្គសម្តេចឪ ។

*គោលគំនិត

- បញ្ជាក់ស្មារតីប្រជារាស្ត្រអោយយល់ពីតំលៃកសិកម្ម
- ជឿងគុណចំពោះព្រះបិតាជាតិ ។ គុណនេះហើយផ្តល់នូវអនាគតរុងរឿងនៃកម្ពុជា ដែលនឹងក្លាយជាអរិយប្រទេស ។

www.budinst.gov.kh www.elibraryofcambodia.org

ផែនការសិក្សាមេរៀន

I- សេចក្តីផ្តើម

តាមទំលាប់រឿងនីមួយៗតែងតែមានផ្នែកបីជាមូលដ្ឋាន ។ ផ្នែកទី១ ឈ្មោះថាផ្តើមរឿង ផ្នែកទី២ជាតួរឿង និង ផ្នែកទី៣ ជាផ្នែកបញ្ចប់រឿង ។ នៅផ្នែកចុងក្រោយនេះ អ្នកនិពន្ធតែងបានបង្ហាញនូវសិល្បវិធីប្លែកៗពីគ្នាដើម្បីបង្កប់នូវគំនិតរបស់គាត់ប្រាប់ដល់អ្នកសិក្សាអ្នកអានទូទៅផ្នែកលើស្ថានភាពជាក់ស្តែងមួយចំនួនដែលគាត់លើកឡើងក្នុងតួរឿងទៅតាមបរិយាកាសសង្គម ។ តាមលោកទស្សនៈគាត់ ។ តើអ្នកនិពន្ធនៃអក្សរសិល្បថ្នាក់ទី១២ បានបញ្ចប់រឿងដោយរបៀបណា ? តាមរយៈនេះគាត់មានបំនងចង់ប្រាប់ពីអ្វីខ្លះ ?

II-តួសេចក្តី

១- ពន្យល់ពាក្យ

ក្រោយពីបានលាតត្រដាងនូវបញ្ហាផ្សេងៗផ្នែកកណ្តាលនៃរឿងរួចមករឿងនីមួយៗបានឈានចូលដល់ផ្នែកចុងក្រោយបង្អស់នៃរឿងដែលយើងកំនត់ថា «ការបញ្ចប់រឿង » ។ ក្នុងផ្នែកនេះមានការប្រែប្រួលទៅតាមប្រភេទរឿង ។ បើរឿង ពុទ្ធនិយមបញ្ចប់ដោយការសរជាតិតួអង្គអក្សរសិល្បប្រជាប្រិយ ទំនើបបានបញ្ចប់ដោយតុំរូវអោយតួអង្គប្រកបដោយប្រាជ្ញា ឈ្លាសវៃ តស៊ូមានភ័ព្វវាសនាខ្ពស់ក្នុងជីវិត ។ លក្ខណៈនេះឈ្មោះថា សិល្បវិធីតែងឬសិល្បៈនៃការតែងនិពន្ធ ។

២- បកស្រាយ

បើយើងមើលក្នុងរឿងភូមិតិរច្ចានដែលសាច់រឿងមានលក្ខណៈទាក់ទង

www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងជិតស្និទ្ធទៅប្រវត្តិសាស្ត្រពិតនៃប្រទេសកម្ពុជានាកំឡុងមុនឆ្នាំ១៩៥៣ អ្នកនិពន្ធបានបញ្ចប់រឿងក្នុងសភាពមួយបែបទុទ្ទិដ្ឋនិយម ។ ពោលគឺបញ្ចប់ទៅដោយពុំបានផ្តល់នូវភាព រីករាយសំរាប់វាសនានៃការតស៊ូរបស់អ្នកស្រុកក្រាំលាវឡើយ ។ យ៉ាងណាមិញក្រុមតស៊ូជាច្រើនត្រូវរងនូវការកាប់សំលាប់យ៉ាងសាហាវព្រៃផ្សៃពី សំនាក់បារាំង ។ គេត្រូវរ៉ាប់រងនូវទណ្ឌកម្មធ្ងើបុណ្យបញ្ចូនបុណ្យកុសលអោយបាដេសដែលពួកគេសំលាប់ ។ អ្នកដែលមានភ័ព្វវាសនារស់រានមានជីវិតបានវិល មកជួបប្រពន្ធកូនប្តីសិរីញ ក្នុងភាពញាំញីតញាញើមភ្នែកនៅកញ្ចឹងក ។ ផ្ទុយពីអាណានិគមនិយមបារាំងនៅតែមានសិទ្ធិពេញលេញត្រួតត្រាកម្ពុជាជាបន្តទៅទៀត ។ តើការបញ្ចប់បែបនេះមានអត្ថន័យយ៉ាងណាខ្លះទៅ ? ។

វិភាគទៅលើប្រភេទរឿងយើងអាចបកស្រាយបានថា អ្នកនិពន្ធមានបំនងចង់បណ្តុះនូវបទពិសោធជ័ម្យ៉ាង ដែលទាក់ទងនឹងការតស៊ូប្រឆាំងរបស់រាស្ត្រខ្មែរចំពោះបរទេសឃ្លានពាន ។ ការតស៊ូនេះហើយដែលជះឥទ្ធិពលដល់ផលវិបាកផ្នែកបញ្ចប់ ។ និយាយអោយចំគឺការតស៊ូនេះទទួលនូវការបង្ក្រាបអោយរាបងួចកន្ទេល ពីសំនាក់ពួកបារាំង ។ សិល្បីវិធីនេះ ចង់ស្តែងពីរូបភាពនៃការតស៊ូបើអ្នកតស៊ូមានឆន្ទៈមុះមុតមានការឯកភាពគ្នាមានចំនាត់តាំងដ៏ត្រឹមត្រូវហើយ ប៉ុន្តែឱកាសសំខាន់ពុំទាន់ហុចអោយគួបផ្សំនឹងរចនាសម្ព័ន្ធបរទេសនៅមានភាពរឹងមាំទេ នោះយើងពុំអាចផ្តួលរំលំអោយបរទេសនោះវិនាសខ្ទាត់ខ្ទាយបានភ្លាមទេ ។ វាមិនខុសពីការ «យកសាំងទៅចាក់លើខ្លួនឯងពេលដែលភ្លើងកំពុងឆេះ» នោះឡើយ។ ក្រៅពីនេះយើងអាចសំលឹងឃើញដល់ជំរៅចិត្តអ្នកនិពន្ធ លោកចង់បណ្តុះកំហឹង ឈឺចាប់ដល់ប្រជារាស្ត្រខ្មែរអោយកាន់តែក្តៅក្នុងដួងចិត្ត ។ ដោយអោយខ្មែរម្នាក់ៗ ចងចាំថាដោយសារ

www.budirist.gov.kh www.elibraryofcambodia.org

តែបារាំងនេះហើយធ្វើអោយខ្មែរឯងទុក្ខវេទនា ព្រាត់ ព្រាស់ក្រុមគ្រួសារនិង ស្លាប់ជាបន្តបន្ទាប់ព្រោះតែគំនិតមហិច្ឆតា អត្តទត្ថភាពរបស់ ពួកគេនោះ ។ អីចឹងទេ! ការបញ្ចប់បែបនេះពុំមែន មានន័យបន្ទុចបង្ហាប់ផ្នត់គំនិតរបីបំរះរបស់ ខ្មែរអោយរួញរៀវនោះជាដាច់ខាត ។

មួយវិញទៀតការបញ្ចប់រឿងភូមិគិរច្ឆានប្រៀបបានទៅនឹងភ្លើង អគ្គីសនីបង្ហាញពីនយោបាយគ្រប់គ្រងនិងការពារជាតិខ្មែរពិតៗ ។ បានសេចក្តី យើងបានធ្វើអោយជំហានរបស់ជាតិយើង ជាន់លើជ្រោះមរណៈត្រដរខ្លួនទៅ មុខពុំរួចទៅក្រោយពុំរួច ដែលជាហេតុធ្វើអោយយើងត្រូវបង្ខំចិត្តទទួលយក បន្តាប់មកវិះរក វិធានការស្តារស្ថានការណ៍ប្រទេសជាតិ អោយមានតុល្យភាព និងមានអធិបតេយ្យភាពឡើងវិញ ។ ដូចនេះយើងឃើញថាការបញ្ចប់រឿង ដោយសិល្បវិធីបែបនេះវាឆ្លើយតបទាំងស្រុងទៅនឹងស្ថានភាពពិតនៃសង្គម ខ្មែរ ។

មិនខុសពីរឿងភូមិគិរច្ឆានប៉ុន្មានទេ ។ រឿងថៅកែចិត្តចោរក៏បាន បញ្ចប់ក្នុងភាពក្រៀមក្រំដែរ ។ លោកពៅ យូឡេង និង អ៊ុំ ឈីន បានធ្វើអោយ អំនាចទឹកប្រាក់ក្លាយជារលកដ៏សក្តិសិទ្ធិលេបត្របាក់សច្ចធម៌ ។ អ្នកដែល ក្រោកដណ្តើម សច្ចធម៌ត្រូវទៅដេកក្នុងគុក ត្រូវបាត់បង់នូវលាភសក្ការៈបាត់ បង់អាជីព ។ ករណីដូចជាពូហាំត្រូវជាប់គុកកម្មករដែលជួយពូហាំត្រូវថៅកែ ចិត្តចោរ បណ្តេញចេញពីការងារ ។ ឯថៅកែចិត្តចោររស់នៅយ៉ាងសប្បាយ លើគំនក់ទឹកភ្នែកក្រុមគ្រួសារកម្មករទាំងអស់ ។

ក្នុងករណីបែបនេះអ្នកនិពន្ធមានទស្សនៈបញ្ជាក់នូវអត្ថន័យបីយ៉ាង ដែលយើងមើលឃើញ ។ អត្ថន័យទី១គឺ អ្នកនិពន្ធចង់បកអាក្រាតពីភាព អយុត្តិធម៌សង្គមបង្ហាញពីពួកនាយទុន ដែលមានថៅកែចិត្តចោរជាស្តេ -

www.elibraryofcambodia.org

ស្រាប់ ។ ថៅ កែរូប នេះជាអ្នកបំពុលបរិយាកាសសង្គមអោយវឹកវរគេយកលុយដើម្បីទាក់យកលុយ ។ គេជួលពូហាំអោយធ្វើការអាក្រក់មួយអោយខ្លួនសំរាប់ដណ្តើមយកឧត្តមភាពលើ មុខរបរខ្លួនដោយពុំរើរវល់ នឹងសេចក្តីស្លាប់នៃមនុស្សជាច្រើន ។ គេគិតតែពីលុយ! លុយ ! ត្រង់នរណាងាប់ក៏គេពុំឈឺក្បាល វិលមុខអ្វីឡើយ ។ អត្ថន័យទី២គឺបែរមុខ ព្រួញទៅរកការបញ្ជាក់ពីភាពទន់ជ្រាយនៃក្រុមមានសមត្ថកិច្ចខ្មែរក្នុងការរក្សាច្បាប់ជូនប្រជារាស្ត្រស្លូតត្រង់ ។ បើតាមសំដីអ្នកនិពន្ធពួកប៉ូលីសដែលតាមដានជំលោះពូហាំ និងថៅកែចិត្តចោរ ត្រូវពុលនឹងលុយរបស់ថៅកែចិត្តចោរ ហ៊ឹងត្រចៀក ខ្វាក់ភ្នែកឃើញថៅកែចិត្តចោរជាផ្កា ឯពូហាំជាលាមក ។ គេបានបិទមាត់ពូហាំរួចបញ្ជូន ពូហាំទៅកាន់ពន្ធនាគារ ដោយគ្មានវែកញែករកខុសត្រូវអ្វីទាំងអស់ ។

លើអត្ថន័យជុំវិញការបញ្ចប់នៃរឿងថៅ កែ ចិត្តចោរយើងអាចដឹងពីទស្សនៈផ្ទាល់របស់អ្នកនិពន្ធគឺលោកចង់ទាញស្មារតីដល់អ្នក ដែលមានបំនងផ្តាច់រឹសគល់នៃល្បិចកលខ្មៅកខ្វក់របស់នាយទុន គឺ ចាំបាច់ត្រូវមើលមុខក្រោយកុំលង់នឹងឧបាយកលរបស់ពួកគេ ។ ពីព្រោះពួកនេះមានស្មៀតច្រើនណាស់ផ្លាស់ប្តូរ បត់បែនដូចសត្វជីងចក់ ។ តួយ៉ាងពូហាំដែលលង់ខ្លួនប្រព្រឹត្តិបាបកម្មតាមថៅកែ ចិត្តចោររហូតដល់មានទោសក៏ព្រោះតែចាញ់បោកសំដីបាតដៃខ្មែងដៃជីអសប្បុរសនេះឯង ។

ពាក់ព័ន្ធទៅនឹងរឿងគួលីកំនែនការបញ្ចប់រឿងនេះបានបង្កនូវ ភាពសុទិដ្ឋិនិយម គួរអោយរំភើបក្នុងចិត្តពន់ប្រមាណ ។ គឺចលនាតស៊ូ របស់អ្នកស្នេហាជាតិខ្មែរ ដែលមាននូ ដួង ម៉ឹង លឹម និងប្រជារាស្ត្រខ្មែរទូទៅបានជំរុញអោយប្រទេសជាតិស្គាល់នូវពន្លឺឯករាជ្យ ។ ពួកអាណានិគមនិយម និងពួកប្រតិកិរិយាដួលរំលំ ។ ខ្មែរបានកាន់កាប់វាសនាប្រទេសជាតិដោយខ្លួនឯង ។

www.budinst.gov.kh www.elibraryofcambodia.org

អ្នកដែលធ្លាប់រស់ក្នុងព្រៃតស៊ូបានកាន់កាប់ប្រទេសជាតិ ដោយខ្លួនឯង ។ អ្នកដែល ធ្លាប់រស់ក្នុងព្រៃតស៊ូបានវិលមកជួបជុំក្រុមគ្រួសារ គួសង្សាមយុវជនបានជ្បារ ចំនងមេត្រីភាពរវាងគ្នានឹងគ្នាឡើងវិញ ។ កសិករបានវិលមកកាន់ស្រែចំការច្បារដំនាំខ្លួនបង្កបង្កើនផលដូចប្រក្រតី ។

យោលលើសិល្បវិធីនេះយើងអាចដឹងនូវបំនងលោកអ៊ីមថុកដែល-ដែលចង់បណ្តុះនូវជំនឿជឿលើ ស្មារតីស្នេហាជាតិប្រាកដជាឈ្នះ ។ ស្មារតីនេះជាកំលាំងចលករដែលគ្មានអ្វីមករារាំងបានឡើយ ។ គួបផ្សំនឹងនេះរឿងក៏បាន បញ្ជាក់ពីភាពទ្រុឌទ្រោមនៃ ពួកជិះជាន់ដែលតែងតែធ្វើការរាតត្បាតដោយខុសច្បាប់លើប្រទេសមួយ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។ ជាការពិតណាស់ប្រទេសណាក៏ដូចប្រទេសណាដែរ នាពេលជាមួយគ្នានេះត្រូវជួបនូវការគ្រួតគ្រា របស់បារាំង ជប៉ុន ដូចគ្នា ។ ទាំងប្រទេសគេទាំងប្រទេសយើងបានក្រោកទាមទារ ឯករាជ្យសិទ្ធិ សេរីភាពដូចគ្នា ។ ការរួមចិត្តរួមគំនិតនេះហើយដែលធ្វើអោយបារាំង ជប៉ុនទ្រាំទ្រពុំ បានដកខ្លួនថយក្រោមកំលាំងតស៊ូវាយបណ្តេញពីប្រជារាស្ត្រម្ចាស់ស្រុក ។

ចំនែករឿងព្រះអាទិត្យរះលើផែនដីចាស់ តួរឿងបានបង្ហាញនូវភាពអួរអាប់ក្នុងជីវិតប្រជារាស្ត្រគ្រួសារខ្មែរម្នាក់ដែល មានសមជាតំនាង ។ ជីវិតរបស់គេ ពោរពេញទៅដោយសោកនាដកម្ម ដោយរឿងអភ័ព្វទោះបីគេខំត្រដរបញ្ចៀសជីវិតមិនអោយជួបក្តី ។ ឧត្តមគតិរបស់គេត្រូវ មនុស្សចិត្តពាលគ្មានធម៌មេត្តា រួមមានថៅកែហុក ឧកញ៉ាសំបូរសម្បត្តិ តំនាងរាស្ត្រយើងក្រុមប៉ូលីស អ្នកទទួល ខុសត្រូវពន្ធនាគារ ជាន់ពន្លិចអោយកប់នៅក្នុងភក់ជ្រាំ ។ ប៉ុន្តែ«ក្រោយភ្លៀង មេឃស្រឡះ» ។ នេះជាគោលគំនិតរបស់លោកសួនសុរិន្ទ នាផ្តែកបញ្ចប់រឿង ។ គឺចង់និយាយថា លោកបានបង្ហាញនូវបរិយាកាសគួរ

www.ibdist.gov.kh www.elibraryofcambodia.org

អោយមោទនភាពនៃជីវិត របស់សម ក៏ដូចជាខ្មែរទូទាំងប្រទេសក្រោមនយោបាយដឹកនាំដ៏ភ្លឺស្វាង របស់អង្គសម្តេចឪ ជាទីសក្ការៈនៃយើង។ ជាក់ស្តែងគឺសមបានផ្លាស់ពីជីវភាពដុនដាបទៅ ជាមានជីវភាពធូរធារមានកិត្តិយសខ្ពង់ខ្ពស់ ។ សមបានក្លាយជាឥស្សរជនដ៏ឆ្នើម ជួសមុខអោយកសិករខ្មែរនៅជនបទ ។

គោលគំនិតខាងលើនេះ គឺជាការពន្លាក់ស្មារតីប្រជារាស្ត្រខ្មែរអោយយល់ពីតំលៃដែលកើត ពីការពុះពារទ្រាំទ្រការលំបាកក្នុងជីវិតរបស់មនុស្ស ។ ពិសេសគឺចង់អោយយើង ស្រលាញ់កសិកម្ម ។ កសិកម្មជាមូលដ្ឋានចំបងបំផុតអោយសេដ្ឋកិច្ចជាតិធ្វើអោយជាតិមានវឌ្ឍនភាព ។ ជាភស្តុតាងឯសមនោះបីគេ មានក្តីមេត្តាករុណាពីរដ្ឋមន្ត្រី ក្មេងអោយរស់ស្រួលធ្វើការស្រនុក ។ តែគេយល់ថា ជីវភាពបែបនេះហាក់បីដូចជាព្រំដែន ខ័ណ្ឌជីវិតរបស់គេអោយចាត់បង់នូវសេរី ភាពនិង តួនាទីពលរដ្ឋ ដែលត្រូវតែមានកាតព្វកិច្ចកសាងជាតិមាតុភូមិដើម្បីជាកិច្ចតបស្នងសងគុណមាតុភូមិដែលខ្លួនកើតនិងរស់នៅ ។ ទស្សនៈនេះហើយនាំ អោយសមអោយវិលទៅរកស្រុកកំនើតឯស្រុកស្រែរហូតក្លាយជាកសិករគំរូម្នាក់ ។

គំនិតទី២ អ្នកនិពន្ធចង់ធ្វើការប្រៀបធៀបស្ថានភាពប្រទេសខ្មែរមុននិង ក្រោយពេលដែលមានចលនាកសាងប្រទេស ក្រោមចលនាសង្គមរាស្ត្រនិយម ដែលមានសម្តេច ឪ ជាព្រះបិតាជាតិ ត្រួសត្រាយផ្លូវ ។ ម្យ៉ាងទៀតលោកក៏មាន បំនងរំលឹកនូវព្រះករុណាទិគុណ របស់អង្គសម្តេចឪដែលបានលើកស្ទួយប្រទេសជាតិ និងប្រជារាស្ត្រអោយឈានឆ្ពោះទៅភាពសំបូរសប្បាយលើគ្រប់វិស័យ ។ ព្រះគុណនេះហើយដែលយើងពុំអាចបំភ្លេចបានហើយក៏ជាស្ថានចំណងអនាគត ជាតិពីប្រទេសជួនដាបអាណានិគមយូ អូស្ត្រាលីទៅជា

www.budinst.gov.kh www.elibraryofcambodia.org

អរិយប្រទេស មាន កិត្យានុភាពល្បីរន្ទឺពាសពេញពិភពលោកនោះ ។

៣- <u>សរុបការពន្យល់</u>

រួមសេចក្តីមកថ្វីត្បិតតែការពាប់រឿងរបស់អ្នកនិពន្ធក្នុងអក្សរសិល្ប៍ថ្នាក់ទី១២ មានលក្ខណៈខុសពីគ្នាខ្លះក្តី ។ ប៉ុន្តែគោលបំណងរបស់លោកអោក់ស៊ីចង្វាក់គ្នាល្អណាស់ ។ គឺគ្រប់រឿងទាំងអស់ត្រើនផ្តោតលើការអណ្តុះស្មារតីតស៊ូបង្ហាញ នូវបទពិសោធន៍ថ្មីសំរាប់ ជោគជ័យនាពេលអនាគត បកអាក្រាតពីឧបាយកលក្រឡិចក្រឡុករបស់ពួកឱកាសនិយម ដែលឆ្មៀតយកចំនេញលើរាស្ត្រ រំកិលមុខម៉ាត់ពិតនៃក្រុមមានសមត្ថកិច្ច ដែលឈ្លក់វង្វេងនឹងទីកប្រាក់ភ្លេចគិតប្រយោជន៍ជាតិជាធំ ។ ពិសេសរឿងនៅបានធ្វើអោយរាស្ត្រខ្មែរវិលឹកនឹកដល់ស្តាប្រះហស្តអង្គ សម្តេចឪ ដែលព្រះអង្គតែងតែបានបូជាអស់នូវព្រះកាយពល ព្រះបញ្ញាញាណព្រះជន្មាឥតស្តាយស្រនោះ ដើម្បីបុព្វហេតុឯករាជ្យជាតិ កសាងនិងការពារជាតិ រីកចំរើនលេចមុខខ្ពស់ត្រដែតនៅលើឆាកអន្តរជាតិ ។

III-<u>យោបល់បញ្ចប់</u>

ផ្អែកលើការវិភាគរួចមកហើយ យើងមានការកោតសរសើរយ៉ាងខ្លាំងចំពោះទឹកដៃនិពន្ធនៃអ្នកនិពន្ធខ្មែរយើង ។ ដោយលោកបានចេះប្រើនូវសិល្បវិធីបង្ហាញនូវបញ្ហាល្អៗសំរាប់ជាគុណប្រយោជន៍ជួយដល់គំនិត និងស្មារតីកូនខ្មែរ នូទៅអោយមានការយល់ដឹងអានការភ្ញាក់រលឹកចូលរួមស្តារបនាជាតិកម្ពុជាដោយ ស្មោះស្ម័ត្រ និង អង់អាចក្លាហាន ។ សិល្បវិធីនេះជាឈ្មោះដ៏អានប្រសិទ្ធភាព ធ្វើអោយយើងអាចអានលទ្ធភាពត្រប់គ្រាន់តែរក្សាទឹកដីអោយគង់វង្សជារៀងរហូតទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

ឃ្លាឧទាហរណ៍១០: គេថា «នារីបានរួមវិភាគទានយ៉ាងធំធេងចំពោះសង្គមជាតិ និងសង្គមគ្រួសារ ។ ចូរបង្ហាញដោយលើកពីសកម្មភាពនារីក្នុងអក្សរសិល្ប៍ ផ្នាក់ទី១២ ដែលអ្នកបានសិក្សារួច ។

គំរោងតែង

១- ពន្យល់ពាក្យ

រួមវិភាគទាន = ការរួមចំនែកធ្វើអ្វីៗសព្វបែបយ៉ាង

សង្គមជាតិ = ប្រទេសជាតិទាំងមូល

សង្គមគ្រួសារ = មនុស្សមួយក្រុមតូច

២- បកស្រាយ

* ន័យទូទៅ : សកម្មភាពនារីក្នុងបុព្វហេតុអភិវឌ្ឍសង្គម

ក- នារីក្នុងរឿងភូមិតិរច្ឆាន

សង្គមជាតិ	សង្គមគ្រួសារ
- ជួយបន្ថយភាពព្រៃផ្សៃតស៊ូ	- បន្ធូរទុក្ខកង្វល់ប្តី
- បង្កើនភាពល្អតលាស់សង្គម	- អត់ធ្មត់ ជួយប្តីអោយមានឥស្សរភាព

ខ- នារីក្នុងរឿងគូលីកំនែន

សង្គមជាតិ	សង្គមគ្រួសារ
- ផ្តល់កំលាំងចិត្តក្នុងការរំដោះជាតិ	- ពង្រឹងជីវភាពគ្រួសារអោយធូរធារ
- លើកកិត្តិយសនារីដូចគ្នា	- ស្មោះស្ម័គ្រប្តូរផ្តាច់ពេលលំបាក

គ- នារីក្នុងរឿងព្រះអាទិត្យរះលើផែនដីចាស់

សង្គមជាតិ	សង្គមគ្រួសារ
- ជួយអ្នកទន្ទ្រេត	- ស្រឡាញ់អំពើល្អ

www.buddhist.gov.kh www.elibraryofcambodia.org

- ជួយអ្នកជួបអាសន្ន
- លើកកិត្តិយសគ្រួសារ

ឃ- <u>នារីក្នុងរឿងថៅកែចិត្តចោរ</u>

សង្គមជាតិ	សង្គមគ្រួសារ
- មិនបង្កភាពល្អក់កករក្នុងសង្គម	- រួមចំណែករំលែកទុក្ខដោយមានបំនងផ្តាច់រឿងអាស្រូវនានា

*<u>ន័យបន្ថែម</u> នារីក្នុងអក្សរសិល្ប៍ថ្នាក់ទី១២ ក៏បានបង្កភាពអាក្រក់ចំពោះសង្គមជាតិនិងគ្រួសារ ។

- ភាពវឹកវរ, អាប់អោនសង្គមជាតិ
- បង្កភាពអន្តរាយក្តៅឈ្នោះគ្រួសារ

I- <u>**សេចក្តីផ្តើម**</u>

ប្រទេសជាតិនីមួយៗនារីតាងតួាយជាកំលាំងចលករដែលធ្វើអោយមានការប្រែប្រួលលើផ្ទៃកនានានៃ អោយរាកនាសម្ព័ន្ធជាតិ ។ នេះអាស្រ័យដោយសារជាតិនីមួយៗទាំងនោះ មានចំនួននារីដ៏ច្រើនកុះករ ហើយនារីទាំងអស់នោះបញ្ចេញអស់នូវកំលាំងកាយចិត្ត ប្រាជ្ញាស្មារតីចូលរួមយ៉ាងសកម្មក្នុងបុព្វហេតុសង្គម ។ ក្នុងន័យនេះហើយ បានជាមានទស្សនៈមួយលើកឡើងថា «នារីបានចូល រួមវិភាគទានដ៏ធំធេងចំពោះសង្គមជាតិនិងគ្រួសារ » ។ តើទស្សនៈនេះមាន អត្ថន័យដូចម្តេចខ្លះ ? នារីក្នុងអក្សរសិល្ប៍ថ្នាក់ទី១២ បានធ្វើ

www.budinst.gov.kh www.elibraryofcambodia.org

អ្វីដែលជាវិភាគទាន សំរាប់សង្គមជាតិនិងសង្គមគ្រួសារនោះ ?

II-តួសេចក្តី

១- ពន្យល់ពាក្យ

អំពើដែលបានចែករំលែកនូវអ្វីៗទាំងអស់ដែលខ្លួនមានសំរាប់ជាផលប្រយោជន៍អ្វីមួយឈ្មោះថា «រួមវិភាគទាន » ។ ឯ« សង្គមជាតិ» ខុសពី « សង្គមគ្រួសារ» ។ សង្គមជាតិសំដៅលើជាតិទាំងមូល ឬអ្វីៗដែលជាផលប្រយោជន៍ទាក់ទងក្រុមមនុស្សភាគច្រើន ឬជាតិទាំងមូល ។ ចំពោះសង្គមគ្រួសារចង់និយាយពី ក្រុមមនុស្សមួយក្រុមតូចដែលមានគ្នាច្រើន ឬតិចរួមមានប្តីប្រពន្ធកូនចៅនោះឯង ។ យោលលើអត្ថន័យនេះយើងអាចទាញទៅរកគំនិតប្រធានខាងលើនេះចង់និយាយថា នារីជាអ្នកដែលចែករំលែកនូវអ្វីៗខ្លួនមានដើម្បីជាផលប្រយោជន៍មនុស្សទូទៅ ឬសំរាប់ជាតិនិងសំរាប់ប្តីប្រពន្ធកូនចៅខ្លួន ។

២- បកស្រាយ

ទំព័រប្រវត្តិសាស្ត្ររបស់ជាតិខ្មែរ បានចារឹកទុកនូវស្នាដៃជាច្រើនរបស់នារីក្នុងបុព្វហេតុជាតិ និង ក្រុមញាតិ ដែលជាមនុស្សរួមជាតិ ឬជាសាច់សាលោហិតរបស់ខ្លួន ។ នាងនាគជាអង្គក្សត្រីខ្មែរ នាកំឡុងសតវត្សទី១នៃ គ្រីស្តសករាជ។ ព្រះនាងបានធ្វើអោយប្រទេសជាតិមានការរីកចំរើនលូតលាស់ ។ សង្គមជាតិមានស្ថិរភាព ។ ប្រជារាស្ត្ររស់យ៉ាងសុខដុមរមនា ។ ព្រះនាងឥន្ទ្រទេវី ជារាជទេពីនៃព្រះបាទជ័យវរ្ម័នទី៧ បានបញ្ជូនអស់នូវព្រះបញ្ជាញ្ជាណ ជួយដល់រាជកិច្ចស្វាមីធ្វើអោយទឹកដីមហានគរចាលឈ្មោះ បោះសំលេងនាយុគសម័យនោះ ។ នេះគឺមិនខុសពីពាក្យប្រៀបរាណខ្មែរចែងថា « សំនាបយោងដី ស្រីយោងប្រុស » ។ ការលើកឡើងពីករណីនាង

www.budinst.gov.kh www.elibraryofcambodia.org

នាគនិងព្រះនាងឥន្ទ្រទេវី ក៏ជាគំរូបញ្ជាក់ថានារីជាកំលាំងរស់មិនអាចផ្តាច់បាន ចំពោះសង្គមជាតិនិងសង្គមគ្រួសារ ។ គឺមានន័យថា ថ្វីត្បិតតែនារីមានកំលាំងពលំតិចមែនតែនារី បានរួមចំនែកដ៏សំខាន់ សំរាប់ធ្វើអោយបុរសដែលមានកំលាំងពលំច្រើនមាំមួន សំរេចអោយបានជោគជ័យតាមចិត្តដែលខ្លួនប៉ង ប្រាថ្នាតាមរយៈប្រាជ្ញានិង កំលាំងកាយខ្លួន ។ ដោយឡែកនារីក្នុងអក្សរសិល្ប៍ថ្នាក់ទី១២ គេបានធ្វើអ្វីខ្លះសំរាប់សង្គមជាតិ និងសង្គមគ្រួសារនោះ ? ។

នាងនីនាងប៊ីនាងតន់ជាតំនាងអោយនារីខ្មែរភាគច្រើន ។ សំរាប់នារីទាំងអស់នេះអ្នកនិពន្ធរឿងភូមិតិរច្ឆានបានបង្ហាញពីគំនិតជួយសង្គមជាតិនៅត្រង់ពួកគេបានចូលរួមយ៉ាងសកម្ម កាត់បន្ថយភាពព្រៃផ្សៃដែលពួកអាណានិគមបារាំង បានប្រព្រឹត្តមកលើសង្គមខ្មែរ ហើយថែមទាំងបានបង្កើនភាពលួតលាស់គួរអោយហោទនៈជូនជាតិ ។ យ៉ាងណាមិញគឺនារីទាំងនេះហើយដែលបានសហការជាមួយ ក្រុមតស៊ូរបស់នៅជួន បំបែកកំលាំងសត្រូវធ្វើអោយសត្រូវទ្រុឌទ្រោមភ្ញីភ្ញែកឈប់មើលងាយខ្មែរ បន្ថយនូវអំពើជិះជាន់លើខ្មែរ ។ នាងនី នាងប៊ីបានប្រថុយ ជីវិតកំទេចបាដេលនិងបរិវារអោយស្លាប់នៅ និងកន្លែង ដើម្បីឆ្លើយតបទៅនឹងកំហឹងរាស្ត្រខ្មែរជាច្រើន ដែលធ្លាប់រងគ្រោះធ្លាប់ជួបទុក្ខវេទនាដោយសារពួកនោះ ។

ចំពោះអនាគតគ្រួសារ នារីទាំងប៉ុន្មានដែលយើងបានបញ្ជាក់រួចមកហើយនេះបានរួមវិភាគទានបន្ថយបន្ថយនូវទុក្ខកង្វល់របស់ប្តី ទ្រាំទ្រអត់ធ្មត់សព្វបែបយ៉ាងដើម្បីឥស្សរភាពប្តី ។ នាងនី នាងប៊ីបានខិតខំប្រែប្រួលលុយកាក់ដែលខ្លួនសន្សំបានទាំងប៉ុន្មាន ទៅបង់អោយបារាំងដោយនាងមិនចង់ឃើញប្តីទទួលទារុណកម្ម ឬក៏ទទួលនូវគ្រោះថ្នាក់ដល់ជីវិតឡើយ ។ ស្មារតីនេះជាគំរូដ៏ល្អនៃនារីខ្មែរដែលមាន «ទឹកចិត្តភក្តីភាព ស្មោះអត់ស្មោះឆ្លើយ លំបាក់វេទនាចំពោះ

www.budirect.gov.kh - www.elibraryofcambodia.org

ក្រុមគ្រួសារ » នោះ ។ នាងតន់ទោះនាងជាប្រពន្ធក្រោយរបស់សុវណ្ណដែលជាបុរសពោះម៉ាយ កូនមួយក្តី ក៏នាងបានរួមចំនែក ផ្តល់នូវការកក់ក្តៅដល់ប្តី បំបាត់នូវកង្វល់ប្តីដោយនាងបានថ្នាក់ថ្នម ថែរក្សាកូនប្រពន្ធមុនសុវណ្ណ អស់ពីចិត្តពីថ្លើម ។ នាងចាត់ទុកក្មេងនោះជាសាច់ឈាមបង្កើតរបស់ខ្លួន ។ កាយវិការដ៏ល្អនេះហើយដែលធ្វើអោយសុវណ្ណមានកំលាំងចិត្តធ្វើនូវអ្វីៗទាំងអស់ប្លុងយកសុភមង្គលជូនជាតិ និងគ្រួសារនោះ ។

គួរអោយកោតសរសើរជាងនេះទៀតនោះគឺនារីក្នុងរឿងគួលីកំនែន។ អ្នកគ្រូគួរស់ នាងហេង ជានារី ដែលបានផ្តល់ជាកំលាំងចិត្ត ដល់ម៉ឹង លឹម អោយមានទឹកចិត្តអង់អាចក្លាហានចេញមុខរំដោះជាតិនិងប្រជាជនខ្មែរពីនឹមត្រួតត្រាបរទេស ។ នាងគួ រស់បានសំដែងនូវមនោសញ្ចេតនាគាំទ្រទង្វើរបស់ម៉ឹង ដែលត្រូវចូលរួមក្នុងចលនាតស៊ូតាមសំនើរបស់នួជួង ។ នាងហេងបានផ្តល់នូវការ ទុកចិត្តដល់លឹមមុនពេលដែលលឹមត្រូវចេញទៅធ្វើគួលីកំនែន ។ ដោយនាង សន្យាថា «ស្មោះស្ម័គ្រនឹង លឹមជានិច្ច» ។ សកម្មភាពបែបនេះគឺយើងឃើញថា នារីទាំងពីរនាក់ គេបានចេញមុខបង្ក្រាបសត្រូវដោយផ្ទាល់មែនតែគេបានរួម ចំនែកជួយជាតិដោយប្រយោលស្របទៅតាមលក្ខណៈសម្បត្តិធម្មជាតិជានារីភេទ។ ពិសេសជាងនេះទៀតគឺនាងហេងនេះហើយដែលរួមវិភាគទានក្នុងការលើកស្ទួយកិត្តិយសនារីខ្មែរទូទៅ ។ ជាក់ស្តែងនាងពុំបានបណ្តោយអោយខ្លួនក្លាយទៅជា ចំនីតណ្ហារបស់ចៅហ្វាយស្រុក តាមរយៈអំនាចនិងទឹកប្រាក់ឡើយ ។ នាងបាន រត់គេចពីស្រុកកំនើតជាមួយឪពុកម្តាយលឹមមកភ្នំពេញរហូតដល់បាត់បង់ជីវិត ។

ចុះវិភាគទានសំរាប់សង្គមគ្រួសារតើមានយ៉ាងណាខ្លះ ? ក្នុងនារីជាកូនជាពលរដ្ឋក្នុងសង្គម នារីក្នុងរឿងគួលីកំនែនបាន រួមចំនែកពង្រឹងជីវភាព

www.buddhism.gov.kh www.elibraryofcambodia.org

គ្រួសារអោយមានលំនឹង ស្មោះស្ម័គ្រប្តូរផ្តាច់ចំពោះក្រុមគ្រួសារពេលមានការលំបាក ។ នារីទាំងនោះគឺចង់ដៅទៅលើយាយម៉ុក ម្តាយនាងហេង នាងហេងនេះឯង ។ អ្នកទាំងអស់នេះហើយបានខិតខំធ្វើស្រែចំការធ្វើការងារស្រាលៗនៅឯផ្ទះទប់ទប់កំលាំងប្តី ឪពុកម្តាយ ដើម្បីប្រមូលចំនួលផ្គត់ផ្គង់គ្រួសារអោយផុតពីភាពដុនដាប ក្នុងកាលៈទេសៈដែលប្រទេសជាតិរបស់ខ្លួនកំពុងឋិតក្នុងគ្រោះអាសន្ននោះ ។

ក្រឡេកទៅមើល នារីក្នុងរឿងព្រះអាទិត្យរះលើផែនដីចាស់ ឯណោះវិញ ។ យាយប៉េងយាយប៉ោះ ជាព្រីទ្ធាចារ្យ ដែលមានជំនាញខាងឆ្លប ។ ដួចចាស់ទាំងពីរបួបនេះបានបូជាអស់កំលាំងកាយចិត្តដែលខ្លួនមានជួយដល់នារីទុរគត ខ្មែរជាច្រើននាក់គ្មានប្រាក់កាសហើយត្រូវសំរាលកូននៅឯផ្ទះនោះ ។ តួយ៉ាងគឺយើងឃើញស្រាប់ ដួនចាស់ទាំងពីរបួបនេះហើយដែលបានបញ្ចេញអស់សមត្ថភាព ដែលខ្លួនមានជួយសំរាលកូនអោយនាងសយដែលជានារីកំសត់ មានសមជាប្តីដែលទាល់ដៃទាល់ជើង ។ តែពុទ្ធោអើយ ! ទោះជាគាត់ខំប្រឹងអស់លទ្ធភាពបែបនេះក្តីគាត់ពុំអាចជួយនាងសយអោយរួចពីសេចក្តីស្លាប់បានឡើយ ដោយសារការសំរាលរបស់នាងសយមានលក្ខណៈពិសេសដែលឆ្លបបូរាណដួចគាត់ពុំអាចបំពេញកិច្ចការងារដ៏លំបាកនេះបាន។ ចំនុចនេះលោក សួនសុរិន្ទចង់បញ្ជាក់ថា នារីខ្មែរជាអ្នកដែលបានរួមចំណែកដ៏សំបើមពុំអាចកាត់ថ្លៃបានចំពោះជនទុគ៌ត ជនដែលជួបនូវគ្រោះអាសន្ននោះ។ ក្រៅពីការជួយសង្គមជាតិ នារីក៏បានជួយដល់គ្រួសារច្រើនណាស់ ។ ដួចជាបានចូលរួមជាទីប្រឹក្សា ផ្តល់មតិយោបល់អោយប្តីដើរទៅរកផ្លូវលួជួយសំរាលបន្ទុកប្តី លើកមុខមាត់ ប្តីអោយខ្ពស់ត្រដែក ។ ជាក់ស្តែងនាងសយជាភរិយាមួយរូបដែលតែងតែបង្កនូវបរិយាកាសរីករាយដល់សមពេលដែលសម

www.budinst.gov.kh www.elibraryofcambodia.org

ឥតការងារធ្វើ ខ្វះសព្វខ្វះគ្រប់ ។ នាងសុយបានធ្វើអោយសមមានក្តីសង្ឃឹមជានិច្ចក្នុងជីវិតតាមរយៈពាក្យសំដីផ្សេងៗ ពេលដែលប្តីធ្លាក់ក្នុងភាពទាល់ច្រកនោះ ។ ព្រោះតែអំពើនេះហើយដែល ធ្វើអោយសមកើតមានក្តីសង្វេគក្តីអាណិតស្រលាញ់ភរិយាស្មើនឹងជីវិតខ្លួន ។

មិនខុសពីនារីក្នុងរឿងដូចដែលយើងបានបង្ហាញរួចប៉ុន្មានទេ ។ មីងយ៉ាន ក្នុងរឿងថៅកែចិត្តចោរ ក៏ជានារីមួយរូបដែលមិនមានបំនង ទាល់តែសោះបង្កើតនូវភាពល្អក់កករចំពោះសង្គមជាតិ ។ មីងមានវិប្បដិសារីខ្លាំងណាស់នៅពេល ដែលប្តីរបស់គាត់បានធ្វើតាមថៅកែ ចិត្តចោរនាំអោយមានគ្រោះថ្នាក់ដល់មនុស្សជាច្រើន ។ ពោលគឺមីងយល់ថា ប្តីរបស់គាត់ធ្វើបែបនេះគឺដើម្បីគាត់និងក្រុមគ្រួសារមែនហើយ ។ ប៉ុន្តែភាពទោឡូញគឺត្រង់ថាការធ្វើពលីកម្មរបស់ពូហាំ បានធ្វើអោយ «ទឹកភ្នែកគ្រួសារជាច្រើនហូរ» ។ ក្នុងចិត្តរបស់គាត់គិតថា បើអ្នកគាត់ជាអ្នកទាំងនោះវិញ ក៏ត្រូវទទួលរងនូវការពិចាប់ខ្មោចផ្សាក្នុងចិត្តដូចគ្នា ចំពោះឧប្បត្តិហេតុដ៏កំនាចរំអែកនេះ ។

ប្រឈមអមុខទល់និងបញ្ហាថ្មីក្នុងគ្រួសារគឺការដែលពូហាំត្រូវបានទទួលទោសដោយអយុត្តិធម៌នោះ ។ មីងយ៉ានមានបំនងចូលរួមរំលែកទុក្ខប្តីអោយបាន អួសទាញប្តីអោយទំលាក់ចោលរឿងក្តីក្តាំថៅកែចិត្តចោរអួសត្រាស់ដើម្បីរង់ចាំ ឱកាសដោះស្រាយរកសន្ទៅនៅពេលក្រោយ ។ គោលគំនិតបែបនេះពុំមែនមានន័យថា គាត់ជាស្ត្រីទន់ជ្រាយចុះញ៉ែនឹងភាពអយុត្តិធម៌ឬក៏គាំទ្រថៅកែចិត្តចោរនោះទេ ។ គាត់មានទស្សនៈតាមរភាពជាស្ត្រីភេទថា «បើពូហាំគេចខ្លួនបានពេល នេះពូហាំប្រាកដជាបានសុខមួយគ្រាគ្រានជាមិនខាននៃជីវិតគាត់ កូននិងម្តាយកាស់ជរា » ។ គំនិតបែបនេះជាការសរសេរអួមួយដែរដែលចាស់ប្លែកណាខ្មែរយើងលោក តែងមានប្រសាសន៍ថា «កុំរងអួនដីងកុំ

www.budinst.gov.kh www.elibraryofcambodia.org

ទទឹងមុខសឹក » ។ គឺបានសេចក្តីថា ក្នុងកាលៈទេសៈមួយដែលសង្គមមនុស្ស ពុំទាន់យល់ពីសច្ចធម៌ គួរតែយើងរកមធ្យោបាយថ្មី កុំអាលតក់ក្រហល់ ប្រញាប់ប្រញាល់ពេក ។ មធ្យោបាយថ្មីនោះគឺត្រូវធ្វើសន្សឹមៗទៅតាម លំដាប់លំដាប់នោះទើបបានសំរេចខ្លួនក៏បានសុខជាតិក៏ចំរើន ។ តាមន័យនេះ អាចកំនត់បានថា មីងយ៉ានពិតជានារីម្នាក់ដែលមានសុឆន្ទៈ ជួយគ្រួសារចង់ អោយគ្រួសារបានរួម រស់ដោយសុវត្ថិភាព និងមានសុភមង្គលនោះ ។

ផ្ទុយពីនារីដូចបានរៀបរាប់ខាងលើក៏យើងបានមើលឃើញផងដែរនារី មួយចំនួនក្នុងរឿងថ្នាក់ទី១២ ជាអ្នកបង្កនូវភាពអាក្រក់ដល់សង្គមជាតិនិង ក្រុមគ្រួសារផង ។ ដោយនារីទាំងនោះ បង្កើតនូវភាពវឹកវរសង្គមធ្វើអោយ សង្គមជាតិ អាប់អោនធ្វើអោយកើរឈ្មោះគ្រួសាររងនូវក្តីអាម៉ាស់ដោយសារ ខ្លួន ។ ក្នុងនោះ មាននាងវ៉ែនដែលជាស្ត្រីវង្វេងនឹងប្រាក់ធ្លាក់ក្នុងអន្លង់ទុក្ខ សោកបំរើភាពភ្លើតភ្លើន ភ្លើនភ្លេចអស់នូវតំលៃប្រពៃណីជាតិ ។ ប្រពន្ធឧកញ៉ា សំបូរសម្បត្តិ អ្នកស្រីជាថៅកែស៊ីក្លូដែលសមជួល ។ នារីទាំងនោះជាមនុស្ស ដែលគិតពីមាសប្រាក់ ចិត្តខ្មៅបូស្បាធ្វេចភ្នែករស់ក្នុងគំនរទុក្ខនៃអ្នកក្រីក្រ ។ ទោះបីអ្នកក្រទាំងនោះបានសំដែង នូវគុណធម៌ដល់ខ្លួនក្តី ។ ជាសក្តីភាព ប្រពន្ធឧកញ៉ាសំបូរសម្បត្តិនេះឯង ជាអ្នកពន្យុះប្តីអោយព្រមានសមនៅពេល សមប្រគល់នូវវត្ថុមានតំលៃអោយខ្លួនដោយសារភាពថា អ្វីដែលខ្លួនធ្វើកន្លង មកនោះគេជាអំពើមិនត្រឹមត្រូវ ។

៣- <u>សរុបការពន្យល់</u>

សរុបសេចក្តីមកនារី ជាអ្នកដែលបានរួមវិភាគទានដ៏ធំធេងចំពោះ សង្គមជាតិនិងសង្គមគ្រួសារមែន ។ ដោយនារីបានបូជាអស់សមត្ថភាពដែល

www.budinst.gov.kh www.elibraryofcambodia.org

ខ្លួនមានធ្វើអោយជាតិមានសិទ្ធិសេរីភាព មានកេរ្តិ៍ឈ្មោះពីរោះសុសសាយមាន ភាពល្អតលាស់ផ្កាស់ប្តូរមុខមាត់ពីអន់ថយទៅចំរើនជឿនលឿន ។ ក្នុងគ្រួសារ នារីធ្វើ អោយគ្រួសារមានសុភមង្គលមានថាមពល អាចបំពេញនូវកិច្ច ការផ្សេងៗបានសំរេចគោលដៅល្អៗស្របតាមច្បាប់សង្គមមនុស្សទាំងមូល ។

III- <u>យោបល់បញ្ចប់</u>

យោលលើខ្លឹមសារ ដែលយើងបានមកស្រាយជាបន្តបន្ទាប់រួចមក ហើយនេះ យើងអាចវាយតំលៃបានថានារីពិតជាមានគុណបំនាច់ដ៏ធំធេងលើ សង្គមជាតិនិងសង្គមគ្រួសារពិតមែន ។ ព្រោះយើងសង្កេតឃើញថា នារី ជាដៃគូដ៏ពិសេស ជួយជ្រោមជ្រែងគ្រប់ការងាររបស់បុរសទាំងការងារនយោ-បាយសេដ្ឋកិច្ចវប្បធម៌ ការពារនិងកសាងប្រទេស ។ ដូចនេះគួរយើង កំចាត់ចោលនូវទស្សនៈរើសអើងស្ត្រីភេទ ហើយនាំគ្នាគិតថា អ្វីៗទាំងអស់ ដែលយើងបានឃើញច្បាស់នឹងភ្នែក នាពេលនេះគឺពុំអាចកាត់ផ្តាច់បានពីការ ចូលរួមចំនែករបស់នារីសោះឡើយ ។

មានលក់ដុំនិងលក់រាយនូវសៀវភៅអាន

គ្រប់មុខវិជ្ជា ល្បើងរូបភាព ចំរៀង KARAOKE

១_តូបលេខ ៧៥ ផ្សារអូឬស្សី

ទូរស័ព្ទដៃលេខ: ០១៨ ៨១៤ ២២៥

២_តូបលេខ ៦៨ ផ្សារធំថ្មី

ទូរស័ព្ទដៃលេខ: ០១៨ ៨១៥ ៦៩៣

សូមអរគុណ !

www.budinst.gov.kh www.elibraryofcambodia.org

ប្រធានទី១១: គេថា «ប៊ឹង និង ពូហាំមានភាវៈជាកូនប្រុស» ។ ចូរបង្ហាញដោយលើកឧទាហរណ៍មកបញ្ជាក់អោយបានពិស្តារ ។

គំរោងឆ្លើយ

១- ពន្យល់ពាក្យ

ភាវៈកូនប្រុស = ភាពជាអ្នកវីរៈប៊ឹង

២- បកស្រាយ

ក- ប៊ឹងមានភាវៈជាកូនប្រុស

- មានចំនេះវិជ្ជាខ្ពង់ខ្ពស់និងមានសីលធម៌រស់នៅល្អ
- មិនកំសាកនឹងពាក្យបំភិតបំភ័យ
- មានជំហរទទួលខុសត្រូវនឹងការងារ
- មានគំនិតស្រលាញ់ សិទ្ធិសេរីភាពនិងឯករាជ្យ
- មិនមានវិប្បដិសារី ចំពោះពិការភាពក្នុងបុព្វហេតុជាតិ

ខ- ពូហាំមានភាវៈជាកូនប្រុស

- មានសមត្ថភាពលើផ្នែក វិជ្ជាជីវៈ
- ម៉ត់ចត់ចំពោះកិច្ចការដែលត្រូវបំពេញ
- ហ៊ានទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានធ្វើ
- មានគំនិតលះបង់ដើម្បីអនាគតគ្រួសារ
- មិនទន់ជ្រាយចំពោះការគំរាមកំហែងរបស់នាយទុន
- មិនក្បត់នឹងឧត្តមគតិខ្លួន

www.budinst.gov.kh www.elibraryofcambodia.org

ផែនចន្ទីអធិប្បាយ

I-សេចក្តីផ្តើម

ម៉ឹងជាតួអង្គឯកដ៏សំខាន់នៃរឿងគូលីកំនែន ។ ឯពូហាំជាតួអង្គដ៏សំខាន់ នៃរឿងថៅកែចិត្តចោរ ។ អ្នកទាំងពីរសុទ្ធតែជាមនុស្សដែលមានគំនិតដ៏ខ្ពង់ខ្ពស់ក្នុងចលនាលុបបំបាត់ចោលនូវភាពសំនល់អាក្រក់ក្នុងសង្គមជាអ្នកដែលមានគំនិតអភិវឌ្ឍក្នុងផ្នែកគស្ដិនិងជីវិត ដោយស្មារតីមុះមុតប្លែកផ្តាច់ ។ ប្រការបែបនេះ ហើយបានជាមានទស្សនៈមួយលើកឡើងថា «ម៉ឹងនិងពូហាំមានភាវៈជាកូនប្រុស» ។ តើចំនុចត្រង់ណាខ្លះ ដែលបញ្ជាក់ថា អ្នកទាំងពីរជាមនុស្សដែលមានលក្ខណៈបែបនេះ ?

II-ក្នុងសេចក្តី

១- ពន្យល់ពាក្យ

«ភាវៈជាកូនប្រុស» ចង់ដៅទៅលើអ្នកដែលមានជំហររឹងប៉ឹងមិនទ្រេតទ្រោត រោអស់អែក ចំពោះឧបសគ្គដែលកើតមានចំពោះមុខ ។ ភាពជាកូនប្រុសគឺ មនុស្សដែលពោរពេញទៅដោយឋាមពលចូលទៅមុខដើម្បីឧត្តមប្រយោជន៍ ។ អំពើដែលគេធ្វើគឺឆ្លងកាត់ការពិចារណាយ៉ាងល្អិតល្អន់ប្រកបដោយគតិបណ្ឌិតយកចំនេះដឹងប្រាជ្ញាដែលខ្លួនមានស្រាយគ្រប់បញ្ហា ។ និយាយរួមអ្វីដែលកំនត់ថា ម៉ឹងនិងពូហាំមានភាវៈជាកូនប្រុសដោយផ្អែកលើអ្នកទាំងពីរជាមនុស្សមានជំហររឹងប៉ឹងបំផុតក្នុងជីវិត ។

២- បកស្រាយ

ច្បាប់ប្រុសបានចែងថា ក្នុងនាមជាកូនប្រុសគឺជាអ្នកឈ្នះ។អ្នកដែល

www.budinst.gov.kh www.elibraryofcambodia.org

អាចធ្វើអ្វីៗបានដោយឥតទើសទាល់រាល់ទង្វើរបស់កូនប្រុសបានស្តែងឡើង-តាមរយៈគំនិតច្នៃប្រឌិត យិតយោងជីវិតអោយឆ្ពោះទៅរកភាពជ័រុងរឿង ។ គេមិនកំសាកមិនមើលបំនាំរាល់ការងារធំៗ ដែលខ្លួនត្រូវបំពេញនោះឡើយ ។

ជាការពិតណាស់ក្នុងនាទីជាកូនប្រុសយើងពិនិត្យឃើញម៉ឹងជាមនុស្ស ម្នាក់ដែលមានចំនេះដឹងខ្ពស់ ។ គេបានបញ្ចប់ការសិក្សានៅសាលាមធ្យមសិក្សា ។ សមត្ថភាពនេះហើយជំរុញអោយគេត្រូវទទួលបានន្ទវការងារដ៏សមស្របមួយនៅខេត្ត ។ ពោលគេជាមន្ត្រីរាជការ ដែលត្រូវកាន់កាប់កិច្ចការរាជការមួយមានអ្នក ជំនួយការអមការងារខ្លួន ។ ទោះបីថិតក្នុងតំនែងបែបនេះក្តី ម៉ឹងតែងបានប្រកាន់ខ្ជាប់នូវសីលធម៌រស់នៅដ៏ល្អប្រសើរ មិនឆ្មើងឆ្មៃមិនតំកើងបូកខ្ពស់ហួសពីអ្នកដទៃ ។ គេគោរពបានយ៉ាងត្រឹមត្រូវសមជាបុរសថ្លៃថ្នូរ ។ យ៉ាងណាមិញក្នុងការ ស្នាក់នៅផ្ទះបងជីដូនមួយអ្នកគ្រូគួ រស់ម៉ឹង តែងប្រកាន់ចរិតថ្លៃថ្នូរ មិនប្រព្រឹត្តឆ្គាំឆ្គងនាំអោយមានការរង្កៀសចិត្តពីម្ចាស់ផ្ទះឡើយ ។ ទំនាក់ទំនងស្នេហារបស់ គេចំពោះអ្នកគ្រូរស់គឺមានភាពទន់ភ្លន់ មិនធ្វើរំលងនឹងប្រពៃណី ។ គេរក្សាខ្ជាប់នូវ ក្តីស្នេហ៍បរិសុទ្ធផុសចេញពីការគោរពគ្នាទៅវិញទៅមក ។ ចំនុចនេះជាភាវៈកូនប្រុសទី១ របស់ម៉ឹង ។

ក្នុងមុខតំនែងជាមន្ត្រីមួយរូបម៉ឹងជាមន្ត្រីរាជការមួយរូបដែលមិនតក់ស្លុតពាក្យគំរាមកំហែង ។ គេធ្វើការងារយ៉ាងម៉ឺងម៉ាត់បំផុត ។ ម៉ឹងប្រកាន់ន្ទវជំហរបែបឈ្មោះថាកុលបុត្រខ្មែរមួយរូបដែលរក្សាបាននូវតំលៃខ្លួនជាកូនប្រុស ។ តួយ៉ាងដូចពេលដែលគេកំពុងបំពេញការងារ ម៉ឹងហ៊ានតវ៉ាត្រង់ៗនឹងបារាំង ពេលគេគំរាមចង់ចាប់ខ្លួនដាក់គុកថា «បើខ្ញុំគ្មានសមត្ថភាពដេញខ្ញុំចោលទៅ ខ្ញុំមិនអង្វរទេ ខ្ញុំមានកំហុសអ្វីបានជាលោកចង់ចាប់ខ្ញុំ »។ សំដីប៉ុណ្ណោះបញ្ជាក់ពី ភាពអង់អាចរបស់ម៉ឹងដែលបានចេញមុខតវ៉ានឹងបារាំង

www.nidirst.gov.kh www.elibraryofcambodia.org

ដែលកំពុងមានឥទ្ធិពលពេញទំហឹងលើទឹកដីកម្ពុជា ។

បើនិយាយពីស្មារតីរបស់ម៉ឹង វិញយើងឃើញថា គេជាបុរសម្នាក់ដែលមានគំនិតស្រលាញ់សិទ្ធិ សេរីភាពនិងឯករាជ្យណាស់ ។ គេចេញមុខដើរតួជាអ្នកនយោបាយបំផុសចលនាតស៊ូដេញបារាំង មិនចង់អោយកម្ពុជាឋិតនៅក្រោមការ ត្រួតត្រារបស់បារាំង ។ គំនិតរបស់គេបានលេចរូបរាងច្បាស់ល្អាស់នៅក្រោយពេលដែលម៉ឹងបានទទួលសំបុត្រពីន្ធូដួងជាបងរបស់ខ្លួន ។ ម៉ឹងបានសំរេចចិត្តបោះបង់ចោលការងារនៅកាន់អារ៉ុងវ៉ាយបណ្តេញពួកអាណានិគមនិយមដោយឥតរារែក ។ ដូចដែលសេចក្តីក្នុងសំបុត្រគេទុកអោយអ្នកត្រួតូរស់ថា «បងទៅតស៊ូដេញពួកឡាំង បារាំងអាហើរចចក្រពត្តិត្រាព្រោះបើនៅយូរឃើញខកការ ចូលក្នុងបន្ទាអន្ទាក់វា ។ បងចេញទៅមុខខំប្រឹងធ្លាតស៊ូតវ៉ាទាមទារសិទ្ធិបងនឹងមកហៅរស់វរបិត្រ ចូលទៅរួមមិត្តជួយតស៊ូ»។ ចន្លះនេះជាគំរូដ៏ប្រសើរដែល យុវជនខ្មែរត្រូវតែរៀនសូត្រតាមដើម្បីសមជាកូនប្រុស ។

គួរអោយយើង ចាប់អារម្មណ៍ប្លុកឯទៀតទៅលើម៉ឹងនោះ គឺម៉ឹងជាអ្នកដែលហ៊ាន បូជាន្ធូវយុវភាពដ៏ផ្លូវផង់របស់ខ្លួនដើម្បីជាតិ ។ ពោលគឺក្រោយពីសំរេចបានឯករាជ្យមកម៉ឹងបានក្លាយខ្លួនទៅជាជនពិការ ។ ពិការភាពនេះពុំធ្វើអោយម៉ឹងមានវិប្បដិសារីឡើយ ។ ដោយពិការភាពរបស់គេគឺដើម្បីជាតិ។ ក្នុងនាមជាពលរដ្ឋ ត្រូវតែមានកាតព្វកិច្ចតបស្នងសងគុណជាតិ ជួយជាតិទោះបីត្រូវពលីជីវិតក្តី ។ ត្រង់ចំនុចនេះក៏យើងបានឃើញ និងភ្នែកនាពេលបច្ចុប្បន្ននេះយុវជនខ្មែរមួយចំនួន បានបូជាដៃ- ជើង- ភ្នែក ក្នុងបុព្វហេតុសង្គ្រោះជាតិអោយរស់រាន ជួយប្រជារាស្ត្រអោយសុខសាន្ត ។ ការលះបង់ទាំងនេះត្រូវបានសាវតារជាតិ ចារឹកទុកនាមអ្នកទាំងនោះក្នុងក្រាំងមាសហើយប្រជាជនគ្រប់

www.budinst.gov.kh www.elibraryofcambodia.org

ជាន់ថ្នាក់សំដែងនូវការគោរពដ៏ស្មោះស្ម័គ្រក្រៃលែង ។

រួចមកហើយយើងបានដឹងពីភាវៈជាកូនប្រុសរបស់ម៉ឹង ។ ចុះចំពោះពូហាំភាវៈជាកូនប្រុសរបស់គាត់គឺត្រង់ណាខ្លះ ? ។ ពូហាំជាអ្នកដែលមានមុខជំនាញផ្នែកវិជ្ជាជីវៈដ៏ចំណាន ។ គាត់ចេះបើកបរ រថយន្តយកប្រាក់មកចិញ្ចឹមខ្លួននិង ក្រុមគ្រួសារដោយសុចរិតតាមកំលាំងល្បើសឈាម និងសមត្ថភាពដែលខ្លួនមាន ។ ការដែលគាត់កើតជាមនុស្ស ហើយមានការងារធ្វើដ៏សមស្រប បែបនេះជាកិត្តិយសដ៏សំខាន់មួយ ។ គាត់មិនដាក់ខ្លួនទៅជាមនុស្ស «ចោលម្បៀតរស់ចង្កៀតផែនដី» នោះទេ ។

បើពិនិត្យ ទៅលើការងាររបស់ពូហាំយើងឃើញថាគេបានបំពេញភារកិច្ចបានយ៉ាងគាប់ប្រសើរ ។ គឺអ្វីដែលគាត់ទទួលធ្វើ គឺធ្វើដោយម៉ត់ចត់ប្រុងប្រយ័ត្ន ។ ក្នុងន័យនេះហើយដែលពូហាំត្រូវបានទទួលនូវការជ្រើមជ្រែងនិងគាំទ្រយ៉ាងពេញ ទំហឹងពីសំនាក់កម្មករក្នុងអាជីព ។ ដោយគេយល់ថា «ពូហាំជាមនុស្សសាច់ការហ៊ានទទួលខុសត្រូវ» ។ ជាភស្តុតាងការដែលគាត់ដាក់ចិត្តទទួលការងាររបស់ថៅកែ ចិត្តចោរគាត់ធ្វើដោយឥតខ្លាចគ្រោះថ្នាក់ ។ ពេលដែលជួបគ្រោះថ្នាក់គាត់មិនខ្លាច នឹងទទួលទោស ។ ដោយសារអំពើរបស់គាត់មានអ្នកបញ្ជាអោយធ្វើដោយច្បាស់លាស់ ។ គាត់មានសាក្សីត្រឹមត្រូវពេលដែលថៅកែចិត្តចោរបញ្ជាអោយខ្លួន បើកឡានបុកឡានថៅកែហុងលីដោយសន្យាថាគេ នឹងប្រគល់លុយ ១ម៉ឺនរៀល ។ លុះការងារបានសំរេចចៅហ្វាយចិត្តខ្មៅក្រឡាស់សំដីយករួចខ្លួន ។ តែពូហាំនៅតែ តាមប្រកិតរក ស ខ្មៅ ទារលុយពីថៅកែនេះជានិច្ចពុំរាថយក្រោយឡើយ ។

តើអ្វីទៅដែលយើងគួរអោយកត់សំគាល់ អោយឃើញថាពូហាំជាកូនប្រុស ដោយគាត់មានគំនិតលះបង់ដើម្បីសុភមង្គលភាពគ្រួសារនោះ ? ។

www.budinst.gov.kh www.elibraryofcambodia.org

យើងជឿជាក់ថាពូហំ ពុំមែនជាមនុស្សមិនដឹងច្បាប់នោះទេ គាត់ពិតជាដឹងថាទង្វើរបស់គាត់ដើម្បីប្លន់យកប្រាក់១ម៉ឺនរៀលពីថៅកែប្រាកដជានឹងធ្វើអោយរូបគាត់មានទោសធ្ងន់ពុំអាចចៀសផុតបានឡើយ ។ ប៉ុន្តែអ្វីដែលពូហំត្រូវតែធ្វើនោះ គឺអោយខ្លួនមានទុក្ខតែម្នាក់ឯងចុះ ដើម្បីអោយមនុស្សបីនាក់ទៀត ដែលជាសមាជិកគ្រួសារគាត់បានសុខសាន្ត ។ ដូចជាសំដីដែលពូហំបានលើកឡើងជាមួយជានិតថា «ពូត្រូវការលុយមួយម៉ឺន គ្មានមួយម៉ឺនប្រពន្ធពូងាប់ឈឺដើមទ្រូងក្អកខេះៗ ។ ពេទ្យអោយសំបុត្រទិញថ្នាំ ពូគ្មានលុយធ្វើម្តេចទុកអោយប្រពន្ធពូស្លាប់រឺ ? ។ កូនស្រីពូ ជាប់ចូលរៀនអនុវិទ្យាល័យសាលាគំរូវអោយទិញសព្វគ្រប់ ។ ខាតរៀនកូនលង់ ដូចពូធំឡើងវេទនាដូចពូ ។ ពូត្រូវត្រូវតែប្លន់ដើម្បីចំណេះកូន ។ ម្តាយពូគាត់ចាស់ហើយគាត់ចង់ធ្វើបុណ្យ ។ គាត់សុំពូ· ។ បើមិនរកប្រាក់អោយគាត់ធ្វើបុណ្យទានហាក់ដូចជាធ្វើទារុណកម្មសំលាប់គាត់អញ្ចឹង» ។ នេះហើយគឺជាការពិចារណានៃកូនប្រុសក្នុងស្ថានភាពជាឪពុក ជាប្តី ជាកូនដែលមានម្តាយចាស់ជរា ។

លើសពីនេះទៀត យើងឃើញថា ពូហំជាមនុស្សរឹងប៉ឹងមិនទន់ជ្រាយនឹង បញ្ហាចំពោះមុខ ព្រមទាំងជាមនុស្សដែលមិនបោះបង់ចោលនូវគំនិតដែលខ្លួនបានគិតទុកនោះឡើយ ។ ជាការបញ្ជាក់លើចំនុចនេះយើងឃើញថាក្រោយពីការទារ លុយថៅកែចិតចោរ ហើយថៅកែនោះមិនព្រមអោយថែមទាំងសំលុតថាប្តឹងប្រើ លុយកាក់សូកប៉ាន់ចិត្តកម្មករប្រពន្ធពូហំ សូកប៉ាន់ប៉ូលីស ពូហំ បាននិយាយយ៉ាងម៉ឺងម៉ាត់ថា «ខ្ញុំនេះហើយតែកុងហំលោកចាប់ខ្ញុំចុះ ខ្ញុំមិនរត់ទេ ។ តែសូមលោកជ្រាបថា បើលោកចាប់ខ្ញុំលោកត្រូវចាប់មនុស្សដែលបានណែនាំខ្ញុំអោយធ្វើអំពើ ឃោរឃៅនេះផង» ។ ភាពម៉ឺងម៉ាត់របស់ពូហំជាសក្ខីភាពបញ្ជាក់ពីចិត្តកូនប្រុស «ទោះទឹកចូលត្រមុះក៏

www.budinst.gov.kh www.elibraryofcambodia.org

នៅតែត្រូវរំកិលល្បែករកការពិតអោយឃើញ» ។ គ្រានោះហើយដែលយើងអាចកំនត់យ៉ាងប្រត្យក្សថា ថ្វីត្បិតតែពូហាំក្លាយជាទណ្ឌិតតែពុំបានធ្វើអោយគាត់បាត់បង់នូវតំលៃជាមនុស្សទេ ។ ពីព្រោះឈ្មោះជាអ្នកទោសរបស់គាត់កើតពីស្មោកគ្រោករបស់នាយទុន ក្រុមភ្នាក់ងារនគរបាលដែលក្បត់ទឹងច្បាប់ក្បត់ទឹងឧត្តមប្រយោជន៍ជាតិ ។ ពួកគេជាឈ្លើងជ័ាចសាហាវបីតជញ្ជាក់ឈាមជាតិប្រជារាស្ត្រអោយវិនាសដោយសារខ្លួននោះ ។

៣. <u>សរុបការពន្យល់</u>

រួមសេចក្តីមក ម៊ឹងក្តី ពូហាំក្តី ជាអ្នកដែលមិនចុះញ៉ែមរាល់ឧបសគ្គ ។ ពួកគេមិនខ្លាចរអារនឹងភាពអយុត្តិធម៌ ហ៊ានបូជាអ្វីដែលខ្លួនមានដើម្បីផលប្រយោជន៍មនុស្សភាគច្រើន ។ ពួកគេមានទឹកចិត្តស្រលាញ់សិទ្ធិ សេរីភាព មិនបណ្តោយ អោយខ្លួនឋិតនៅក្រោមការគំរាមកំហែងតាមអំពើចិត្តនៃជនក្បត់ប្រយោជន៍ជាតិ ហ៊ានទទួលខុសត្រូវរាល់ទង្វើដែលខ្លួនបានធ្វើ ។ ពួកគេបានយកសមត្ថភាពដែល ខ្លួនមានទៅបំពេញនូវរាល់កិច្ចការងារដោយគំនិតឯករាជ្យ និងប្រកបដោយ វិចារណញ្ញាណ ។ គ្រប់សកម្មភាពទាំងអស់នេះហើយបញ្ជាក់យ៉ាងច្បាស់ថា «ម៊ឹងក្តី ពូហាំក្តីអានភាវៈជាកូនប្រុស» នោះ ។

III- <u>យោបល់បញ្ចប់</u>

ចុងបញ្ចប់នេះដោយផ្អែកលើបំនកស្រាយខាងលើ យើងអាចវាយតំលៃបានថា ម៊ឹង និង ពូហាំ ពេញជាតួអង្គមនុស្សប្រុសពិតៗ បញ្ហានេះដោយយោលលើការងារ ការយល់ដឹង ការបញ្ចេញយោបល់ ចរិតឫកពាកាយវិការរបស់អ្នកទាំងពីរ ប្រកបទៅដោយចិត្តកតញ្ញូ ចិត្តស្រឡាញ់ សិទ្ធិសេរីភាពក្លាហានហ៊ានវែកមុខពួក អសកម្មក្នុងសង្គម ។ ពិសេសពួកគេបានផ្តល់ជាគំរូដ៏

www.budinst.gov.kh www.elibraryofcambodia.org

ល្អៗមួយផ្នែកធំដែលទុកជា មេរៀនសំរាប់អោយយើងយកតំរាប់តាម ។ បើក្នុងសង្គមជាតិសំបូរទៅដោយ មនុស្សដែលមានលក្ខណៈសម្បត្តិដូចអ្នកទាំងពីរយើងជឿជាក់ថា ជាតិរបស់យើងពិតជានឹងស្គាល់នូវភាពថ្កុំថ្កើងរុងរឿងយ៉ាងធាប់រហ័សពុំខានឡើយ ។

☆☆☆☆
☆☆☆

www.budinst.gov.kh www.elibraryofcambodia.org

ប្រធានទី១២ : «រស់និងស្លាប់ជាច្បាប់របស់ធម្មជាតិ » ។ តើរស់និងស្លាប់បែបណាគាប់ប្រសើរ រស់និងស្លាប់បែបណាមិនគាប់ប្រសើរនោះ ? ។ ចូរអ្នកបង្ហាញដោយ លើកឧទាហរណ៍ករណីស្លាប់ និងរស់របស់តួអង្គមួយចំនួនក្នុងរឿងភូមិតិរច្ឆាន ។

គំរោង

១- ពន្យល់ពាក្យ

រស់និងស្លាប់គាប់ប្រសើរ = ការមានជីវិតនិងការបាត់បង់ជីវិតទៅវិញប្រកបដោយកិត្តិយសមានតំលៃ

រស់និងស្លាប់មិនគាប់ប្រសើរ = ការមានជីវិតនិងស្លាប់ទៅវិញគ្មានន័យនិងទទួលការថ្កោលទោស។

២- បកស្រាយ

☆ **ន័យទូទៅ**

- ព្រះពុទ្ធមានព្រះជន្មកសាងកុសលកម្ម ជួយសត្វលោកអោយដើរកផ្លូវល្អ បរិនិព្វានតាមអាយុសង្ខារ → គាប់ប្រសើរមនុស្សគោរពរាប់គំនរ
- អ្របិយជនរស់ប្រព្រឹត្តបាបកម្ម ស្លាប់ដោយតែហោង → មិនគាប់ប្រសើរគ្មានន័យអាសោចក្តើសូន្យឈ្មោះ ។

រឿងតូមិតិរច្ឆាន

ក. តួអង្គរស់និងស្លាប់គាប់ប្រសើរ

នៅជួន ក្រុមតស៊ូនារីត្រាំងលាវ

www.budinst.gov.kh www.elibraryofcambodia.org

- បំពើផលប្រយោជន៍ជាតិ ជួយជាតិអោយរស់រានមានជីវិត
- តស៊ូផលប្រយោជន៍ជាតិ ជួយជាតិអោយរស់រានមានជីវិត
- តស៊ូប្តូរផ្តាច់ដើម្បីសុភមង្គល
- មិនសាបព្រោះនូវភាពសៅហ្មង

២. តួអង្គរស់និងស្លាប់មិនគាប់ប្រសើរ

បាដេស ថីសូន ពួកដៃជើងបារាំង

- រុកគួនសេចក្តីអ្នកឯទៃ គិតតែប្រយោជន៍ផ្ទាល់ខ្លួន
- ខ្វះចិត្តមេត្តា ករុណា រំលោភលើច្បាប់មនុស្សជាតិ
- ក្បត់ជាតិ ក្បត់ប្រជាជន បំពើផលប្រយោជន៍សត្រូវ

ផែនចំណែកជីវិតស្នេហ៍

I- សេចក្តីផ្តើម

នៅលើលោកយើងនេះគ្មានអ្វីមួយដែលនៅនឹងនរទេវាតែងតែប្រែប្រួលផ្លាស់ប្តូរឥតឈប់ឈរ ពីថ្មីទៅចាស់ ពីរឹងមាំទៅជាពុកផុយ ។ បើនិយាយពីមនុស្សវិញគឺ វាប្រែពីក្មេងទៅចាស់ជរា ពីរស់រានមានជីវិតស្រស់បស់ទៅជាមានជំងឺ ឈឺរួចស្លាប់ទៅវិញជាធម្មតា ។ ហេតុនេះហើយបានជាមានទស្សនៈមួយលើកឡើងថា «រស់និងច្បាប់ ជាច្បាប់របស់ធម្មជាតិ» ។ តើរស់និងស្លាប់បែបណាដែលគាប់ប្រសើរ និងមិនគាប់ប្រសើរនោះ ? ។ ក្នុងរឿងភូមិតិរច្ឆានតួអង្គណាខ្លះដែល មានលក្ខណៈស្របនឹងទស្សនៈខាងលើនេះ ?

www.budinst.gov.kh www.elibraryofcambodia.org

I- តួសេចក្តី

១- ពន្យល់ពាក្យ

ព្រះពុទ្ធគឺជាបុគ្គលមួយរូបដែលបានរកឃើញមាគ៌ាសំរាប់អោយមនុស្ស ចេញផុតពីដំណើរវិលកើតស្លាប់ក្នុងវាលវដ្តសង្សារ តាមរយៈការកសាងនូវកុសលផលបុណ្យលួពេលមនុស្សនៅរស់ ។ ព្រះអង្គបានបំពេញនូវបុញ្ញកម្ម ដោយរឹងប៉ាន់នូវគំនិតលោភលន់បៀតបៀន គំនិតអាត្មានិយម អោយធ្វើតែអ្វីៗ ដែលជាគុណប្រយោជន៍។ មិនតែប៉ុណ្ណោះព្រះអង្គបំពេញបានត្រឹមត្រូវនូវបារមី ទាំង១០ប្រការ ។ ការដែលព្រះអង្គអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ទាំងនេះហើយធ្វើអោយ ព្រះអង្គផុតពីទុក្ខគីលែងមានជីវិតកើតរួចស្លាប់ទេវិញ ។ ពោលគឺទ្រង់បានចូលនូវបរិនិព្វាន ។ ការរស់និងស្លាប់បែបនេះប្រសើរបំផុតដែលសត្វលោកទាំងឡាយគួរយកទៅអនុវត្តជាគំរូ ។

ទន្ទឹមនឹងនេះ ដែលក្នុងសង្គមមានបថុជ្ជនជាច្រើនដែលបានតាំងខ្លួនជាអប្រិយជន ។ គេរស់នៅសាបព្រោះតែអំពើពាលាអាវ៉ាសែបង្កទុក្ខវេទនាដល់អ្នកស្លូតត្រង់ ។ គេមិនញញើតដៃក្នុងការកាប់សំលាប់ទន្ត្រានលើច្បាប់ធ្វើអោយ សង្គមជាតិជួបនូវភាពវឹកវរមិនមានការរីកចំរើន ។ ជាក្រិត្យក្រមជនប្រភេទនេះ អាចនឹងស្លាប់ទេវិញដោយសារស្មាដៃអ្នកស្លូតត្រង់ឬត្រូវច្បាប់កាត់ទោសអោយ ជាប់គុកអោយដេកស្លាប់ក្នុងគុក ដោយពុំបានជួបប្រពន្ធកូនក្រុមគ្រួសារ ។ គីស្លាប់គ្មានន័យអ្វីទាំងអស់ ។ ការរស់និងស្លាប់របៀបនេះកំនត់ថាមិនគាប់ប្រសើរនោះ ។

នៅលើទំព័រអក្សរសិល្ប៍ភូមិតិរច្ឆាន តួអង្គមួយចំនួនដែលយើងសង្កេតឃើញថា ពេលដែលគេរស់រានមានជីវិត គេបានបញ្ចេញអស់នូវសមត្ថភាព

www.budinst.gov.kh www.elibraryofcambodia.org

ដែលមានបូជាជូនជាតិមាតុភូមិ។ ក្នុងនោះយើងឃើញមាននៅជូនជាភស្តុតាងស្រាប់ ។ អ្នកទាំងពីរបន្ទាប់ពីបានឃើញយ៉ាងច្បាស់ពីអំពើព្រៃផ្សៃរបស់បារាំងដែលប្រព្រឹត្តិមកលើទឹកដីខ្លួន ។ គេដឹងថាពួកនេះបានយកកម្មជាជាឈ្នាន់អភិវឌ្ឍន៍ប្រទេសខ្លួនតាមរយៈការប្រមូលពន្ធដារលើអ្វីៗទាំងអស់រាប់ទាំងមនុស្សផង ។ គេចាំច្បាស់ទៀតថា បារាំងបានយកកម្មជាជាកន្លែងប្រមូលកំលាំងពលរដ្ឋខ្មែរពេញវ័យ ធ្វើជាទាហានច្បាំងការពារអំនាចត្រួតត្រាខ្លួនលើប្រទេសនានាពិភពលោក ។

រស់នៅមើលឃើញសភាពការណ៍បែបនេះ នៅ ជួន មិនព្រងើយកន្តើយឡើយគេបានរៀបចំផែនការ រួមជាមួយប្រជារាស្ត្រជាច្រើននាក់ សំរេចចិត្តត្រូវតែតស៊ូវាយកំចាត់អាណានិគមនិយមអោយចេញផុតពីកម្ពុជា ។ ឆន្ទះនេះធ្វើអោយគេពិចារណាថា ប្រសិនបើខ្លួនស្លាប់ក៏ត្រូវតែធ្វើកិច្ចការនេះមិនរាថយ។ ចំនុចនេះអាចអោយយើងទាញបានថា « ការរស់របស់នៅជូនគឺរស់តាប់ប្រសើរ » ។ រស់ដោយមិនចង់អោយនរណាត្រួតត្រាធ្វើបាបខ្លួននិងជាតិតាមអំពើចិត្ត ។

ទន្ទឹមនឹងនេះនៅនឹងជួននេះឯងដែលបានបញ្ជាក់សំដីចេញពីមាត់របស់ខ្លួនថា «គេមានចំណេះក្បាច់គុនពេញខ្លួន តែគេពុំយកចំណេះនោះទៅបង្កវិនាសកម្មដល់អ្នកស្លូតត្រង់ឡើយ ។ គេប្រើវាសំរាប់កំចាត់ជនពាលធ្វើបាបអ្នកទន់ខ្សោយប៉ុណ្ណោះ » ។ ពាក្យប៉ុន្មានម៉ាត់នេះបញ្ជាក់អោយយើងដឹងយ៉ាងច្បាស់ថាពួកគេជា អ្នកដែលរស់ដោយមិនសាប ព្រោះនូវភាពសៅហ្មងដល់សង្គមជាច់ខាត ។ ជំហរបែបនេះត្រូវបានក្រុមរួមចលនាតស៊ូនៅជូនមានទំនុកចិត្តយ៉ាងខ្លាំងលើរូបគេ ។ គេគិតថា ការរស់របស់នៅជូនពិតជាអស្ចារ្យគួរអោយកោតសរសើរក្រៃលែង ។

www.budinst.gov.kh www.elibraryofcambodia.org

កំហឹងនៃការឈឺចាប់ បង្កើតជាកំលាំងដ៏ខ្លាំងក្លានៅ ជួននិងក្រុមតស៊ូ រួមថែមទាំងមាននារីដែលមានប្តីត្រូវបារាំងចាប់ដាក់គុក និងធ្វើទារុណកម្ម នោះបានវាយសំរុកទៅលើបារាំងដែលមានបាដេសជាប្រមុខ អោយជួបនូវ គ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ ។ ឧបទ្ទវហេតុជាប្រវត្តិសាស្ត្របានបញ្ចប់បាដេសត្រូវ ស្លាប់ ។ មរណភាព របស់បាដេសរុញច្រានអោយ រ៉ែដង់ស៊ីដង់ស៊ុបប៉េយើរ បារាំងចេញបញ្ជាសំលាប់ក្រុមតស៊ូ ។ មេចលនាតស៊ូជាច្រើនត្រូវបារាំងចាប់ បញ្ជូនអោយទៅស្លាប់នៅគុកកោះត្រឡាច ។ ទាក់ទងនឹងការស្លាប់នៃក្រុម ចលនាតស៊ូខ្មែរចាត់ទុកថា ជាការស្លាប់ដ៏គាប់ប្រសើរ ។ ដោយពួកគេស្លាប់ ដើម្បីមាតុភូមិស្លាប់ដើម្បីបុព្វហេតុទាមទារសិទ្ធិសេរីភាពនិងឯករាជ្យជូនជាតិ។ ស្លាប់ក្រោមទង់ជាតិ ។ ការស្លាប់របស់ គេត្រូវបានចារឹកឈ្មោះមរណជននោះ ក្នុងក្រាំងមាសនៃប្រវត្តិសាស្ត្រជាតិ ។ ស្លាប់ក្នុងនាទីជាវីរជនជាកុលបុត្រ ដ៏ឆ្នើមនៃទឹកដីអង្គរ ។

ផ្ទុយទៅវិញ ការរស់និងស្លាប់មិនគាប់ប្រសើរក្នុងរឿងភូមិតិរច្ឆានចង់ សំដៅលើជនបរទេសមានបាដេសជាតំណាង និងបរិវារបារាំងដែលជា ជនជាតិខ្មែរ ។ ការរស់និងការស្លាប់របស់បាដេសមានហេតុផលច្បាស់លាស់ ណាស់ ។ បារាំងរូបនេះបានប្រើអំណាចរបស់ខ្លួនបង្កទុក្ខវេទនាដល់រាស្ត្រខ្មែរ។ គេបានធ្វើអោយខ្មែរ ជួបតែនឹងឥនភាព គ្មានសុភមង្គល ។ តួយ៉ាងដូចជាគេ បានយកតួនាទីដែលខ្លួន មានបញ្ជាអោយបរិវារ ខ្លួនវាយដំច្រំធាត់ខ្មែរឥតត្រា ប្រណីចាប់ដាក់គុក ឬសំលាប់ចោលដោយឥតវែកញែករកខុសត្រូវ ។

ធម្មតាទេ ការសាងបាបកម្មពេលរស់នៅ លុះដល់ស្លាប់ទៅត្រូវទទួលនូវ ផលកម្មតាមនេះដែរ ។ នេះជាពុទ្ធឱវាទរបស់ព្រះសម្មាសម្ពុទ្ធនៃយើង ។ យ៉ាង ណាមិញបាដេសត្រូវបានរងនូវរន្ទះកទ្ធារបស់នាងនី នាងបីប្រកាច់ត្រដរខ្សល់

www.buddhist.gov.kh www.elibraryofcambodia.org

ស្លាប់ដូច ឆ្កែ ឆ្មា ។ ការស្លាប់របៀបនេះពុំមានតំលៃគាប់ប្រសើរបន្តិចសោះឡើយ ។ បាដេស ស្លាប់ទៅបានពង្រីកនូវសេចក្តីរីករាយដល់រាស្ត្រខ្មែរប្រៀបបាន «នឹងការច្រានដុំ សិលាដ៏ធំមហិមាពីដើមទ្រូង» របស់គេ ។ ពោលគឺការស្លាប់របស់បាដេសមិនសូម្បីតែរាស្ត្រខ្មែរដែលរងទុក្ខនោះ មិនគាំទ្រនោះទេ ទោះបីមេធាវីដែលជាជនជាតិ បារាំងដូចគ្នានោះមិនគាំទ្រដែរ ។ ដូចជាលោក «តែសាំងហ្ស៊ីល្លី » លរតារហ្សក់ កុប ឌុយហ្វុង » ជាដើម ។ លោកបានអះអាងថា «បារាំងមានកំហុសដោយ ប្រព្រឹត្តលំអៀងចំពោះរាស្ត្រខ្មែរចំពោះការបង់ពន្ធ បើប្រៀបធៀបប្រទេសនៅឥណ្ឌូចិនដូចគ្នា » លោកឌុយហ្វុងថា «បាដេសនេះឯងដែលមិនគោរពពាក្យសន្យារបស់ខ្លួន ព្រមទាំងរំលោភលើសិទ្ធិមនុស្សថែមទៀត ទើបរាស្ត្រក្រោកតទល់បែបនេះ» ។ ដូចនេះអ្នកប្រាកដនិយមទាំងបីរូបខាងលើនេះ សុទ្ធតែមានគំនិតឯកច្ឆ័ន្ទមិនអោយតំលៃទាល់តែសោះ ចំពោះមរណភាពរបស់បាដេស ដោយសំដែងនូវទស្សនៈថ្កោលទោសបាដេសគ្រប់ៗគ្នា ។ ប្រការនេះអាចអោយយើងទាញបានម្តងទៀតថា «ការស្លាប់របស់បាដេសគឺមិនគាប់ប្រសើរ » ។

អមជាមួយគ្នាដែរ យើងឃើញពីការរស់និងការស្លាប់របស់ថីសួនដែលអ្នកនិពន្ធបានតួសបញ្ជាក់ប្រាប់យើងដែរនោះ អាចកាត់ទុកបានថា «ការរស់និងស្លាប់របស់គេមិនគាប់ប្រសើរ » ផងដែរ ។ ហេតុអ្វីបានជាហ៊ានថាបែបនេះ ? ។ ពីព្រោះ ពេលដែលថីសួននៅរស់គ្មានចិត្តមេត្តាអាណិតអាសូរដល់រាស្ត្រខ្មែរដូចគ្នាឡើយ ។ គេបានដាក់ខ្លួនបំរើផលប្រយោជន៍បរទេសក្បត់ជាតិក្បត់ប្រជាជនឯង។ ជាភស្តុតាងថីរូបនេះងុបងុលនឹងអំនាចដែលបារាំងបន្តុបដោយគេបានតំឡើងឋុង មពោញចង្កូមខាំត្របាក់ខ្មែរស្លូតត្រង់អោយមានគ្រោះថ្នាក់ដោយសារសំជីខ្លួន ។ ដូចដែលសំជីរបស់បាតុភូមិក្រាំងលាវពេល

www.budinst.gov.kh www.elibraryofcambodia.org

ដែលដេញតាមទាន់ថីសួន នៅលើ កុដិព្រះសង្ឃមកអាក្រាតថា «ហ៊ឹះ ! លោកថី លោកចៃបារាំង លោកឯងប៉ិនបក ប្រែណាស់ចេះយកគាប់គួរចៅហ្វាយនាយអោយលោតកញ្ជ្រោល សង្កិតសង្កត់ខ្មែរគ្នាឯង ។ នែថីកំនត់ ! ទាល់តែជីងខ្លួនថា ជិតស្លាប់ទើបថីឯងប្រើពាក្យទន់ភ្លន់មក រកយើងប៉ុន្តែមុននេះបន្តិចថីឯងធ្វើឫកបារាំង ឬលើសបារាំងទៅទៀត» ។ ពាក្យពេចន៍គ្រប់ម៉ាត់ទាំងនេះអាចអោយយើងវិនិច្ឆ័យបានថា ថីសួនទាំងខ្លួននៅរស់ និងពេលស្លាប់ទៅវិញ គឺគ្មានបានធ្វើអ្វីល្អសោះ ក្នុងនាមខ្លួនដែលមានឈាមជ័រជាខ្មែរ ។ ចំនុចនេះហើយធ្វើអោយជីវិតរបស់គេទាំងនៅរស់និងបញ្ចប់ទៅវិញក្រោម ទំងន់នៃពាក្យសំដីប្រមាថពីរាស្ត្រខ្មែរ ស្នេហាជាតិគ្រប់ៗមាត់ ។

៣- សរុបការពន្យល់

រួមមក «ការរស់និងស្លាប់ជាច្បាប់របស់ធម្មជាតិ » ពិតមែនហើយ ។ តែបំនាច់នឹងរស់ ឬស្លាប់ត្រូវអោយមានលក្ខណៈគាប់ប្រសើរផង ដោយត្រូវតែហ៊ានធ្វើអ្វីៗទាំងអស់ដើម្បីសេចក្តីសុខដល់មនុស្សទូទៅ ។ បើរស់និងស្លាប់ត្រូវធ្វើតែពិចារណាជាអំពើល្អត្រឹមត្រូវ កុំប្រព្រឹត្តបំពារបំពានលើអ្នកដទៃ ។ ការដែលរស់ និងស្លាប់មិនគាប់ប្រសើរមិនគួរនឹងអោយមានតទៅទៀតទេ ។ ដោយការរស់និង ការស្លាប់របៀបនេះ នាំអោយអំពល់អ្នកផងទាំងពួង ។ រស់ដោយការជាញ់យក ចំណេញលើលើសឈាមអ្នកដទៃ ។ ស្លាប់ដោយនាំយកទៅវិញនូវភាពស្មុយអសោច និងភាពគួរអោយស្អប់ខ្ពើមបំផុត ។ ស្លាប់និងរស់របៀបនេះឈ្មោះថា «រស់និងស្លាប់ទំងន់ផែនដី » ។

III- <u>យោបល់</u>

ទស្សនៈដែលលើកឡើងក្នុងប្រធាននេះ ជាទស្សនៈប្រកបទៅដោយ

www.budinst.gov.kh www.elibraryofcambodia.org

អត្ថន័យដ៏ខ្ពង់ខ្ពស់បំផុត ។ ព្រោះតាមរយៈនេះ វានឹងក្លាយទៅជាប្រទីបបំភ្លឺផ្លូវ
មនុស្សគ្រប់ៗរូបអោយមានគំនិតភ្ញាក់រលឹក កែច្នៃខ្សែជីវិតរបស់ខ្លួនអោយរស់
នៅមានកិត្តិយស និងស្លាប់ទៅវិញក្នុងកិត្តិយស ។ មនុស្សត្រូវចៀសវាងយក
ជីវិតដ៏មានតំលៃរបស់ខ្លួនទៅប្រើក្នុងផ្លូវអបាយមុខផ្ទុយពីច្បាប់ ។ បើធ្វើបាន
បែបនេះលុះ ទីអវសានៃជីវិតទៅអ្នកដឹង ទទួលបានកិត្តិនាមដ៏រុងរោចវ័ក្នុង
សង្គមមនុស្សជាក់ជាពុំខានឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រធានទី១៣ : «បញ្ហាជីវិបរិះពីគំនាបសង្គម និងបញ្ហាស្នេហាជាប្រធានបទដ៏សំខាន់ក្នុងចំនោមប្រធានបទផ្សេងៗទៀតដែលអ្នកនិពន្ធខ្មែរយើងយកមកធ្វើជាមធ្យោបាយបង្កើតរឿង » ។ ចូរបង្ហាញដោយលើកឧទាហរណ៍ពីរឿងដែលអ្នកបានសិក្សារួចមកហើយ ។

គំរោងតែង

១- ពន្យល់ពាក្យ

បញ្ហាជីវិបរិះពីគំនាបសង្គម : រំដោះខ្លួនអោយផុតពីការជិះជាន់

បញ្ហាស្នេហា : ការស្រឡាញ់គ្នាគ្មានអ្វីផ្តាច់បាន

២- បកស្រាយ

*** ន័យទូទៅ**

- ប្រធានបទផ្សេងៗនៃអក្សរសិល្ប៍ខ្មែរជំនឿការព្រាត់ប្រាស់សង្គ្រាម . . . ។

*** ប្រធានបទនៃអក្សរសិល្ប៍**

ក) រឿងទុំទាវ

រឿបរិះពីគំនាបសង្គម ស្នេហា

- ទំនៀមទំលាប់បិទសិទ្ធិ : - ស្នេហាទុំទាវ ធ្វើអោយមានការប្រទាក់ ប្រទងសាច់រឿងពីដើមចប់ភ្ជាក់ផ្តើលពីមជ្ឈដ្ឋានរាស្ត្រព្រះរាជា

ខ) រឿងរាមកេរ្តិ៍

- ទាងសិតាមិនរួមរស់នឹងព្រះរាម : - ស្នេហាធ្វើអោយកើតសង្គ្រាមឥតឈប់

www.budinst.gov.kh www.elibraryofcambodia.org

ទាមទារនូវតំនិតរបស់ប្តី	រវាងព្រះរាម និងក្រុងភាពណ៌ស្លាប់ មនុស្សជាច្រើន

គ) រឿងភូមិគិរហ្លាន

- បាដេសជិះជាន់ បង្កនូវការតស៊ូរបស់រាស្ត្រខ្មែរឥតឈប់ឈរ	- ក្តីស្នេហាចំពោះប្តីធ្វើអោយនាងនីនាង ប៊ី ប្រថុយស្លាប់

ឃ) រឿងភូលីកំឆែង

- ការបង្កវិនាសកម្មរបស់បារាំង ជប៉ុន អាមេរិក ជាបុព្វហេតុបង្កើតរលកតស៊ូជាប់រហូត - ពីពីភាព អយុត្តិធម៌ បង្កពីមន្ត្រីខ្មែរ	- ក្តីស្នេហាជំរុញអោយនាងហេងស្លាប់ម៉ឹងត្រូវចេញតស៊ូ

ច) រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់

- សមរីខ្លួន ពិជីវភាពលំបាកការក្បត់ចិត្ត នៃពួកអ្នកនយោបាយនាយទុន - ប្រែពីវេទនាបានសុខសាន្ត	- ក្តីស្រឡាញ់ប្រពន្ធធ្វើអោយសមរងនូវទារុណកម្មភាពគ្រាំគ្រាចិត្ត ហ៊ានធ្វើអ្វីៗដើម្បីប្រពន្ធ



www.budinst.gov.kh www.elibraryofcambodia.org

សេចក្តីអធិប្បាយ

I- សេចក្តីផ្តើមរឿង

មុននឹងតាក់តែងរឿងនីមួយៗអ្នកនិពន្ធតែងតែបានគិតរួចជាស្រេចនូវគោលគំនិតធំៗ ទុកជាគ្រឹះសំរាប់ប្រទាក់បញ្ហាក្នុងរឿងអោយអ្នកមានភាពណែងណងគ្នា ពីបញ្ហាមួយទៅបញ្ហាមួយទៀត ធ្វើអោយអានធូរល់តាមដានសាច់រឿងរហូត ទីបញ្ចប់ ។ ក្នុងចំនោមគោលគំនិតដែលអ្នកនិពន្ធខ្មែរជ្រើសរើសមកបញ្ចូលក្នុង រឿងរបស់គាត់មួយផ្នែកធំគឺបញ្ហារើបំរះពីគំនាបសង្គម និងបញ្ហាស្នេហា» ។តើរឿងណាខ្លះដែលអ្នកនិពន្ធខ្មែរបាន ប្រើប្រាស់នូវប្រធានបទទាំងពីរនេះ ? ។ បញ្ហាទាំងពីរបានរំលេចឡើងនូវរឿងរ៉ាវអ្វីខ្លះ ? ។

II- តួសេចក្តី

១- ពន្យល់ពាក្យ

«**បញ្ហាស្នេហា**» ចង់ដៅទៅលើការស្រឡាញ់រវាងឆ្លងដោយមនោសញ្ចេតនា រវាងមនុស្សប្រុស និងស្រីក្នុងភាវតមួយដ៏ខ្ពស់ រហូតក្លាយខ្លួនជាគូអនាគតបង្កើតជាកូនចៅតពូជពង្ស ឬចង់យោលទៅលើសេចក្តីស្រលាញ់គ្មានដែលគ្មានអ្វី មួយមកបំបែកបាន ។ ឯ«បញ្ហារើបំរះពីគំនាបសង្គម» មានន័យថា ការរំដោះខ្លួនអោយរួមចាកផុតពីការគាបសង្កត់ទាំងផ្លូវកាយចិត្តនឹងស្មារតីដោយសារទំលាប់ ចាស់គំនិតឈ្លានពានភាពអយុត្តិធម៌ផ្សេងៗជាដើម ។ ក្នុងន័យនេះយើង អាចដឹងពីទស្សនៈប្រធានគេចង់និយាយថាអ្នកនិពន្ធខ្មែរយើងបានយកបញ្ហារំដោះ ខ្លួនអោយផុតពីភាពអន់ថយអសកម្ម និងបញ្ហាស្រលាញ់គ្នាក្នុងនាទីជាប្តីប្រពន្ធ គ្មានអ្វីមកវារាំងបាន ធ្វើជាគោល

www.budinst.gov.kh www.elibraryofcambodia.org

គំនិតស្នូលសំរាប់បង្កើតរឿង ព្រមទាំងធ្វើអោយ រឿងគាត់មានការប្រទាក់ប្រឡាគ្នាពីបញ្ហាមួយទៅបញ្ហាមួយទៀត ពីដើមរឿងរហូតដល់បញ្ហារឿង ។

II-<u>បកស្រាយ</u>

«គំនាបសង្គម» មានប្រើនបែប ច្រើនយ៉ាងណាស់ ។ ការដែលអ្នកមានទ្រព្យ មានអំណាចធ្វើបាបលើអ្នកទន់ខ្សោយការ ដែលបារាំងបំបិទសិទ្ធិយុវជនក្នុងការ រើសគូស្រករការបង្ខំមនុស្សអោយទទួលយកនូវជំនឿមិនសមហេតុផលជាដើម ។ អ្វីៗទាំងនោះហៅថា «គំនាបសង្គម» ។ ស្នេហាក៏មានច្រើនករណីដែរ ។ ស្នេហាប្លន់ផ្តាច់ឆ្លងកាត់ឧបសគ្គធំ ស្នេហាបង្ខំចិត្ត ស្នេហារាត់រាយ ស្នេហាក្បត់ចិត្ត ស្នេហាការិន្ទះ ។ ទាំងអស់នេះសុទ្ធតែជាដើមហេតុធ្វើអោយ មានការប្រទូសរ៉ាយគ្នា ឥតឈប់ឈរ រវាងមនុស្ស១ក្រុមទៅមនុស្សមួយក្រុមទៀត ។ បញ្ហានេះពុំមែនជារឿងអាក្រក់នោះទេព្រោះវាជារឿងរបស់ធម្មជាតិ ដែលមនុស្សម្នាក់ៗ ត្រូវជួប ដោយចៀសពុំរួច ។

អ្នកនិពន្ធរឿងទុំទាវបានយកនាងទាវជាបច្ច័យបង្កើតទំនាស់រវាងអ្នកធំនិងអ្នកតូច រវាងម្តាយនិងកូន រវាងគ្រូនិងសិស្ស ។ យ៉ាងណាមិញក្តីស្នេហ៍របស់ទុំលើទាវ និងទាវចំពោះទុំជំរុញអោយគេហ៊ានជំនះនឹងរបាំងប្រពៃណី «ទុំលួចសីកមិនស្តាប់គ្រូទាវហ៊ានតវ៉ានឹងបញ្ហាម្តាយដែលតំរូវអោយខ្លួនរៀបការជាមួយបុរសដែលខ្លួនមិនស្រលាញ់ » ។ បញ្ហាទាំងពីរនេះហើយបានធ្វើអោយសាច់រឿងប្រទាក់គ្នា ពីមួយទៅមួយរហូតដល់ទុំទាវស្លាប់រួចមានការជំនុំជំរះក្តី ដោយផ្តាល់របស់ព្រះរាជាចំពោះអ្នកដែលបានបំពានលើរាជអាជ្ញា។

ចំពោះរឿងរាមកេរ្តិ៍ខ្មែរវិញបញ្ហារើបំរះពីគំរាមសង្គមនិងបញ្ហាស្នេហាបានក្លាយទៅជារំលកដ៏ធំបំបែកនូវរឿងរ៉ាវច្រើនស្មេកស្តុះ។នាងសិតាបដិសេធ

www.budinst.gov.kh www.elibraryofcambodia.org

មិនរួមរស់ជាមួយព្រះរាមនៅឡើយបញ្ចប់ ព្រោះតែព្រះរាមពុំយល់ពីតំលៃនៃចិត្តភក្តីភាពរបស់ខ្លួន ។ ព្រះរាមធ្វើអោយនាងខឹងនឹងការពិសោធច្រើនលើកច្រើនសាពីចិត្តស្នេហារបស់នាងចំពោះព្រះរាម ។ ក្តីស្នេហានៃតួអង្គច្រើនលើរូបនាងសិតាម្នាក់ធ្វើអោយមានការល្បងវិទ្វិ ដ៏គ្រឹកគគ្រេងធ្វើអោយសង្គ្រាមមួយយ៉ាងធំ តកូនតចៅរវាងព្រះរាមនិងរាពណ៍ ធ្វើអោយភាគីទាំងសងប្រើនូវកលយុទ្ធប្លែកៗ ស្លាប់អស់កូនចៅ បងប្អូននិងរេហ៍ពលជាច្រើន ។ បញ្ហាភ្លោះនេះបង្កើតនូវការ វិនិច្ឆ័យផ្សេងៗពីគ្នាលើបុគ្គលិកលក្ខណៈសម្បត្តិនៃតួទំនាស់ទាំងពីររបស់មជ្ឈ ដ្ឋានអ្នកសិក្សាជាច្រើន ។

បើពិនិត្យក្នុងរឿងភូមិគិរច្ឆាន រឿងតួលីកំនែនរឿងព្រះអាទិត្យថ្មីការតស៊ូប្រឆាំងកំទេច ពួកអ្នកបង្កអំពើយុត្តិធម៌ ពួកឈ្លើងហុតឈាមសង្គមដើម្បីជាប្រយោជន៍ ឬមនុស្សជាតិគឺជាដើមចមនៃសាច់រឿងរបស់អ្នកនិពន្ធក្នុងរឿងទាំងបី ។ លោកឱកគាម, ខៀក អំ លោក អ៊ឹម ថុក លោកសួន សុរិន្ទ សុទ្ធតែមានទស្សនៈព្រមគ្នា យកប្រធានបទបញ្ហាលើបំរែពីតំរាបសង្គមជាស្នូលរឿងគាត់ ។ ជាក់ស្តែងរឿងភូមិគិរច្ឆានបានបង្ហាញថាបារាំងជាដើមហេតុធ្វើអោយមានទុក្ខដល់ខ្មែរ តាមរយៈរូបភាពផ្សេងៗ ។ ខ្មែរដែលជាអ្នករងគ្រោះមិននៅស្ងៀមអោយ គេធ្វើបាបតាមអំពើចិត្តឡើយ ។ ក្នុងនាមជាម្ចាស់ទឹកដីគេបានក្រោកឡើងកំចាត់ ពួកនោះអោយវិនាស ។ គឺបានធ្វើអោយបាដេសស្លាប់ ។ ការស្លាប់របស់បាដេស កើតពីការរើបំរះ បង្កនូវបញ្ហាថ្មីមួយទៀតគឺការដាក់ទណ្ឌកម្មរបស់មេត្រួតត្រាបារាំងយ៉ាងធ្ងន់ធ្ងរលើប្រជារាស្ត្រខ្មែរនៅភូមិក្រាំងលាវ ។

ឯរឿងតួលីកំនែនមនិខុសពីរឿងភូមិគិរច្ឆានឡើយ ។ ការឈ្លានពានកាន់យកចំនេញតត្រាប្រណីនៃមហាប្រទេស រួមនិងជនក្បត់ជាតិខ្មែរបានពួត

www.budinst.gov.kh www.elibraryofcambodia.org

ផ្ទុំ កើតជាភ្លើងកំហឹងដល់លីម ម៉ឺង នួជួងរួម នឹងខ្មែរ គ្រប់ច្រកល្ហកកំទេច ពួកទាំងនោះវិញ ។ សកម្មភាពបែបនេះកំនត់កំនើតតាំងពីជប៉ុន ប្រើល្បិចយកខ្មែរធ្វើជាគួលី កំនែនពួកខ្មែរឧទិកាសនិយមឆ្លៀតយកចំនេញពីការងារនេះ ។ បារាំងអាមេរិករួមគ្នាបំបាត់ជប៉ុន ។ ខ្មែររួមគ្នាបណ្តេញនេះរហូត រកឃើញជ័យជំនះចុងក្រោយ នៅឆ្នាំ១៩៥៣ ។

ដោយឡែកសមជាអ្នកដែលទទួលរងនូវសោកនាដកម្ម ការខកចិត្ត ជាច្រើនលើកច្រើនសា ។ ជួបនូវស្ថានភាពបែបនេះគេបានពុះពារជានិច្ច ។ ស្ថានភាពបីបិះនេះគឺមានជាហូរហែ ដូចជាសមត្រូវត្រដរអស់ក្នុងនាទីជា កម្មករឆាក់ ស៊ីក្លូប្រឆាំងនឹងពួក ថៅកែដែលមានចិត្តកាច សាហាវលើប្រពន្ធ ខ្លួន ក៏ដូចជា កម្មករួមអាជីព ។ សមបានបើកកកាយពីចិត្តខ្វៅច្រេះនៃតំនាង រាស្ត្រដែលខ្លួន បានបោះឆ្នោតអោយ ។ ទាំងអស់នេះសុទ្ធតែជាមែកធាងនៃ ការរើបិះពីគំនាបសង្គមនេះឯង ។

លើប្រធានបទ បញ្ហាជាមធ្យោបាយបង្កើតរឿង យើងឃើញថា អ្នក និពន្ធក្នុងរឿងថ្នាក់ទី១២ ច្រើនផ្តោតទៅលើការស្រលាញ់ក្នុងនាទីប្រពន្ធចំពោះ ប្តីនិងគួកំនាន់ចិត្តពុំទាន់រៀបការ ។ នាងនី នាងប៊ី នាងតន់ សុខចិត្តទ្រាំទ្រនូវ ការលំបាកវេទនាសព្វបែបយ៉ាងក្នុងន័យ បង្ហាញពីសេចក្តីស្រលាញ់ខ្លួនចំពោះ ប្តីដែលកំពុងចិតក្នុងការធ្វើបាបការឃុំឃាំងខ្លួនរបស់បារាំង ។ នាងហេងព្រម រត់តាមជាមួយអនាគត ឱពុកក្មេកម្តាយក្មេករហូតដល់ស្លាប់ខ្លួន គឺគំនិតរក្សា ចិត្តស្រលាញ់ស្មោះស្ម័គ្រនិងលីម ។ ម៉ឺងដែលចេញទៅតស៊ូ ក្រៅពីគំនិតចង់ ជួយជាតិគឺនៅមាន គំនិតមួយទៀតចង់បំពេញនូវឧត្តមគតិគួស្នេហ៍ខ្លួនគឺអ្នក គ្រួគ្រួរស់ ។ ការរៀបរាប់ ដោយត្រួសៗបែបនេះជា ភស្តុតាងច្បាមអោយ ឃើញថា បញ្ហាស្នេហាជាកម្មវត្ថុទី២ បន្ទាប់ពីបញ្ហាបីបិះ ពីគំនាបសង្គម

www.budinst.gov.kh www.elibraryofcambodia.org

ដែលអ្នកនិពន្ធនៃអក្សរសិល្ប៍ថ្នាក់ទី១២ យកមកធ្វើជាមធ្យោបាយបង្កើតរឿងគាត់នោះ ។

៣- <u>សរុបការពន្យល់</u>

រួមសេចក្តីមកបញ្ហាជីវិតពីគំនាបសង្គមនិងបញ្ហាស្នេហាជាប្រធានបទដែលអ្នកនិពន្ធយកមកបង្កើតរឿងគាត់មែន ។ បញ្ហាទាំងពីរនេះពុំមែនជាបញ្ហាកំប៉ិកកំប៉ុកនោះឡើយ ។ ដោយមនុស្សម្នាក់ៗដែលរស់ក្នុងសង្គមតែងត្រូវការសិទ្ធិ សេរីភាពត្រូវការរស់ក្នុងភាពជាអ្នកទទួល ខុសត្រូវក្នុងជីវិតខ្លួនក្រុមគ្រួសារ និង ជាតិទាំងមូល ។ ម្យ៉ាងទៀតមនុស្សចាំបាច់ត្រូវមានស្នេហាសំរាប់ជាឱសថ ផ្តុះផ្សារជីវិតកុំអោយរងាងកា ។ ពិសេសគឺដើម្បីរក្សាពូជពង្សមនុស្សអោយមានជានិច្ចលើលោកសន្និវាសយើងនេះ ។

III-<u>យោបល់បញ្ចប់</u>

ឆ្លងតាមការបកស្រាយរួច ហើយយើងអាចវាយតំលៃបានថាការដែលអ្នកនិពន្ធខ្មែរយកបញ្ហាជីវិតពីគំនាបសង្គម និងបញ្ហាស្នេហា ធ្វើជាប្រធានបទក្នុងការបង្កើតរឿងគាត់ ជាគំនិតត្រឹមត្រូវល្អណាស់ ។ ព្រោះការបង្ហាញនូវបញ្ហាទាំងពីរនេះអាចជាផ្លូវនាំជីវិតមនុស្សអោយទៅជួបនូវវឌ្ឍន - ភាព ។ បញ្ហាទាំងពីរវ៉ា នឹង អាចក្លាយជាឧបទេស នៃនាំមនុស្សត្រង់ប្រអោយមានស្មារតីធ្មឹនលឿនទៅមុខមិនបណ្តោយអោយជនអាក្រក់ណាមួយឆ្លៀតយកចំនេញលើខ្លួនបាន ហើយនិង មានបទពិសោធន៍បរិបូរទាញយកផលពីរឿងរ៉ាវស្នេហា ដែលសត្វលោកទាំងមូល ត្រូវប្រទះដោយខានពុំបាននោះទៀតផង ។

www.budinst.gov.kh www.elibraryofcambodia.org

ស្វែងយល់ប្រធានពិភាក្សា

I-<u>សេចក្តីផ្តើម</u>

- លំនាំបញ្ហា
- ចំនួលបញ្ហា
- ចំនោទបញ្ហា
- តើមតិនេះត្រឹមត្រូវទាំងស្រុងដែរឬទេ (ប្រធានមតិ១)
- តើបណ្តាមតិទាំងពីរមតិណាសមហេតុផលជាងគេ?(ប្រធានមតិ២)

II-<u>ខ្លួនសេចក្តី</u>

១- មតិស្របឬមតិទី១	២- មតិផ្ទុយ ឬមតិទី២
ក) ពន្យល់ពាក្យ- សំរួលមតិទី១	ក- បង្ហាញមតិទី២- សំរួលមតិទី២
ខ) បកស្រាយភ្ជាប់អំនាង	ខ- បកស្រាយភ្ជាប់អំនាង
គ) សរុបមតិស្របឬមតិទី១	គ- សរុបមតិផ្ទុយ ឬមតិទី២

៣- <u>ពិភាក្សា, សំយោគមតិ, ពិភាក្សាសំយោង</u>

<u>ករណីពិភាក្សា</u>	<u>ករណីសំយោគ</u>	<u>ករណីពិភាក្សាសំយោគ</u>
- សរសេរក្នុងន័យ	- សរសេរផ្សំបញ្ចូល	- សរសេរផ្តុំមតិទាំង
លំអៀងរកមតិណា	គ្នាក្នុងន័យថា	ពីរ រួចលើកយក
ដែលសមហេតុផល	មតិទាំងពីរត្រូវមាន	មតិថ្មីមកបន្ថែមដើម្បី
ជាងគេ	ចំនុចពីរទើបត្រូវ	បំពេញលើមតិទាំងពីរ

www.budinst.gov.kh www.elibraryofcambodia.org

III-យោបល់បញ្ចប់

យោបល់ពិភាក្សា	យោបល់សំយោគមតិ	យោបល់ពិភាក្សាសំយោគ
- វាយតំលៃយកមតិ	- វាយតំលៃគាំទ្រមតិ	- វាយតំលៃគាំទ្រ
ណាមួយក្នុងចំណោម	ទាំងពីរ	មតិទាំងពីរ រួចប្រាប់
មតិទាំង ពីរ		ចំនុចបំពេញ
- ប្រាប់ពីទស្សនៈផ្ទាល់	- ប្រាប់ពីទស្សនៈផ្ទាល់	- ប្រាប់ពីទស្សនៈផ្ទាល់

ទស្សនៈលើការតែងប្រធានពិភាក្សា

ប្រធានពិភាក្សា ជួចតុលាការ ស្រាយនូវទំនាស់
អោយជនពីរនាក់ សុខចិត្តលែងទាស់ ផ្សះផ្សារទំនាស់
អោយស្រុះស្រួលគ្នា។
នាទីអ្នកតែង គ្រាន់តែសំដែង មតិនានា
ស្របតាមការយល់ ជនពីរអង្គា កុំយកខ្លួនជា
ម្ចាស់មតិឡើយ ។

ម៉ិញ លីថាន
សាស្ត្រាចារ្យវិទ្យាល័យបឹងត្របែក

www.budinst.gov.kh www.elibraryofcambodia.org

ឃ្លាធនធី១៤ :គេថា« មានលុយមានសុភមង្គលនិងឈ្នះលើអ្វីៗទាំងអស់ »។
តើអ្នកយល់ដូចម្តេចដែរ? ចូរពិភាក្សាភ្ជាប់ឧទាហរណ៍ពីអក្សរសិល្ប៍ថ្នាក់ទី១២ ។

គំរោងតែង

១- មតិស្រប

ក- ពន្យល់ពាក្យ

- លុយ = ក្រដាស់ប្រាក់ចាយវាយ
- សុភមង្គល = មង្គលល្អ, សេចក្តីសុខចំរើន

ខ- បកស្រាយ

*សង្គមមនុស្ស

- ទិញសំភារៈប្រើផ្ទះសមរម្យ ជួលមនុស្សប្រើ ស្រនុកកាយ
- រួចពីទុក្ខនានា ឈ្នះសត្រូវគ្រប់ទិសទី

*អក្សរសិល្ប៍ទី១២ រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់

- ហួ ថៅកែហុក សំបូរសម្បត្តិ រួចពីការលំបាក ប្រែសជាខ្មៅបាន
- សមគ្មានលុយស្លាប់ប្រពន្ធ មិនអាចអោយពេទ្យនានាមកជួយប្រពន្ធបាន

រឿងថៅកែចិត្តចោរ

- បង្វែរការពិតបាន លុបលាងអំពើព្រៃផ្សៃបាន

គ- សរុបមតិស្រប

២- មតិផ្ទុយ

ក- បង្ហាញមតិផ្ទុយ

- លុយពុំសុទ្ធតែផ្តល់សេចក្តីសុខ ជោគជ័យដល់មនុស្សទេ

www.budinst.gov.kh www.elibraryofcambodia.org

ខ- <u>ឧបត្ថម្ភរាយ</u>

*សង្គមមនុស្ស

- មានលុយពុំអាចទិញយកសញ្ញាប័ត្រ ឬចំនេះចូលខ្លួនដោយការខ្ជិលច្រអូសរៀន ។

- លុយ ពុំអាចទិញជីវិតបាន

*អក្សរសិល្ប៍ទី១២

រឿងគូលីកំនែន

- លុយពុំអាចទិញមនុស្សមានភក្តីភាពស្មេហាដូចនាងហេង

- លុយជាសាំងដុតកំហឹងមនុស្ស (បារាំង)

រឿងថៅកែចិត្តចោរ

- លុយពុំអាចទិញឧត្តមគតិមនុស្សបាន

- លុយពុំអាចជួយបិទបាំងជិតទាំងស្រុងនូវអំពើអាក្រក់មនុស្ស

៣- ពិតាក្សា សំយោគ

- លុយជួយមនុស្សតែមួយគ្រា លើកមុខបានមួយភ្លែត

- សុភមង្គល សេចក្តីសុខ កើតពីការកសាងកុសលកម្ម ។

www.budinst.gov.kh www.elibraryofcambodia.org

សេចក្តីអធិប្បាយ

I- សេចក្តីផ្តើម

ក្នុងជីវិតរស់នៅរបស់មនុស្ស លុយជាមធ្យោបាយដ៏សំខាន់ដែលអាចអោយមនុស្សយកវាទៅប្រើប្រាស់ ក្នុងការទិញផ្លូវភ្នុំប្រើប្រាស់អាចធ្វើដំនើរទៅកាន់ទីឆ្ងាយៗបានដោយសុវត្ថិភាព ។ មិនតែប៉ុណ្ណោះលុយជាឧបករណ៍អោយ មនុស្សទាញយកប្រយោជន៍ ផ្សេងៗតាមដែលខ្លួនប្រាថ្នា ។ ចិតក្នុងន័យនេះទើប មានមតិមួយលើកឡើងថា «មានលុយមានសុភមង្គល និងឈ្នះលើអ្វីៗទាំងអស់» ។ តើមតិនេះត្រឹមត្រូវទាំងស្រុងដែរឬទេ ?

II-តួសេចក្តី

១- មតិស្រួប

ពាក្យ«លុយ» ក្នុងមតិប្រធានសំដៅលើក្រដាសប្រាក់ចាយវាយដែលមានការទទួលស្គាល់ជាទូទៅ ។ ឯពាក្យ «សុភមង្គល» មានថាសេចក្តីសុខចំរើន។ ពាក្យ «ឈ្នះ» សំគាល់លើជោគជ័យផងទាំងពួង ។ តាមន័យនេះមតិប្រធានគេចង់និយាយថា បើមានប្រាក់ច្រើនហើយ ប្រាក់នោះនឹងនាំមនុស្សអោយជួបសេចក្តីសុខនិងសំរេចបាននូវជោគជ័យនានាដល់អ្នកដែលមានប្រាក់ ។

ការដែលមតិប្រធានគេហ៊ានអះអាងបែបនេះដោយគេសង្កេតឃើញយ៉ាងច្បាស់ក្នុងសង្គមមនុស្សបណ្តាជនដែលសំបូរលុយគេអាចទិញមធ្យោបាយធ្វើដំនើរ អាចទិញផ្ទះសំបែង ជួលមនុស្សមកបំរើខ្លួន នាំអោយរូបគេស្រួលកាយសប្បាយចិត្ត គ្មានភ័យព្រួយនឹងការបពោលកំលាំងហត់នឿយសោះ

www.budinst.gov.kh www.elibraryofcambodia.org

ឡើយ ។ ករណីខ្លះទៀតអ្នកមានលុយអាចការពារខ្លួនគេមិនអោយមានគ្រោះថ្នាក់ផ្សេងៗ ដែលបង្កឡើងពីសត្រូវឬពីការឃុំឃាំងចោទប្រកាន់អាក្រក់ណាមួយមកលើ ខ្លួនគេបាន ។ ចំនុចនេះមានន័យថា « មានលុយមានសុភមង្គល និងឈ្នះលើអ្វីៗទាំងអស់» ។

បើពិនិត្យនៅក្នុងផ្នែរឿងថ្នាក់ទី១២វិញ ក៏មានលក្ខណៈគ្រប់គ្រាន់បំរើទស្សនៈប្រធាននេះខ្លាំងណាស់ ។ ជាក់ស្តែងក្នុងរឿងព្រះអាទិត្យថ្មីរះលើផែនដី ចាស់អ្នកនិពន្ធបានបញ្ជាក់ថា នាយហួជាអ្នកដែលមានទោសធ្ងន់ ត្រូវទទួលនូវទណ្ឌកម្ម ។ តែដោយគេមានលុយជះលើអភិបាលគុក ។ ពួកនោះបានប្រគល់កន្លែងអោយគេដេកនៅយ៉ាងស្រួល មានទាំងអ្នកជាប់គុកដូចគ្នាចំបំរើមិនអោយមានឃ្មើស ។ ក្នុងរឿងនេះផដែល ថៅកែហុកដែលបានប្រព្រឹត្តអំពើព្រៃផ្សៃលើរូបរាងកាយប្រពន្ធសម ។ ពេលនោះសមបានធ្វើការសងសឹកតាមរយៈអំពើមនុស្សឃាត ។ ប៉ុន្តែទឹកប្រាក់បែរជាបន្ធន់ចិត្តសមអោយលះបង់ការសងសឹកភ្លាម ។ មិនតែប៉ុណ្ណោះទឹកប្រាក់នេះទៀតសោត អាចបញ្ជាអោយក្រុមប៉ូលីស ល្មោភប្រាក់ចាប់អូសទាញសមមកវាយដំច្រំធាក់ជាទីងន់រួចបញ្ជូនសមក្នុងគុកបាន៣ខែទៀត ។ ប្រការនេះបញ្ជាក់ថាលុយអាចជួយថៅកែផុតពីស្លាប់ និងអាចក្រឡែខ្មៅទៅជាស ឈ្នះលើចិត្តសងសឹកដោយជោគជ័យ ។

ទន្ទឹមនឹងនេះដែររឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់បានគូសបញ្ជាក់អោយឃើញថា គហបតីសំបូរ សម្បត្តិដែលមានលុយច្រើននោះអាចពន្លុះមនុស្ស ចិត្តឆ្កែទៅខាំត្របាក់សមជាជនសប្បុរសទទួលរង់នូវរបួស និង ជាក់គុកថែមទៀត។ ចំនុចនេះក៏បានលាតត្រដាងថា លុយអាចធ្វើអោយសំបូរសម្បត្តិសំរេចបាននូវ ល្បិចខ្មៅរបស់ខ្លួនតបនឹងក្តីសប្បុរសនៃទេវតាជនម្នាក់

www.buddhist.gov.kh www.elibraryofcambodia.org

បានយ៉ាងងាយ ។ បន្ថែមពីលើនេះទៀតលោកសួន សុរិន្ទក៏បានគូសបញ្ជាក់ពីអំនាចទឹកលុយនេះយ៉ាងច្បាស់ទៀតថា ប្រពន្ធសមត្រូវឆ្លងទន្លេដែលជាលក្ខណៈធម្មតារបស់ស្ត្រីភេទ បែរជាស្លាប់ ព្រោះសមពុំមានប្រាក់ទៅអូសទាញត្រូពេទ្យ អសប្បុរសសំលឹងឃើញតែលុយមក ជួយសង្គ្រោះប្រពន្ធខ្លួនបាន ។ចំនុចនេះចង់និយាយថា ប្រសិនបើសមមានលុយវិញនោះ «ពេទ្យនរ» ពិតជានឹងជួយប្រពន្ធសមអោយរស់រានមានជីវិតមិនខាន ។ មិនតែប៉ុណ្ណោះ លុយនាំចិត្តចៅក្រមកាត់ក្តីលំអៀង ដូចពាក្យសាមញ្ញខ្មែរតែងតែនិយាយចំអកថា «ចោរប្លន់ខ្លួនម្ចាស់ជាប់គុក» នោះឯង ។

ចំនែកឯរឿងចៅកែចិត្តចោរឯណោះវិញ មតិអ្នកទី១សង្កេតឃើញថា «លុយពិតជានាំមកនូវសុភមង្គលនាំបកនូវជោគជ័យ» ពិតៗ។ជាតិកតាងគឺនៅត្រង់ចៅកែ ចិត្តចោរដែលត្រូវមានទោសពីការបញ្ជាដោយចេតនាលើពូហាំ អោយបើកឡានបុកឡានចៅកែហុងលី ។ តែចៅកែរូបនេះបែរជារួចខ្លួនឯពូហាំត្រូវមានទោសតែម្នាក់ឯង ។ តើចៅកែនេះប្រើលុយនៅពេលណា ? ទិញក្បាលនរណា ? ឈ្នះលើអ្វី ? ។ ចៅកែចិត្តចោរបានប្រើលុយពេលប៉ូលីសតាមចាប់ខ្លួនគេទៅផ្តន្ទា ទោស ធ្វើអោយពួកប៉ូលីស រវេងរវាន់បកក្បាលមកខាំត្រចាក់ពូហាំ ប្រៀបដូចឆ្កែត្រចាក់សាច់ ។ ទីបំផុតលុយធ្វើអោយចៅកែរូបនេះរួចខ្លួនក្រអេះថែមទាំងលុប លាងនូវអំពើព្រៃផ្សៃរបស់គេយ៉ាងស្អាតចែសទៀតផង ។

រួមមកលុយពិតជាទេវតាជួយមនុស្ស លុយពិតជាថ្នាំពិសេសលុយជា អាវុធដ៏សំខាន់ឈ្នះឧបសគ្គផងទាំងពួង សមតាមមតិរបស់ប្រធានបានលើកឡើងពិតប្រាកដមែន ។

www.budinst.gov.kh www.elibraryofcambodia.org

២- មតិទីពីរ

ផ្ទុយពីមតិប្រធាន មានមតិមួយទៀតយល់ថា «លុយពុំសុទ្ធតែផ្តល់នូវសេចក្តីសុខ និង ពុំសុទ្ធតែជួយមនុស្សអោយទទួលបានជោគជ័យ » ទាំងស្រុងនេះហើយ ។ មតិនេះចង់និយាយថា លុយ ជាប្រភពផ្តល់នូវសេចក្តីទុក្ខ មានលុយ ពុំធ្វើអោយមនុស្សសំរេចបាននូវ អ្វីតាមបំនងខ្លួនឡើយ ។

ករណីដូចជាបច្ចុប្បន្នដែលក្រសួងអប់រំត្រូវពង្រឹងគុណភាពអប់រំ ដែលពីមុនអ្នកមានលុយអាចទិញសញ្ញាប័ត្រអាចសូកប៉ាន់ទៅរៀននៅបរទេសដោយងាយៗ ។ តែមកដល់ឥឡូវសិស្សរៀនខ្សោយមានលុយសូក គឺ ពុំអាចទទួលបានផលទាំងស្រុងនោះទេ ។ លុះត្រាណាតែសិស្សនោះមានសមត្ថភាពពេញបរិបូរទើបសញ្ញាប័ត្ររត់ចូលដល់ដៃខ្លួនគេបាន ។ នេះជាសក្ខីភាពមួយបញ្ជាក់ថា លុយពុំសុទ្ធតែផ្តល់សុភមង្គលផ្តល់ជោគជ័យដល់មនុស្សឡើយ ។ កស្តុតាងម្យ៉ាងទៀត ទាក់ទងទៅនឹងជីវិតផ្កាល់នៃមនុស្សលោក ។ គឺមានន័យថា អ្នកមានលុយច្រើនបែរជាទទួលនូវការក្រៀមក្រំដោយសារលុយ ។ ពីព្រោះលុយធ្វើអោយចិត្តមនុស្ស កាន់តែចំបែងលើសលើម រហូតបង្កជាជំងឺតម្កាត់ជាប់ជាប្រចាំ ។ ទីបំផុតក្លាយជា ជំងឺភ្ញាំ ។ ជីវិតរបស់គេបានធ្លាក់ដល់មាក់មច្ចុរាជ ។ ពេលនោះហើយទោះបីគេ មានលុយច្រើនមហាសាលក៏គេពុំអាចទៅទិញជីវិតអោយរស់នៅមើលឃើញ ពិភពលោក បានជួបជុំក្រុមគ្រួសារតទៅទៀតឡើយ ។ រូបគេនឹងក្លាយជាសាកសព ប្រៀបដូចជាអង្កត់ខុសរកប្រយោជន៍គ្មាន ។ នេះហើយបញ្ជាក់ថា លុយពុំអាចផ្តល់សុភមង្គលនិងពុំអាចសំរេចអោយបាននូវក្តីប្រាថ្នា របស់ជនសំបូរលុយឡើយ ។

បើក្រឡេកមើលក្នុងទំព័រអក្សរសិល្ប៍ថ្នាក់ទី១២ ម្តងវិញ ។ រឿងតូលី

www.budinst.gov.kh www.elibraryofcambodia.org

កំនែន ចៅហ្វាយស្រុកគឺអ្នកមានលុយដ៏សន្ធឹកសន្ធាប់ពីការសង្កត់សង្កិនលើរាស្ត្រខ្មែរ ។ ចៅហ្វាយស្រុករូបនេះមានបំនងយកនាងហេង ជាស្រីក្រមុំព្រហ្មចារីយ៍បំរើការសប្បាយរបស់ខ្លួន ។ ប៉ុន្តែលុយរបស់មន្ត្រីពាលពុំអាចបន្ទន់ចិត្តដ៏រឹងមាំរបស់នាងហេង អោយក្លាយជាឧបករណ៍បំរើតណ្ហាខ្លួនសមតាមចិត្តដែលខ្លួនប្រាថ្នាឡើយ ។ គឺមានថាលុយគឺ វាន៍យសំរាប់តែជនល្មោភអំនាចល្មោភតណ្ហាប៉ុណ្ណោះ ។ តែចំពោះជនដែលមានឧត្តមគតិ មានភក្តីភាពដូចនាងហេងជាដើមនោះលុយថោកជាងក្រដាសកិតលាមកទៅទៀត ។ ក្នុងរឿងដដែល ពួកអាណានិគមនិយម គេចូលចិត្តប្រើលុយជាឡប់ឡែសំរាប់ទាញយកប្រយោជន៍សំរាប់ពង្រីកអំនាចខ្លួនលើជាតិដទៃ សំរាប់បន្ថយចិត្តអ្នកស្នេហាជាតិស្នេហាឯករាជ្យ អោយទន់ជ្រាយ ។ ប៉ុន្តែលុយរបស់ពួកនោះបានក្លាយទៅជាសាំងទឹងភ្លើងផុតកំទេចខ្លួនពួកនោះទេវិញទេ ។ បន្ថែមលើសពីនេះវាកាន់តែពង្រីកឆន្ទៈតស៊ូរបស់រាស្ត្រខ្មែរ អោយកាន់តែខ្លាំងក្លាកំចាត់ពួកអាណានិគមនិយមទេវិញ ។ ការបញ្ជាក់បែបនេះចង់និយាយថា លុយពុំអាចជាឈ្នាន់សំរាប់អោយពួកអាណានិគមនិយមជាន់ ឈានជើងចូលអោកបំពេញតាមបំនងមហិច្ឆតាខ្លួនបានឡើយ ។

ភស្តុតាងម្យ៉ាងទៀតនៅក្នុងរឿងថៅកែចិត្តចោរ នៅពេលដែលក្រុមនគរបាលលេចមុខដល់ផ្ទះ ថៅកែរូបនេះ គេបានប្រើទឹកលុយដើម្បីអូសទាញកម្មករអោយមកជើពពួកហំ អោយគាំទ្រខ្លួន ទំលាក់កំហុសលើពួកហំ ។ ពេលនោះលុយពុំអាច ទិញសច្ចភាពទិញ មនសិការស្រលាញ់យុត្តិធម៌របស់កម្មករទាំងអស់បានឡើយ ។ កម្មករម្នាក់ៗពុំព្រមដើរតាមសំដីរបស់ថៅកែចិត្តចោរទោះណាជាថៅកែនេះប្រៃ លុយប្រើពាក្យទន់ភ្លន់ចំពោះខ្លួនក្តី ។ នេះមកពីគេធ្លាប់បានស្គាល់ពីក្រយៅពិត របស់ថៅកែដែល «ពាក្យខាងក្រៅត្រជាក់តែចិត្តខាង

www.budinst.gov.kh www.elibraryofcambodia.org

ក្នុងភ្លៅពាល់រលាក » ។ ការលើកនូវបញ្ហានេះ ស្តែងអោយឃើញថាលុយ ពុំអាចជារនាំងសក្តិសិទ្ធិអាចបិទបាំង ជិតអំពើអាក្រក់នៃជនសំបូរប្រាក់ឡើយ។ ទោះណាជាក្នុងពេលមួយគេអាចយក លុយជាឧបករណ៍ ក៏ប៉ុន្តែពុំអាចការពារខ្លួនបានយូរអង្វែងឡើយ ។ ពីព្រោះអំពើអាក្រក់ និង លួចប្រៀបបានទឹកនឹងប្រេង ទោះបីខំក្រឡុកយ៉ាងណាក្តី ក៏ពុំអាច រលាយចូលគ្នាបានឡើយ ។ យ៉ាងណា មិញលុយពុំសុទ្ធតែអាចជួយមនុស្សអោយ មានសុភមង្គល ឬសំរេចជោគជ័យ តាមក្តីប្រាថ្នានៃមនុស្សនោះទេ គឺវាបានតែមួយពេលដ៏ខ្លីប៉ុណ្ណោះ ។

តាមរយៈការការបង្ហាញប៉ុណ្ណោះជាភស្តុតាងសអោយឃើញថាលុយ អាចអោយមនុស្សជួបអពមង្គលនិង ពុំអាចសំរេចបានតាមសំនូមពរទាំងស្រុង ឬឈ្នះលើអ្វីៗនោះទេ ។

៣- ពិគាក្សារសំយោគ

រួចមកហើយមតិនីមួយៗដែលបានលើកឡើងជុំវិញបញ្ហាឥទ្ធិពលនៃលុយអាចអោយយើងពិចារណាឃើញថា ករណីខ្លះលុយពិតជាឧបករណ៍ជួយមនុស្សអោយមានសុភមង្គល អាចឈ្នះលើអ្វីៗទាំងអស់មែន ។ តែពុំសន្មតថាមានស្ថិរភាព ទាំងស្រុងនោះឡើយ ។ ដោយសារសង្គមបច្ចុប្បន្នបានវិវត្តន៍ ដល់តំណាក់កាលមួយដែលមនុស្សទាំងអស់មានការចេះដឹងប្រហាក់ប្រហែលគ្នា ។ លុយពុំមានសមត្ថភាពគ្របលើចន្លះមនុស្ស អាចទិញចំនេះវិជ្ជាអាចអន្តងចិត្តជនដទៃមកបំរើឧបាយកលខ្មៅក្រខ្វក់ល្អក់កករនៃចិត្តអ្នកមានលុយបានឡើយ ។ ម្យ៉ាងទៀត នាពេលនេះលុយវាគ្រាន់តែជាមធ្យោបាយដ៏សាមញ្ញដែលមនុស្សត្រូវប្រើវានាពេលដ៏សមស្របទើបអាចអោយមនុស្សទាញយកប្រយោជន៍បាន ។ នេះមកពីមនុស្សបច្ចុប្បន្នមានច្បាប់ទំលាប់ការពារ

www.budinst.gov.kh www.elibraryofcambodia.org

ត្រឹមត្រូវពិសេសច្បាប់ស្តីពីសិទ្ធិមនុស្ស ច្បាប់ស្តីពីការផ្តន្ទាទោសអ្នកប្រើលុយក្នុងផ្លូវអន្ធការគឺគេមិនអោយតំលៃលុយ លើសពីតំលៃមនុស្ស លើសពីកិត្តិយសមនុស្សបានជាដាច់ខាត ។ បើក្នុងករណី ដែលលុយផ្តល់សុភមង្គលឬជោគជ័យដល់មនុស្សមែន ក៏សុភមង្គលឬជោគជ័យ នោះវាជាលទ្ធផលត្រឹមតែមួយគ្រាប៉ុណ្ណោះ ។ សុភមង្គលឬជោគជ័យមនុស្សត្រូវ ពឹងផ្អែកចំនេះប្រាជ្ញាលើសេចក្តីល្អនៃមនុស្ស ។ ការរក្សាចិត្តសន្តោសប្រណីយោគ យល់គ្នាទៅមកតាមលំអាននៃព្រះពុទ្ធសាសនា ដែលតែងទូន្មានមនុស្សថា «សុភមង្គលឬជ័យជំនះរបស់មនុស្សពឹងលើការរឹងាប់កិលេស និងការពឹងលើ សមត្ថភាពខ្លួនឯងផ្តាល់ដោយកសាងកុសលកម្មជាមូលដ្ឋាន» ។

III-<u>យោបល់បញ្ចប់</u>

យោលតាមការពិភាក្សាខាងលើនេះ យើងអាចវាយតំលៃបានថាមតិរបស់ប្រធាន គឺជាមតិមួយដែលត្រឹមត្រូវបានតែមួយជ្រុងតូច ឬ អាចចាត់ទុកថាជាមតិ អន់ថយក៏ថាបាន ។ បើតាមត្រឹមត្រូវពិតនោះសុភបង្គលឬជ័យជំនះរបស់មនុស្ស ពឹងផ្អែកទាំងស្រុងលើលុយមួយផ្នែក ។ មួយផ្នែកពឹងលើការប្រឹងប្រែងលើការតស៊ូ ការធ្វើល្អរបស់មនុស្សរួមផ្សំថែមទៀត ។ ដូចនេះគួរតប្បីមនុស្សម្នាក់ៗឈប់យល់ច្រឡំថា មានលុយមានសុភមង្គលនិងឈ្នះលើអ្វីៗទាំងអស់ទៀត ។ បើបន្តយល់ឃើញបែបនេះទៀត អ្នកនឹងជួបនូវផលវិបាកអាក្រក់ណាមួយក្នុងជីវិតជាក់ជាពុំខាន ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រធានទី ១៥: មានមតិមួយលើកឡើងថា «អក្សរសិល្ប៍ថ្នាក់ទី១២បានធ្វើអោយយុវជនមានគំនិតទន់ជ្រាយ» ។ ឯមតិមួយទៀតយល់ថា «អក្សរសិល្ប៍ថ្នាក់ទី ១២ បានធ្វើអោយយុវជនមានគំនិតរឹងប៉ឹង» ។ ចូរពិភាក្សា ។

គំរោងតែង

១- មតិស្រប

ក- ពន្យល់ពាក្យ គំនិតទន់ជ្រាយ = ក្មេងរា កំសាក

ខ- បកស្រាយ អោយយុវជន

- បាក់ស្បាតលែងហ៊ានតស៊ូ
  - រឿងភូមិតិរច្ឆាន
  - ថៅកែចិត្តចោរ
- អស់សង្ឃឹមក្នុងជីវិត ពុំអាចយកលើកស្ទួយអោយមានភាពខ្ពង់ខ្ពស់ឈ្នះទឹកប្រាក់ ពុករលួយបាន
- រឿងព្រះអាទិត្យថ្ងៃរះលើផែនដីចាស់
- មិនមានគំនិតចង់រស់លើមាតុភូមិ ⟹ ជួបតែវិបត្តិភាពគ្រាំគ្រា
- ទុក្ខវេទនា ពីជំនាន់មួយទៅជំនាន់មួយ
- រឿងភូមិតិរច្ឆាន - រឿងគួលីកំផែន

២- មតិផ្ទុយ

ក- ប្រាប់មតិផ្ទុយ

- ធ្វើអោយយុវជន មិនមានចិត្តទ្រេតទ្រោត មានចិត្តម៉ឺងម៉ាត់

ខ- បកស្រាយ

- មិនបោះបង់ចោលគំនិតតែប្រែសង្គម

www.budirist.gov.kh www.elibraryofcambodia.org

- រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់
- រឿងចៅកែចិត្តចោរ

- មានភាពជឿជាក់ឆន្ទៈ ឥស្សិដ្ឋត្រឹមត្រូវ
- គួលីកំនែន

- មិនមានចិត្តរាយមាយ
- រឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់- ភូមិតិរច្ឆាន

៣- <u>ពិតាក្សា</u>

- បង្កើតភាពក្លាហាន ទៅមុខ មិនធ្វើអោយយុវជនអស់សង្ឃឹម ។
- ការបង្ហាញភាពបរាជ័យ ជាបទពិសោធន៍សំរាប់ចាប់យកជោគជ័យនាពេលអនាគត ។

♠♠♠

សេចក្តីរេរិល្អាយ

I-<u>សេចក្តីផ្តើម</u>

តាមទ្រឹស្តីអក្សរសិល្ប៍បានគូសបញ្ជាក់ថា អក្សរសិល្ប៍ជាអាវុធមុខពីរ ។ វាអាចធ្វើអោយអ្នកអានដុះចេញនូវទស្សនៈលួបប្រែប្រួលផ្លាស់ប្តូរពីស្ថានភាព ប្រតិកិរិយាទៅជាស្ថានភាពជឿលើសពីគេឯង ។ មួយវិញទៀត អក្សរសិល្ប៍ក៏បានក្លាយជាវត្ថុរាំងខ្ទប់អួសទាញចិត្ត អ្នកអានអោយ ស្តីកស្រពន់ខ្លាចរអារពុំហ៊ានធ្វើអ្វីៗសព្វបែបយ៉ាង ។ យោងលើលក្ខណៈនេះហើយបានជានៅក្នុងការវាយតំលៃ លើលទ្ធផលក្រោយពីបានសិក្សាអក្សរសិល្ប៍ថ្នាក់ទី១២ មានមតិពីរយល់ផ្សេងពីគ្នា ។ មតិទី១យល់ថា «អក្សរសិល្ប៍-

www.budinst.gov.kh www.elibraryofcambodia.org

ថ្នាក់ទី១២បានធ្វើអោយយុវជនមានគំនិតទន់ជ្រាយ » ។ មតិមួយទៀរយល់ថា «អក្សរសិល្ប៍ថ្នាក់ទី១២បានធ្វើអោយយុវជនមានគំនិតរឹងប៉ឹង » ។ តើបណ្តាមតិទាំងពីរខាងលើមតិណាសមហេតុផល ជាងគេ ?

II-តួសេចក្តី

១- មតិស្រប

ដើម្បីវិភាគវែកញែករកខុសនឹងត្រូវអោយមតិទាំងពីរខាងលើនេះ យើងគួរយល់អត្ថន័យក្នុងមតិទី១ជាមុនសិន ។ ពាក្យ«ទន់ជ្រាយ» សំដៅលើភាពមិនក្លាហានរួញរាខ្លាចរអាមិនទៅមុខ ។ ក្នុងន័យនេះ មតិទី១គេចង់និយាយអត្ថបទរឿងថ្នាក់ទី១២បើយុវជនសិក្សា ឬអានរួចវាអាចធ្វើអោយគេបាត់បង់អស់ រលីងនូវភាពក្លាហាន ពុះពារទៅមុខទាំងផ្លូវកាយនិងចិត្ត ។

ប្រការដែលមតិទី១ គេហ៊ានអះអាងបែបនេះដោយគេពិនិត្យឃើញថាអក្សរសិល្ប៍នេះមួយផ្នែកបានបញ្ជាក់នូវខ្លឹមសារ ធ្វើអោយយុវជនមានគំនិតបាក់ស្បាត បាត់អស់ នូវគំនិតស៊ូទ្រាំទ្រប្រយុទ្ធនិងពួកឈ្លានពាន ។ ជាក់ស្តែងបើធ្វើការរំលឹកពីឆ្នាំដែលប្រជាជនក្រឹងលាវ ត្រូវបារាំងសំលាប់រង្គាលដោយអាវុធការធ្វើទារុណកម្មឥតរើសមុខ ។ សំខាន់គឺការធ្វើរបស់បារាំងទៅលើនៅជួន និង មនុស្សជាច្រើនទៀតដែលចូលរួមជាមួយពួកគេគឺនឹងធ្វើអោយយុវជនព្រឺស្ញើប រលាយអស់រលីងនូវចិត្តជីវិះ ។ ព្រោះថា រាល់អ្នកតស៊ូត្រូវរងនូវការបង្ក្រាបយ៉ាង សាហាវយោរយៅ រងនូវគ្រោះថ្នាក់ដ៏ធំធេងពុំអាចកាត់ថ្លៃបាន ។ បើយ៉ាងនេះទេ រឿងភូមិតិរច្ឆានពិតជានឹងទាញស្មារតីយុវជនអោយថយក្រោយមិនក្រោកតស៊ូទៀតឡើយ ព្រោះអីការតស៊ូ នឹងនាំអោយគេមានគ្រោះថ្នាក់ដល់ជីវិត និងភូមិស្រុករបស់ខ្លួនចៀសពុំរួច ។

www.budinst.gov.kh www.elibraryofcambodia.org

ទន្ទឹមនឹងនេះដែរក្នុងរឿងចៅកែចិត្តចោរក៏មានលំនាំ មួយដួចគ្នា បេះបិតនឹងរឿងភូមិតិរច្ឆានផងដែរ ។ តាមរយៈការទទួលនូវលទ្ធផលរបស់ពួហាំនឹងធ្វើ ។ អោយយុវជនស្រងាកក្នុងចិត្ត ។ ពួហាំដែលពុះពារគ្រប់បែបយ៉ាងជាមួយចៅកែ ចិត្តចោរដែលមើលទៅឃើញថាគួរតែចៅកែរួបនេះត្រូវមានទោសធ្ងន់ ដោយគេជាមេខ្លោងក្នុងការទទួលខុសត្រូវ និងបញ្ជាអោយពួបរើកឡានបុកឡានចៅកែហុងលើនោះ ។ ភាពបរាជ័យរបស់ពួហាំបានក្លាយជាហ្វ្រាំងទប់ស្កាត់ចិត្តយុវជន អោយស្តីកស្រពន់ចោះបង់ចោលទស្សនៈពស្តីពើអ្បីសុភមង្គល និង វែកញែកអោយឃើញស ខ្វៅ គុណទោសនោះ ។

ក្រៅពីកំនុចនេះមតិអ្នកទី១ គេនៅបានមើលឃើញថារឿងថ្នាក់ទី១២ ដដែលបានបញ្ចេញនូវសិល្បីវិធីមួយផ្នែកទៀត ដែលអាចញ្ជឹងចិត្តយុវជនអោយអស់សង្ឃឹមក្នុងជីវិត ដោយសារភាពអយុត្តិធម៌សង្គមបានក្លាយទៅជាកំលាំងដ៏ធំមហិមា កាត់ផ្តាច់សរសៃសស្លងនៃជនសប្បុរសជនស្រលាញ់យុត្តិធម៌អោយស្ងិតខ្ចិនខ្ចង់នៅនឹងកន្លែង ។ យ៉ាងណាមិញរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់ក្តីរឿងចៅកែចិត្តចោរក្តី សុទ្ធតែលើកឡើងពីឥទ្ធិពលនៃកំលាំងទឹកប្រាក់អំពើពុករលួយ មានតួនាទីពេញផ្តែប្រទេស ។ ពិសេសនៅទីក្រុង ។ នាយទុនធំៗបង្កនូវហិង្សាលើកម្មករ ។ កម្មករត្រូវទទួលរងនូវការបាត់បង់អាជីពព្រោះតែការទាមទារយុត្តិធម៌របស់ពួកគេ ។ តួយ៉ាងសមត្រូវចៅកែរោងចក្រសាប៊ូបណ្តេញចេញពីការងារ ។ ក្រុមកម្មករគាំទ្រពួហាំត្រូវចៅកែចិត្តចោរបញ្ឈប់មិនទទួលគេធ្វើជា កម្មករតទៅទៀត ។ ប្រាក់បានធ្វើអោយពួកប៉ូលីសលែងគោរពច្បាប់ ។ បញ្ហានេះបង្កនូវភាពអយុត្តិធម៌ផ្នែងៗគ្នាលើអ្នកក្រីក្រ ។ សមត្រូវគេចោទអោយជាប់គុកទទេៗរាប់ខែ ។ ពួហាំត្រូវជាប់គុកព្រាត់ប្រពន្ធកូនមួយឆ្នាំ អោយនៅរងទុក្ខវេទនាគ្មានសង្ឃឹមថា ប្តីរបស់គាត់

www.budihst.gov.kh www.elibraryofcambodia.org

នឹងមានសេរីភាព ដោយសារគាត់ជាអ្នកក្រគ្មាន ប្រាក់សំរាប់សូកប៉ាន់។

ចុងក្រោយនេះ ការដែលមតិទី១ ថាអក្សរសិល្ប៍ថ្នាក់ទី១២នឹងធ្វើអោយយុវជនមានគំនិតទន់ជ្រាយនៅត្រង់ថា រឿងនេះវានឹងធ្វើអោយយុវជនមិនមានគំនិតចង់រស់តទៅទៀតនៅលើមាតុភូមិខ្លួន។មូលហេតុអ្វីបានជាហ៊ានថាដូចនេះ? ។ បានជាហ៊ានដូចនេះមកពីផ្នែករឿងខ្លះ រួមមានភូមិតិរច្ឆានរឿងគូលីកំនែនសុទ្ធតែបានបង្ហាញនូវទុក្ខវេទនាឥតស្រាកស្រាន្តនៃប្រជារាស្ត្រខ្មែរពីជំនាន់មួយទៅជំនាន់មួយ ។ ជាក់ស្តែងរឿងភូមិតិរច្ឆានពីដើមរឿងរហូតចប់ខ្មែរគ្មានស្គាល់ទាល់តែសោះពន្លឺសុភមង្គល ។ សុវណ្ណ ប៊ុតមានគំនិតរកស៊ីលក់ដូរតែត្រូវខាតបង់ដោយសារមុខរបរខ្លួន ។ សុវណ្ណត្រូវព្រាត់ពីប្រពន្ធដោយសារតែជំងឺគ្មានលទ្ធភាពព្យាបាល ។ នាងនីនាងប៊ីនាងតន់ត្រូវនិរាសព្រាត់ប្រាស់ប្តី ទោះបីគេសុខចិត្តធ្វើពលីកម្មជួយសព្វជួយគ្រប់ក្តី ។

ចំនែករឿងគូលីកំនែនក្រុមគ្រួសារកសិករខ្មែរ ត្រូវជាប់កំនែនឥតឈប់បង ប្អូន ប្តី ប្រពន្ធ កូនចៅ ត្រូវរស់នៅបែកគ្នា ។ ជូនកាលត្រូវស្លាប់ក៏សឹងមាន ។ ដូចជា នាង ហេង ត្រូវស្លាប់ដោយការគេចវេះ ពីកណ្តាប់ដៃចៅហ្វាយស្រុកចិត្តខ្មៅ ។ សំដីរបស់ប៊ីងក្រោយពីចលនាតស៊ូខ្មែរ ឈ្នះបារាំងហើយគេបានបញ្ជាក់ថា ខ្មែរត្រូវចក្រពត្តិអាមេរិកត្រួតត្រាថែមទៀត ។ ដូចនេះខ្មែរត្រូវធ្វើការតទល់បន្ត និងពួកនោះទៀត ។ ពេលនោះហើយឈាមខ្មែរនឹងហូរក្រាល លើផែនដីបន្តទៀត ការលើកឡើងនូវសោកនាដកម្មសង្គ្រាមបែបនេះ អាចធ្វើអោយយុវជនធុញថប់នឹកតូចចិត្តលែងមានគំនិតចង់រស់នៅប្រទេសខ្លួនហើយមានគំនិតរត់ទៅរស់នៅឯបរទេស ។

ផ្អែកលើសេចក្តីដូចបានរៀបរាប់ខាងលើនេះហើយទើបមតិអ្នកទី១ ហ៊ានវិនិច្ឆ័យយ៉ាងដាច់ណាត់ថា «អក្សរសិល្ប៍ថ្នាក់ទី១២ បានធ្វើអោយយុវជន

www.bakhet.gov.kh www.elibraryofcambodia.org

មានគំនិតទន់ជ្រាយ» នោះ ។

២- <u>មតិថ្មុយដូច</u>

មិនប្រាកដដូចដែលមតិទី១ យល់នោះទេ ។ «អក្សរសិល្ប៍ថ្នាក់ទី១២ ជាអក្សរសិល្ប៍ដែលពង្រឹងចិត្តយុវជនអោយមានស្មារតីរឹងប៉ឹង» ។ គឺបានសេចក្តីរឿងទាំងនោះវាបែរជាបង្កើនន្ទវិភាពម៉ឹងម៉ាត់ ភាពរឹងមាំ ដល់យុវជនមិនធ្វើអោយយុវជនមានចិត្តទ្រេតទ្រោតភ្លេចជាតិ ចុះចាញ់ន្ទវិនុបសគ្គដែលកើតមានចំពោះមុខខ្លួនឡើយ ។

ធម្មតាទេ សង្គមណាក៏ដូចសង្គមណាដែរភាពអយុត្តិធម៌តែងនឹងមានជាដរាប ។ ប៉ុន្តែកន្លងមកភាពអយុត្តិធម៌ពុំបានក្លាយទៅជាវត្ថុរឹងក្បាលដែលប្រទេសនិមួយៗបង្ក្រាបពុំបាននោះទេ ។ អ្នកសាបព្រោះអំពើអយុត្តិធម៌មិនថាអ្នកធំ អ្នកជូចទេ អ្នកនោះត្រូវបានច្បាប់ផ្តន្ទាទោសជាមន្តបន្តាប់ ។ ក្នុងន័យនេះ យើងឃើញថា រឿងព្រះអាទិត្យថ្ងៃរះលើផែនដីចាស់រឿងចោរកែ-ចិត្តចោរ ។ ការដែលកំនត់អោយសមក្តី ពូបាំក្តីត្រូវចាញ់ដោយអំពើអយុត្តិធម៌ពុំមានឈ្មោះថា ពង្រួញស្មារតីយុវជន អោយទន់ជ្រាយឡើយ ។ ប៉ុន្តែវាបែរជាធ្វើអោយគេកាន់តែ មានការឈឺចាប់រួចរិះរកវិធានការថ្មីតាមសម័យកាលដើម្បីបោសសំអាតអំពើនេះពីសង្គមជាតិខ្លួន ។ ករណីសមក៏ដូចពូបាំដែលត្រូវចាញ់ចោរកែហុកចោរកែសំបូរសម្បត្តិ ចោរកែចិត្តចោរពុំឈ្មោះថាជាឧបសគ្គដល់ឆន្ទៈយុវជនឡើយ ។ យ៉ាងហោចណាស់មុនពេលដែលអ្នកពីរត្រូវប៉ូលីសល្មោភប្រាក់ធ្វើលើសច្បាប់ ពួកគេបានបកអាក្រាតន្ទវិការពិតជាច្រើនធ្វើអោយយុវជនភ្ញាក់ស្មារតី មើលឃើញច្បាស់ពីល្បិចកលខ្មៅកខ្វក់នៃពួកទាំងអស់នោះ ដើម្បីធ្វើអោយគេមានជំហរមាំមួន ឆ្លុះដំបៅស្នុយរលួយនេះអោយអស់ពីសង្គមជាតិខ្លួនទាំងថ្ងៃអនាគតពុំខានឡើយ ។

www.budinst.gov.kh www.elibraryofcambodia.org

ចំនុចមួយទៀតតាមរយៈរឿងគូលីកំនែននិងរឿងភូមិតិរច្ឆានផ្តល់នូវ ភាពជឿជាក់ដល់យុវជនថា ធន្លៈតស៊ូដ៏ត្រឹមត្រូវ ពិតជានឹងធ្វើអោយសំរេច បាននូវជោគជ័យជាពុំខាន ។ ជាសកីភាពគឺយើងឃើញថា មុីង នួដួង លីម ដែលជាតំនាងអោយកំលាំងតស៊ូរបស់ខ្មែរបានធ្វើអោយចង្វាក់បេះដួងខ្មែរដើរ ក្នុងដំនើរចម្ងាយ ។ ពួកគេបានផ្តល់នូវជោគជ័យដ៏ត្រចះត្រចង់ជូនជាតិ មាតុភូមិ ។ មហាអំនាចដែលធ្លាប់មានវិទ្ធិបារមី មានអំនាចអាចធ្វើអ្វីៗមក លើជាតិខ្មែរត្រូវបានទទួលនូវមេរៀនដ៏សែនជូរចត់ ។ ពួកគេត្រូវខាតបង់សព្វ បែបយ៉ាងពុំអាចគណនាបាន ។ ពេលនោះលីម បានទទួលនាទី ជំនួសពួក ប្រតិកិរិយាដែលជាឆ្កែបំរើបរទេស ។ សំលេងរីករាយ របស់ប្រជាកសិករខ្មែរ តាំទ្រអ្នកតស៊ូបានលាន់ឮឡើង ។ មេឃុំចៅហ្វាយស្រុកចាស់ជំនាន់បារាំងត្រូវ បានប្រជាកសិករដកការទុកចិត្តពីពួកគេទាំងស្រុង ។ ពេលនោះហើយដែល អ្វីៗទាំងអស់ក្លាយជាការពិតស្របតាមការចង់បានរបស់រាស្ត្រខ្មែរ ។

ចំពោះរឿងភូមិតិរច្ឆាន ដែលពុំបានក្រាប់ពីជោគជ័យក្រោមការតស៊ូ មែនពិត ប៉ុន្តែការតស៊ូនេះពុំមែនមិនផ្តល់នូវផលល្អសំរាប់ខ្មែរ និង សំរាប់ អោយយុវជនខ្លាចរអារក្នុងការតស៊ូនោះទេ ។ ការតស៊ូនេះបានធ្វើអោយអាណា និគមនិយមបារាំង តាំងជំនើរទៅមុខរបស់ពួកគេ ។ គេនឹងមានកូនចិត្តមួយ ភ័យព្រួយញាំញីតនឹងរាស្ត្រខ្មែរ ។ ម្ល៉ោះហើយបែបផែននៃការរំលោភបំពាន របស់គេនឹងមិនមានទ្រង់ទ្រាយធំដូចពេលមុនៗទៀតឡើយ ។ បូផ្សាំងដែលជា ប៉ើស៊ីដង់ស៊ុបបើរ យើរប្រចាំស្រុកខ្មែរនាពេលនោះពុំហ៊ានបណ្តោយអោយ បក្សពួកគេប្រព្រឹត្តិនូវ អំពើគាបសង្កត់ដោយត្រង់ៗដូចរបៀបបារាំង ដែល បានធ្វើមកលើរាស្ត្រខ្មែរ នៅខេត្តកំពង់ឆ្នាំងនៃភូមិក្រាំងលាវទៀតឡើយ ។

លើសពីនេះទៀតតាមរយៈរឿងព្រះអាទិត្យថ្មីរះលើផែនដីចាស់និងរឿង

www.budhist.gov.kh www.elibraryofcambodia.org

ភូមិតិរច្ឆានេះ ដដែលបានធ្វើអោយយុវជនមានជំហរ នឹងនរមិនរាយមាយ ភ្លើត ភ្លើនតាមការបោកបញ្ឆោតនៃពួកបរទេសអោយភ្លេចជាតិខ្មែរភ្លេចមាតុភូមិ លង់ខ្លួនបំរើពួកនោះដោយឥតពិចារណាទៀតផង ។ ភស្តុតាងរឿងព្រះអាទិត្យថ្មីរះលើ ផែនដីចាស់សមដែលជាតំនាងអោយខ្មែរម្នាក់ដែលមានមនសិការស្នេហាជាតិស្នេហាទឹកដីកំនើត គេបានសំរេចទៅរួមរស់នៅជនបទធ្វើស្រែចំការតាមនយោ បាយឯករាជ្យលើវិស័យកសិកម្ម ដែលត្រួសត្រាយដោយសម្តេចព្រះនរោត្តសីហនុជាបិតាកសិកម្មជាតិ ។ ការតាំងចិត្តរបស់សមលើវិស័យនេះបានធ្វើអោយរូបគេ មានអនាគតដ៏ត្រចះត្រចង់ ។ ភាពខ្មៅងងឹតដែលធ្លាប់តែគ្របជណ្តប់លើខ្លួនបានគេរលាយអស់ក្រោមទឹកចិត្តប្តូរផ្តាច់នឹងការងារចិញ្ចឹមជីវិត ដែលត្រូវបង្ហូរញើសក្រោមកំដៅថ្ងៃក្តៅ លើទឹកដីដ៏មានជីជាតិរបស់ខ្លួន ។

ទាក់ទងទៅនឹងរឿងភូមិតិរច្ឆានមតិទី២ បានសំលឹងឃើញយ៉ាងប្រត្យក្សនឹងភ្នែកថាជនដែលក្បត់ជាតិឯង លក់ខ្លួនបំរើបរទេសបានជួបនូវជតាកម្មអាក្រក់បំផុត ។ ថីស្ងួននិងបរិវារបារាំងដទៃទៀត ត្រូវប្រជារាស្ត្រខ្មែរផ្តន្ទាទោយ៉ាងទាន់ហន់ ។ ឈ្មោះរបស់ពួកនេះត្រូវបានកប់បាត់ក្នុងទំព័រសាវតារជាតិ ។ រូបភាពបែបនេះពិតជាបំភ្លឺភ្នែកយុវជនអោយមើលឃើញឡើងវិញនូវផ្លូវគំនិតថ្មី មានចិត្តរឹងមាំមិនប្រថុយខ្លួនអោយចូលក្នុងគន្លងពួកប្រតិកិរិយាទាំងនោះ ។ គេនឹងអាចផ្លាស់ប្តូរ គំនិតចូលមករួមដៃខាងក្រុមខ្មែរស្នេហាជាតិជួយជាតិអោយរីកចំរើនរុងរឿងទៅមុខ ។

ផ្អែកលើភស្តុតាងមួយចំនួនដែលបានបកស្រាយទាំងអស់នេះហើយដែលមតិទី២ អាចធ្វើការសន្និដ្ឋានបានថា «រឿងថ្នាក់ទី១២ ពិតជានឹងធ្វើអោយយុវជនខ្មែរ ជំនាន់ក្រោយមានគំនិតរឹងប៉ឹង »នោះ ។

www.budinst.gov.kh www.elibraryofcambodia.org

៣-ពិតាគឃ្នា

ក្រោយពីបានធ្វើការផ្លាស់ប្តូរនូវមតិយោបល់ជុំវិញមតិទាំងពីរខាងលើ ជុំវិញ រឿងថ្នាក់ទី១២ ដែលផ្តល់នូវតំនិតពិតសំរាប់យុវជនខ្មែរនោះ យើងអាចអះអាងបានថា បណ្តាអក្សរសិល្ប៍ថ្នាក់ទី១២ ពិតជាបង្កើតនូវភាពភ្លាហានភាពរឹង មាំដល់យុវជនមិនអោយយុវជនមានគំនិតទន់ជ្រាយនោះឡើយ ។ ការបង្ហាញពីភាពអសកម្ម ដែលអ្នកនិពន្ធរឿងទាំងនោះវាជាមធ្យោបាយដ៏សំខាន់សំរាប់ផ្តល់ជាបេរៀនអោយយុវជនយើងពិចារណារកអោយឃើញនូវវិធីថ្មី ដើម្បីកែប្រែសង្គម ជាតិខ្លួនដោយឆ្ពោះទៅរកតំនាក់កាលមួយថ្មីតាមការចង់បានរបស់យុវជនម្នាក់ៗ ដែលជាសសរទ្រូងនៃប្រទេសជាតិនោះ ។

III-យោបល់ចុងបញ្ចប់

រួមសេចក្តីមក ការយល់របស់មតិទី១ជាការយល់មិនត្រឹមត្រូវឡើយ។ តាមពិតអក្សរសិល្ប៍នានា ដែលបញ្ចូលក្នុងកម្មវិធីសិក្សាសុទ្ធតែដើរតួនាទីដ៏សំខាន់ ដឹកនាំចិត្តគំនិតយុវជនអោយហ៊ានប្រឈមមុខទល់នឹងបញ្ហាសុគស្ទាញគានតឹងនានា ដែលប្រទេសជាតិខ្លួនបានជួបប្រទះ ។ អក្សរសិល្ប៍ទាំងនោះប្រាកដជានឹងក្លាយជាដៃគូដ៏ពិសិដ្ឋសំរាប់ជាជំនួយដល់យុវជនយកមកធ្វើជាអាវុធផ្នែកស្មារតី ជំរុញសង្គម ជាតិឈានឆ្ពោះទៅរកសុភមង្គលនិងវឌ្ឍនភាព ដ៏ប្រសើរនាពេល ដែលខ្លួនចូលប្រលូកក្នុងកិច្ចការងារធំៗជូនជាតិរបស់ខ្លួនពុំខាន ។

យោនយកកំនើតកើតជាខ្មែរ	ជាតិខ្លាំងពូកែផ្នែកអាស៊ី
ត្រូវខំធ្វើការខំសាមគ្គី	បំពេញនាទីពូជអង្គរ

www.budinst.gov.kh www.elibraryofcambodia.org

ប្រធាន : (២៧ មិថុនា ១៩៩៥)

ក្នុងរឿងគូលីកំនែនលោកចៅហ្វាយបានពោលថា «រាស្ត្រមានភារៈតែមួយមុខ គឺត្រូវបង់ពន្ធជូនរាជការ » ។ តើមតិនេះត្រឹមត្រូវឬទេ ? ចូរពិភាក្សាដោយលើកឧទាហរណ៍ក្នុងរឿងថ្នាក់ទី១២ ដែលអ្នកបានសិក្សាមកបញ្ជាក់ ។

គំរោងតែន

I-សេចក្តីផ្តើម

- លំនាំបញ្ហា ÷ - រកគំនិតមកផ្តើមអោយទាក់ទងនឹងប្រធាន
- ចំនួលបញ្ហា ÷ - ភ្ជាប់គំនិតខាងលើមកប្រធាន
- ចំនោទបញ្ហា ÷ - តើមតិលោកចៅហ្វាយនេះត្រឹមត្រូវឬទេ ?

II-តួសេចក្តី

១- <u>មតិស្រប</u> រាស្ត្រត្រូវបង់ពន្ធជូនរាជការព្រោះ

- ជាភារកិច្ច
- ជាច្បាប់សំរាប់ប្រទេស
- បើមិនបង់ពន្ធរាជការគ្មានថវិកាសំរាប់បំពេនិងកសាងប្រទេស

(លើកពីរឿងគូលីកំនែន, ភូមិតិរច្ឆាន)

២- <u>មតិផ្ទុយ</u>

រាស្ត្រមិនមែនមានភារកិច្ចត្រឹមបង់ពន្ធប៉ុណ្ណោះទេ ។ ភារកិច្ចរាស្ត្រមានច្រើនទៀតដូចជា ÷

- ជួយកសាងសមិទ្ធិនានា
- ជួយការពារប្រទេស

www.budirst.gov.kh www.elibraryofcambodia.org

- តស៊ូ(ជីវភាពរស់នៅ, ជីវភាពសង្គម, ការឈ្លានពាន. . .)

- ចូលរួមផ្តែកនយោបាយ (បោះឆ្នោត. . . .)

(លើកពីរឿងភូមិតិរច្ឆាន, គួលើកំផែន, ព្រះអាទិត្យថ្មីរះលើដែនដីចាស់, ចៅកែចិត្តចោរ)

៣- <u>សំយោគមតិ</u>

- រាស្ត្រត្រង់បង់ពន្ធនិងត្រូវចូលរួមទទួលខុសត្រូវលើរាល់ ការងារ ដើម្បីការរីកចំរើននិងភាពសុខសាន្តរបស់ប្រទេសជាតិ

- គំនិតប្រធាននេះកំនត់ភារកិច្ចគួចបំផុតរបស់រាស្ត្រ ។ គេមិនអាច ផ្តាច់ការងារទទួលខុសត្រូវរបស់រាស្ត្រចំពោះវាសនាអនាគតជាតិបានឡើយ ។

III-<u>យោបល់បញ្ចប់</u>

ក- <u>ទាយតំលៃប្រធាន</u>

- មតិប្រធានមិនទាន់ត្រឹមត្រូវទេ រាស្ត្រមានភារកិច្ចច្រើនបែបយ៉ាង ទៀតក្នុងការបំរើប្រទេសជាតិ ។

ខ- <u>យោបល់ផ្ទាល់</u>

- ការពោលដូចនេះ គឺមកពីគេមិនចង់អោយរាស្ត្រមានការភ្ញាក់រលឹក ។ យើងជារាស្ត្រត្រូវយល់ភារកិច្ចខ្លួនអោយបានច្បាស់លាស់ទើបប្រទេសធាបរីក ចំរើន ។

www.budinst.gov.kh www.elibraryofcambodia.org

ប្រធាន (ឆ្នាំ ១៩៩៦- លើកទី១)

នៅក្នុងរឿងថៅកែចិត្តចោរ មតិខ្លះយល់ថា «ការបញ្ចប់រឿងដោយអោយពូហាំជាប់គុកម្នាក់ឯងបែបនេះជាការត្រឹមត្រូវណាស់ » ។ ចំពោះអ្នកវិញតើមតិខាងលើនេះត្រឹមត្រូវដែរឬទេ? ចូរពិភាក្សា ។

គំរោងតែ១

I- សេចក្តីផ្តើម

- លំនាំបញ្ហា : និយាយទាក់ទងនឹងសិល្បវិធីក្នុងការបញ្ចប់រឿង
- ចំនួលបញ្ហា : ភ្ជាប់ពាក្យបង្ហាញគំនិតប្រធាន
- ចំនោទបញ្ហា: តើមតិនេះត្រឹមត្រូវទាំងស្រុងដែរឬទេ?

II-តួសេចក្តី

- ឃ្លាភ្ជាប់សេចក្តី
- ពន្យល់ពាក្យគន្លឹះ
- ពន្យល់ន័យប្រធាន

១- មតិស្រប : ការបញ្ចប់រឿងដោយអោយពូហាំជាប់គុកម្នាក់ឯងជាការត្រឹមត្រូវណាស់ព្រោះ

ក- តាមផ្លូវច្បាប់

- ពូហាំបានប្រព្រឹត្តិអំពើឧក្រិដ្ឋ បើកឡានទៅបុកឡាន ថៅកែហុងលីធ្វើអោយស្លាប់មនុស្សជាច្រើនដែលអ្នកនោះគ្មាន ទោសកំហុស

ខ- តាមគន្លងចរិយាហាំមិនឧឡើងខុសត្រូវលើអំពើរបស់ខ្លួន

- គាត់ប្រមាថជីវិតដ៏មានតំលៃរបស់មនុស្ស គាត់ចាត់ទុក «អ្នកនោះស្លាប់មកពីសិយ- អាយុវាអស់ »

www.buddhist.gov.kh www.elibraryofcambodia.org

គ- **តាមឆ្នូវព្រះពុទ្ធសាសនា**

- ពួបាំធ្វើអំពើអាក្រក់ កម្មអាក្រក់ បានផលអាក្រក់

សរុប : ពួបាំជាប់គុកម្នាក់ឯងត្រឹមត្រូវ

២- **មតិផ្ទុយ**: ការអោយពួបាំជាប់គុកម្នាក់ឯងមិនត្រឹមត្រូវទេអ្នកដែលត្រូវជាប់គុកទៀតនោះគឺថៅកែប៉ូលីសព្រោះ

ក- **ថៅកែជាអ្នកបញ្ជា**

- បានអោយពួបាំទៅធ្វើដើម្បីបំពេញបំរើមហិច្ឆតា ចិត្តលោភលន់

ខ- **ថៅកែចេញមុខជានិងសង្ឃ**

- ធ្វើបានគេទទួលខុសត្រូវនិងអោយរង្វាន់ ១ម៉ឺនរៀល

គ- **ថៅកែជាមនុស្សខ្មៅចោរ**

- ក្រឡាស់សំដីយករូចខ្លួនប្រើលុយស្លូកប៉ាន់មានគំនិតអយុត្តិធម៌ក្នុងខ្លួនជានិច្ចយករូបភាពសាសនា មនុស្សធម៌បិតបាំងអំពើអាក្រក់ ។

ឃ- **ប៉ូលីសក៏ត្រូវតែមានទោស**

- ទទួលសំនូកពីជនខិលខូច ល្មើសច្បាប់

៣- **សំយោគមតិ**

- ការអោយពួបាំជាប់គុកម្នាក់ឯងមិនត្រឹមត្រូវ
- ត្រូវអោយមេដើមគំនិតនិងអ្នកផ្សំគំនិតខូចមានទោសដែរ

III-យោបល់

- ទស្សនៈប្រធានពុំទាន់មានលក្ខណៈត្រឹមត្រូវ →រាស្ត្រក្រមិនសុខចិត្តព្រោះអ្នកមានលុយ អំនាចឈ្នះពួកគេវេទនាដដែល → ភាពអយុតិធម៌បែបនេះធ្វើអោយសង្គមអន់ថយ ។

- ការបញ្ចប់បែបនេះអ្នកនិពន្ធចង់រិះគន់សង្គមដែលប្រកបដោយអំពើអយុត្តិធម៌ → រួមគ្នាកំចាត់ពួកនោះអោយអស់ ។

www.buddhist.gov.kh www.elibraryofcambodia.org

ប្រធានត្រូវរិះសុំរាប់បួនពិចារណា និង ល្បងតែង

១- ប្រធានពិភាក្សា

❶-ប្រធាន : មតិមួយលើកឡើងថា « សមជាអ្នកដែលជួបតែនឹងរឿងអាស្រូវនានាព្រោះតែគេខ្វះភាពវាងវៃ » ។ តើអ្នកយល់យ៉ាងដែរចំពោះមតិនេះ ។

❷-ប្រធាន : សុភាសិតមួយឃ្លាបានលើកឡើងថា «នារីបង្ហិលចង្រ្កានមិនជុំ» ។ តើអ្នកយល់យ៉ាងណាដែរចំពោះសុភាសិតនេះ ។ ចូរពិភាក្សាដោយភ្ជាប់ឧទាហរណ៍ពីក្នុងអក្សរសិល្ប៍ថ្នាក់ទី១២ ។

❸-ប្រធាន : អក្សរសិល្ប៍ថ្នាក់ទី១២ អប់រំយុវជនអោយផ្តោតតែទៅលើបញ្ហាសង្គមវិទ្យា ។ តើអ្នកយល់យ៉ាងណាដែរចំពោះមតិខាងលើនេះ ?

២- ប្រធានពន្យល់

❶-ប្រធាន : អំនាចផ្តាច់ការក្តី ពន្ធនាគារក្តី អាចផ្តាច់ជីវិតមនុស្សអាចឃុំឃាំងរូបកាយមនុស្សបានប៉ុន្តែវាពុំអាចបំបាត់ ឧត្តមគតិមនុស្សបានឡើយ ។ តាមរយៈទស្សនៈនេះចូរអ្នកធ្វើការឆ្លុះបញ្ចាំងពីករណីតួអង្គនានា ក្នុងអក្សរសិល្ប៍ ថ្នាក់ទី១២ ។

❷-ប្រធាន : ពូហាំក្នុងរឿងថៅកែចិត្តចោរជាអ្នកដែលមានជំហរមុះមុតក្នុងការដោះស្រាយវិបត្តិគ្រួសារនិងវិបត្តិផ្ទាល់ខ្លួន ។ ចូរបង្ហាញ

❸-ប្រធាន: តាមរយៈអក្សរសិល្ប៍ថ្នាក់ទី១២ នឹងបង្កើតបានន្ធវ ធនធានមនុស្ស ដែលពោរពេញទៅដោយគុណធម៌ទ្រទ្រង់ជាតិ និង ប្រជា-រាស្ត្រអោយមានអរិយធម៌រុងរឿង ។ ចូរបង្ហាញ ។

www.budinst.gov.kh www.elibraryofcambodia.org

❹-ប្រធាន : ព្រះពុទ្ធទ្រង់ទូន្មានសត្វលោកថា «ពៀរវិងាប់ដោយការមិនចងពៀរ» ។ តែទ្រឹស្តីនេះពុំអាចយកមកអនុវត្តបានទេ ចំពោះតួអង្គមួយចំនួនក្នុងអក្សរសិល្ប៍ថ្នាក់ទី១២ ។ តើមកពីមូលហេតុអ្វី ? ចូរបង្ហាញ ។

សៀវភៅ «យល់ដឹងពីចប្បាបមិនទៅទៅ» សំរាប់សិស្សដែលប្រលងជាប់សញ្ញាបំត្រ មធ្យមសិក្សាភីរតទី២ រួចហើយចង់ស្វែងយល់ត្រៀមប្រលងជ្រើសៗ ។

អ្នករៀបរៀង

ម៉ិញ - លីចាន

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

(មជ្ឈមណ្ឌលភាសាបុរីមហាសុវណ្ណ)
វិទ្យាស្ថាន សូក្រាត អភិវឌ្ឍន៍ ខ្ពស់បំផុត
SOCRATES INSTITUTE FOR DEVELOPMENT
AND ADVANCED LEARNING (SIFDAL)

ផ្តល់សេវាកម្មជូនដូចជា :

- អរិញ្ញាប័ត្រផ្នែកសេដ្ឋកិច្ច
- ថ្នាក់ប្រកាសនីយ័បត្រផ្នែកសេដ្ឋកិច្ច
- វិទ្យាសាស្ត្រកុំព្យូទ័រ
- ថ្នាក់ពាណិជ្ជកម្មរយៈពេលខ្លី
- ថ្នាក់ភាសាបរទេសតាមបែបអន្តរជាតិ
- ថ្នាក់បង្រៀនភាសាអង់គ្លេសពេញម៉ោង
- ថ្នាក់ភាសាអង់គ្លេសសំរាប់មនុស្សពេញវ័យ
- ថ្នាក់ចំណេះដឹងទូទៅមាប៉ាពីទីឥណ្ឌូមហាវិទ្យាល័យ

គ្រូល្បីៗ មានសមត្ថភាពគរុកោសល្យត្រឹមត្រូវ ។

អាស័យដ្ឋានផ្ទះលេខ ២២ CDE ផ្លូវ ១៥២ ច្រកចូល
បណ្ណាគារ ជួលិណា សង្កាត់វាលវង់ ខ័ណ្ឌ ៧មករា
TEL : (023) 724 949 - 720855

មានលក់ដុំ និង រាយ លក់រាយនៅ:

- តូបលេខ ១៤ (ផ្សារអូរឬស្សី) TEL : 018 814 225
- តូបលេខ ៦៧ (ផ្សារចំការដូង) TEL : 018 815 693
- បណ្ណាគារតន្ត្រទេវី (ក្រុងចាត់ដំបង) អរគុណ

www.budinst.gov.kh www.elibraryofcambodia.org